សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ
និងវិទ្យាសាស្ត្រសេដ្ឋកិច្ច

សារណាបញ្ចប់ការសិក្សា

យុត្តិធម៌សម្រាប់អនីតិជនក្នុងរឿងក្តីព្រហ្មទណ្ឌ

ស្រាវជ្រាវចាប់ពីថ្ងៃទី ១៨ ខែ មីនា ឆ្នាំ ២០១៩ ដល់ថ្ងៃទី ១៦ ខែ ឧសភា ឆ្នាំ ២០១៩

ស្រាវជ្រាវដោយ

និស្សិតឈ្មោះ **សាំង រដ្ឋា**
រ៉ា សម្បត្តិ

សាស្ត្រាចារ្យណែនាំ

លោក **ហ៊ីង ឡេង**

ថ្នាក់បរិញ្ញាបត្រ **នីតិសាស្ត្រ**
ជំនាន់ទី ១៩

ឆ្នាំចូលសិក្សា ២០១៥
ឆ្នាំសរសេរសារណា ២០១៩

សេចក្តីថ្លែងអំណរគុណ

ខ្ញុំបាទឈ្មោះ **សាំង រដ្ឋា** សូមឱនកាយថ្វាយបង្គំ អភិវន្ទនកិច្ច និងសម្តែងនូវកតញ្ញូតាធម៌ ចំពោះលោកឪពុកឈ្មោះ **សាំង ហ៊ីន** និងអ្នកម្តាយឈ្មោះ **ពាង សុគន្ធ** អ្នកដ៏មានគុណទាំងទ្វេរ អ្វីប្រៀបផ្ទឹមពុំបាន ដែលលោកទាំងទ្វេបានខិតខំចិញ្ចឹមបីបាច់ថែរក្សាតាំងពីតូច រហូតមកដល់ពេលបច្ចុប្បន្ន ។ ជាពិសេសលោកទាំងពីរបានខិតខំប្រឹងប្រែងអស់ពីកម្លាំងកាយ កម្លាំងចិត្ត ក្នុងការផ្គត់ផ្គង់ដើម្បីឲ្យខ្ញុំបាទ បានសិក្សារៀនសូត្រ ចាប់តាំងពីថ្នាក់បឋមសិក្សា អនុវិទ្យាល័យ វិទ្យាល័យ រហូតមកដល់ថ្នាក់មហាវិទ្យាល័យ ក្នុងពេលបច្ចុប្បន្ននេះទៀត ។ គុណូបការៈលោកអ្នកដ៏មានគុណទាំងពីរពិតជាមិនអាចកាត់ថ្លៃបាន ។ កូនសូមគោរពថ្លែងអំណរគុណ ចំពោះលោកទាំងពីរយ៉ាងជ្រាលជ្រៅបំផុតដែលរកអ្វីក្នុងលោកនេះមកប្រៀបផ្ទឹមបានឡើយ ។

ខ្ញុំបាទឈ្មោះ **ង៉ា សម្ប្បត្តិ** ជាកូនសូមគោរពប្រណិបត្តិដោយសេចក្តីកតញ្ញូតាធម៌ ចំពោះលោក ឪពុកឈ្មោះ **យី ង៉ា** និងអ្នកម្តាយ **ហ៊ុន ផល្លា** លោកទាំងទ្វេបានផ្តល់កំណើតដល់រូបកូន ។ លោកទាំងទ្វេជាអ្នកមានគុណយ៉ាងច្រើនលើសលប់ គ្មានអ្វីប្រៀបបានមកលើរូបកូន ព្រមទាំងបានខិតខំយកចិត្តទុកដាក់ចិញ្ចឹមបីបាច់ថែរក្សាផ្តល់ដំបូន្មាន ផ្តល់ភាពកក់ក្តៅជំនះរាល់ការលំបាក់គ្រប់បែបយ៉ាងជាពិសេសទំនុកបម្រុងឲ្យខ្ញុំបានសិក្សារៀនសូត្រតាំងពីថ្នាក់បឋមសិក្សា រហូតដល់បញ្ចប់ថ្នាក់បរិញ្ញាបត្រនៅមហាវិទ្យាល័យ ។

សូមគោរពថ្លែងអំណរគុណចំពោះ គណៈគ្រប់គ្រង សាស្ត្រាចារ្យ និងបុគ្គលិក មន្ត្រីរាជការទាំងអស់នៃ **សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច** ដែលបានយកចិត្តទុកដាក់ក្នុងការគ្រប់គ្រងនិងបង្រៀនដល់សិស្សនិស្សិតទាំងអស់ដោយសេចក្តីស្រលាញ់ពេញចិត្ត។

ជាពិសេស សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅជាទីបំផុតចំពោះ **លោកសាស្ត្រាចារ្យ ហ៊ាង ឡេង** ដែលបានខិតខំទាំងកម្លាំងកាយចិត្ត និង ប្រាជ្ញាស្មារតីដោយមិនខ្លាចនឿយហត់ក្នុងការផ្តល់នូវគំនិតល្អៗ ណែនាំ និងផ្តល់យោបល់ដ៏មានសារៈសំខាន់ឲ្យយើងចងក្រងបានជាសារណាបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រនេះ។

ជាថ្មីម្តងទៀត ក្រុមយើងខ្ញុំសូមគោរពជូនពរដល់លោកអ្នកមានគុណទាំងពីររបស់ពួកខ្ញុំ ព្រមទាំងគណៈគ្រប់គ្រង សាស្ត្រាចារ្យ មន្ត្រីរាជការ បុគ្គលិកនៃ **សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច** និង ជាពិសេសសូមគោរពថ្លែងអំណរគុណចំពោះ **លោកសាស្ត្រាចារ្យ ហ៊ាង ឡេង** សូមជូនពរឲ្យជួបប្រទះតែនឹងពរទាំងឡាយ ៥ប្រការ ៖ អាយុ វណ្ណៈ សុខៈ ពលៈ និងបដិភាណៈ កុំបីឃ្លៀងឃ្លាតឡើយ ព្រមទាំងទទួលបានភាពជោគជ័យគ្រប់ភារកិច្ច។

អារម្ភកថា

ជាបឋមខ្ញុំបាទ **សាំង រដ្ឋា** និង **រ៉ា សម្ផ្ការ** សូមស្វាគមន៍ដល់មិត្តអ្នកអានគ្រប់រូប ជាពិសេសព្រមទាំងសាស្ត្រាចារ្យជាទីគោរព សិស្សនិស្សិតជាទីរាប់អាន ។ ក្នុងនាមយើងខ្ញុំជានិស្សិតដែលកំពុងសិក្សានៅសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច យើងខ្ញុំបានរៀបចំសរសេរសារណាបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រនីតិសាស្ត្រ ក្រោមប្រធានបទស្តីពី **យុត្តិធម៌សម្រាប់អនីតិជនក្នុងរឿងក្តីព្រហ្មទណ្ឌ** ។ ប្រធានបទសារណាមួយនេះធ្វើឡើងដោយមានការគាំទ្រ និងការជួយលើកទឹកចិត្តបង្ហាត់បង្ហាញ កែតម្រូវយ៉ាងពេញទំហឹងពីសំណាក់ **លោកសាស្ត្រាចារ្យ ហ៊ីង ឡេង** ដែលជាសាស្ត្រាចារ្យផ្នែកនីតិសាស្ត្រ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ។

យើងខ្ញុំសង្ឃឹមយ៉ាងមុតមាំថា សារណាមួយនេះ និងចូលរួមជាវិភាគទានមួយចំណែកតូចនៅក្នុងដំណើរការកំណែទម្រង់ប្រព័ន្ធយុត្តិធម៌អនីតិជន និងសិទ្ធិសេរីភាពរបស់អនីតិជននៅក្នុងប្រទេសកម្ពុជា ហើយក៏ជាឯកសារស្រាវជ្រាវមួយថ្មីផ្សេងទៀត ដែលបំពេញឲ្យសេចក្តីត្រូវការជាចាំបាច់ដល់មជ្ឈដ្ឋានអ្នកសិក្សាស្រាវជ្រាវដែលបាន នឹងកំពុងជួបប្រទះការខ្វះខាតនូវផ្នែកឯកសារទាក់ទង និងប្រធានខាងលើនេះក្នុងពេលបច្ចុប្បន្ន ។

ម៉្យាងវិញទៀតយើងខ្ញុំសូមអភ័យទោសចំពោះចំណុចខ្វះខាតដែលមានក្នុងសារណានេះ។ យើងខ្ញុំទទួលយកនូវការរិះគន់ក្នុងន័យស្ថាបនាពីសំណាក់មិត្តអ្នកអានទាំងអស់គ្នា ដើម្បីធ្វើការកែលម្អសារណាមួយនេះឲ្យកាន់តែប្រសើរ។

មាតិកា

ទំព័រ

សេចក្តីផ្តើម ១
១. លំនាំបញ្ហានៃការស្រាវជ្រាវ ១
២. ចំណោទបញ្ហានៃការស្រាវជ្រាវ ២
៣. គោលបំណងនៃស្រាវជ្រាវ ២
៤. ដែនកំណត់នៃការស្រាវជ្រាវ ៣
៥. វិធីសាស្ត្រស្រាវជ្រាវ ៣
៦. សារៈសំខាន់នៃការស្រាវជ្រាវ ៣
៧. រចនាសម្ព័ន្ធនៃការស្រាវជ្រាវ ៣

ជំពូកទី ១

សិទ្ធិ និងការទទួលបានការការពាររបស់អនីតិជន

ផ្នែកទី១ : សញ្ញាណទូទៅ ៤
១.១. និយមន័យ ៤
១.២. គោលដៅ ៤
១.៣. គោលបំណង ៥
១.៤. វិសាលភាព ៥
ផ្នែកទី២ : គោលការណ៍ និងសិទ្ធិជាមូលដ្ឋានរបស់អនីតិជន ៦
២.១. គោលការណ៍ជាមូលដ្ឋាន ៦
២.២. សិទ្ធិជាមូលដ្ឋាន ៩
ផ្នែកទី៣ : ការទទួលខុសត្រូវព្រហ្មទណ្ឌ និងរដ្ឋប្បវេណីរបស់អនីតិជន ១០
៣.១. ការទទួលខុសត្រូវព្រហ្មទណ្ឌ ១០
៣.១.១. នីតិភាពនៃការទទួលខុសត្រូវព្រហ្មទណ្ឌ ១១
៣.១.២. ការកំណត់អាយុនៃការទទួលខុសត្រូវព្រហ្មទណ្ឌ ១២
៣.២. មូលហេតុនៃការមិនទទួលខុសត្រូវ ឬការសម្រាលការទទួលខុសត្រូវព្រហ្មទណ្ឌ ១២
៣.៣. ការទទួលខុសត្រូវផ្នែករដ្ឋប្បវេណី ១៤
ផ្នែកទី៤ : សមត្ថកិច្ចមន្ត្រីនគរបាលយុត្តិធម៌ និងការស៊ើបអង្កេត ១៥
៤.១. សមត្ថកិច្ចមន្ត្រីនគរបាលយុត្តិធម៌ ១៦

៤.១.១. ការចាប់ខ្លួន ១៦
៤.១.២. ការឃាត់ខ្លួន ១៨
៤.២. ការសាកសួរ និងការស្តាប់ចម្លើយរបស់មន្ត្រីនគរបាលយុត្តិធម៌ ២០
៤.៣. រយៈពេលនៃការឃាត់ខ្លួនរបស់មន្ត្រីនគរបាលយុត្តិធម៌ ២១

ជំពូកទី ២

សមត្ថកិច្ចរបស់ស្ថាប័នតុលាការចំពោះអនីតិជន

ផ្នែកទី១ : ការចោទប្រកាន់របស់អយ្យការចំពោះអនីតិជន ២២
១.១. សមត្ថកិច្ចរបស់អង្គការអយ្យការ ២២
១.១.១. ការផ្ទៀងផ្ទាត់អាយុរបស់អនីតិជន ២២
១.១.២. ការសួរចម្លើយដោយតំណាងអយ្យការ ២២
១.១.៣. ការតម្កល់រឿងទុកឥតចាត់ការចំពោះអនីតិជន ២៣
១.២. អំណាចរបស់តំណាងអយ្យការក្នុងការបង្ហែ ២៣
១.២.១. ការឲ្យដំណឹងអំពីការចោទប្រកាន់ ២៤
១.២.២. ការបំបែកសំណុំរឿង ២៤
ផ្នែកទី២ : ការស៊ើបសួរដោយចៅក្រមស៊ើបសួរចំពោះអនីតិជន ២៤
២.១. សមត្ថកិច្ចនៃការស៊ើបសួរ ២៤
២.១.១. ការបើកការស៊ើបសួរ និងការបង្ហាញខ្លួនរបស់អនីតិជននៅពេលស៊ើបសួរ ២៥
២.១.២. ការស្តាប់ចម្លើយអនីតិជន ២៥
២.១.៣. ការព្យួរការសិក្សា និងការងារសម្រាប់អនីតិជន ២៦
២.២. អំណាចរបស់ចៅក្រមស៊ើបសួរ ២៦
២.២.១. អំណាចក្នុងការបង្ហែ ២៦
២.២.២. អំណាចក្នុងការឃុំខ្លួនបណ្តោះអាសន្ន ២៧
២.២.៣. អំណាចក្នុងការដាក់ឲ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ ២៨
២.២.៤. ថិរវេលានៃការឃុំខ្លួនបណ្តោះអាសន្ន ២៩
២.៣. ដីកាដំណោះស្រាយរបស់ចៅក្រមស៊ើបសួរ ៣០
២.៤. ការប្តឹងទៅសភាស៊ើបសួរ និងការបញ្ជូនរឿងទៅសភាស៊ើបសួរនៃសាលាឧទ្ធរណ៍ ៣០
ផ្នែកទី៣ : ការជំនុំជម្រះចំពោះអនីតិជនរបស់សាលាដំបូង ៣១
៣.១. សមត្ថកិច្ចនៃការជំនុំជម្រះរឿងក្តីអនីតិជននៃសាលាដំបូងរាជធានី-ខេត្ត ៣១

៣.១.១. សមត្ថកិច្ចនៃការជំនុំជម្រះ ៣១
៣.១.២. ការផ្តល់អាទិភាពលើរឿងក្តីអនីតិជន ៣១
៣.១.៣. សវនាការជាអសាធារណៈ ៣១
៣.១.៤. ពេលសវនាការ ៣២
៣.១.៥. ការឲ្យរួចផុតពីបទចោទ ៣២
៣.២. ជំនួយរបស់មេធាវី ៣៣
៣.៣. ការផ្តល់ព័ត៌មានអំពីសិទ្ធិដល់អនីតិជនដោយតុលាការ ៣៣
៣.៤. ការឆ្លើយសារភាពរបស់អនីតិជននៅពេលសវនាការ ៣៣
៣.៥. ការប្រកាសសាលក្រម ៣៤
ផ្នែកទី៤ : តុលាការជាន់ខ្ពស់ចំពោះរឿងក្តីអនីតិជន ៣៤
៤.១. សមត្ថកិច្ចតុលាការជាន់ខ្ពស់ចំពោះរឿងក្តីអនីតិជន ៣៤
៤.២. អំណាចរបស់តុលាការជាន់ខ្ពស់ក្នុងការបង្ហៃ ៣៤
៤.៣. នីតិវិធីរបស់តុលាការជាន់ខ្ពស់ ៣៦
ផ្នែកទី៥ : ការបង្ហៃអនីតិជនចេញពីប្រព័ន្ធតុលាការ ៣៦
៥.១. គោលបំណង និងគោលការណ៍នៃការបង្ហៃ ៣៦
៥.២. នីតិវិធីនៃការបង្ហៃ ៣៧
៥.៣. លក្ខខណ្ឌអប្បបរមានៃការបង្ហៃ ៣៧
៥.៤. លក្ខណៈវិនិច្ឆ័យសម្រាប់ការបង្ហៃ ៣៨
៥.៥. ផែនការនៃការបង្ហៃ ៣៨
៥.៥.១. វិធាននៃការបង្ហៃ ៣៨
៥.៥.២. ការរៀបចំបង្កើតផែនការបង្ហៃ ៣៩
៥.៥.៣. ការសម្រេចអំពីផែនការបង្ហៃដោយអាជ្ញាធរទទួលបន្ទុកបង្ហៃ ៤០
៥.៦. ការអនុវត្តផែនការបង្ហៃ ៤០
៥.៦.១. ការអនុវត្ត ៤០
៥.៦.២. ការកែប្រែវិធានការបង្ហៃក្នុងពេលអនុវត្ត ៤០
៥.៦.៣. បរាជ័យក្នុងការអនុវត្តវិធានការបង្ហៃ ៤០
៥.៧. ការបញ្ចប់នីតិវិធីបង្ហៃ ៤១

ជំពូកទី ៣

ការទទួលទោស ការដោះលែង និងការលើកលែងទោសចំពោះអនីតិជន

ផ្នែកទី ១ : ការផ្តន្ទាទោស និងការអនុវត្តទោស ៤២
១.១.ការផ្តន្ទាទោសចំពោះអនីតិជន ៤២
១.២.ការអនុវត្តទោសចំពោះអនីតិជន ៤៣
១.៣. ទោសដែលអាចអនុវត្តបានចំពោះអនីតិជន ៤៤
ផ្នែកទី ២ : ការផ្តល់ និងការមានតីតិសម្បទាឡើងវិញ ៤៤
២.១. ការផ្តល់នីតិសម្បទាឡើងវិញតាមផ្លូវតុលាការ ៤៥
២.២. ការមាននីតិសម្បទាឡើងវិញតាមច្បាប់កំណត់ ៤៦
ផ្នែកទី ៣ : សមត្ថកិច្ចគ្រប់គ្រងអនីតិជន ៤៧
៣.១. មណ្ឌលយុវនីតិសម្បទា ៤៧
៣.២. សិទ្ធិជាមូលដ្ឋានរបស់អនីតិជនក្នុងមណ្ឌលយុវនីតិសម្បទា ៤៨
៣.៣. ការធ្វើអធិការកិច្ចមណ្ឌលយុវនីតិសម្បទា ៤៨
៣.៤. ភ្នាក់ងារសង្គមកិច្ច ៤៩
ផ្នែកទី ៤ : ការដោះលែង ការលើកលែងទោស និងការបន្ថយទោសអនីតិជន ៤៩
៤.១. ការដោះលែងដោយមានលក្ខខណ្ឌ ៤៩
៤.១.១. លក្ខខណ្ឌទាក់ទងនឹងបុគ្គល ៤៩
៤.១.២. លក្ខខណ្ឌទាក់ទងនឹងគំនិត មារយាទ និងការទទួលរងទោស ៥០
៤.២. ការលើកលែងទោស និងការបន្ធូរបន្ថយទោសចំពោះអនីតិជន ៥០
សេចក្តីសន្និដ្ឋាន ៥១
អនុសាសន៍ ៥៣
គន្ថនិទ្ទេស
ឧបសម្ព័ន្ធ

សេចក្តីផ្តើម

សេចក្តីផ្តើម

១. លំនាំបញ្ហានៃការស្រាវជ្រាវ

ប្រទេសជាច្រើននៅក្នុងពិភពលោកមិនថាប្រទេសនោះ ប្រកាន់យករបបនៃការដឹកនាំប្រទេសរបស់ខ្លួនបែបកុម្មុយនីស្តក្តី ឬបែបប្រជាធិបតេយ្យក្តី គេតែងតែបង្កើតច្បាប់សម្រាប់គ្រប់គ្រងប្រទេសជាតិ ដើម្បីកុំឲ្យប្រទេសរបស់ខ្លួនមានភាពអនាធិបតេយ្យ គ្មានរបៀបរៀបរាយ អសន្តិសុខ គ្មានសណ្តាប់ធ្នាប់ ឬមានការប្រើប្រាស់សិទ្ធិ ដែលច្បាប់បានផ្តល់ឲ្យខ្លួនហួសពីដែនកំណត់ជាដើម ។ ប្រទេសមួយចំនួន បានបង្កើតឲ្យមានវិធាននៃការទទួលខុសត្រូវចំពោះអំពើមួយចំនួនមិនថាជាប្រជាពលរដ្ឋរបស់ខ្លួន ឬជនបរទេសឡើយ ឲ្យតែបានប្រព្រឹត្តបទល្មើសណាមួយដែលបានប៉ះពាល់ដល់សង្គម ឬប្រទេសជាតិរបស់គេត្រូវតែទទួលខុសត្រូវចំពោះអំពើល្មើសរបស់ខ្លួននោះ ហើយក៏មានទណ្ឌកម្មជាច្រើនដើម្បីយកមកអនុវត្តចំពោះបុគ្គលទាំងនោះមានដូចជា ៖ ការទទួលខុសត្រូវព្រហ្មទណ្ឌ ការទទួលត្រូវរដ្ឋប្បវេណី ចំពោះជនរងគ្រោះ ឬរដ្ឋជាអាទិ៍ ។

ចំណែកឯព្រះរាជាណាចក្រកម្ពុជាយើងវិញ ក៏មិនខុសពីប្រទេសទាំងនោះផងដែរ ដែលមានបទល្មើសមួយបានកើតឡើង ត្រូវតែមាននូវបុគ្គលណាម្នាក់ទទួលខុសត្រូវចំពោះបទល្មើសនោះ ។ បុគ្គលដែលប្រព្រឹត្តបទល្មើសអាចជារូបវន្តបុគ្គល ឬ នីតិបុគ្គល ។ រូបវន្តបុគ្គលមានការបែងចែកជាពីទៀតគឺ នីតិជន និង អនីតិជន ។ នីតិជន សំដៅទៅលើជនដែលមានអាយុចាប់ពី ១៨ ឆ្នាំ ឡើងទៅ ។ ចំពោះ អនីតិជន គឺសំដៅទៅលើជនដែលមានអាយុតិចជាង ១៨ ឆ្នាំ នៅពេលជននោះបានប្រព្រឹត្តបទល្មើស ។ ហើយជាពិសេសគឺ តម្រូវឲ្យមានការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌ ឬសំណងរដ្ឋប្បវេណីចំពោះជនរងគ្រោះ ឬការដាក់ទណ្ឌកម្មផ្សេងទៀត តាមរយៈការដាក់ពន្ធនាគារ ឬមណ្ឌលយុវនីតិសម្បទា ដើម្បីយកបុគ្គលនោះមកធ្វើការអប់រំណែនាំ ឲ្យដឹងអំពីកំហុសរបស់ខ្លួន និងបន្ទាប់ពីការអនុវត្តទោស រួចហើយនោះនឹងបញ្ជូនជននោះទៅរស់នៅក្នុងសង្គមវិញ ដើម្បីធ្វើជាពលរដ្ឋល្អដែលមានប្រយោជន៍សម្រាប់សង្គម គ្រួសារ មិត្តភក្តិជាដើម ។ ហើយបើក្រឡេកទៅមើលច្បាប់ស្តីពីយុត្តិធម៌អនីតិជន ឆ្នាំ ២០១៦ ដែលច្បាប់នេះបានឲ្យមានការទទួលខុសត្រូវចំពោះទង្វើរបស់ខ្លួន ជម្រុញឲ្យមានភាពស្រុះស្រួលរវាងអនីតិជន និងជនរងគ្រោះ ការពារជនរងគ្រោះ និងសហគមន៍ព្រមទាំងជួយដល់ការស្តារនីតិសម្បទា និងការធ្វើសមាហរណកម្មអនីតិជនទៅក្នុងសង្គម និងសហគមន៍។ ម្យ៉ាងទៀតច្បាប់ស្តីពីយុត្តិធម៌អនីតិជន ក៏មានវិសាលភាពគ្រប់គ្រងទៅលើប្រព័ន្ធយុត្តាធិការ និងការប្រព្រឹត្តទៅនៃប្រព័ន្ធយុត្តិធម៌របស់អនីតិជន ។

បើយោងតាមមាត្រា ៥០ នៃអនុសញ្ញាស្តីពីសិទ្ធិកុមារ បញ្ជាក់ច្បាស់ពីសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌របស់កុមារ និងកំណត់កាតព្វកិច្ចឲ្យរដ្ឋនានាពិចារណាទៅលើអាយុរបស់

កុមារ និងឆន្ទៈពិតប្រាកដក្នុងការលើកកម្ពស់ការដាក់បញ្ចូលកុមារ ដើម្បីដើរតួនាទីស្ថាបនាក្នុងសង្គម ព្រមទាំងលើកស្នូយឲ្យមានការបង្កើតច្បាប់ នីតិវិធីនានា អាជ្ញាធរ និងស្ថាប័ននានា ត្រូវអនុវត្តឲ្យបានពិតប្រាកដចំពោះកុមារ ។ ជាពិសេសមាត្រា ៤០នេះបង្គាប់ថា រដ្ឋគួរបង្កើតវិធានការនានាដើម្បីដោះស្រាយលើករណីកុមារ ដោយមិនចាំបាច់មានវិធានការចុងក្រោយតាមនីតិវិធីតុលាការនោះទេ និងបង្កើតវិធានការផ្សេងពីនេះវិញដូចជា ការថែទាំ ការណែនាំ និងការតាមដាន ការប្រឹក្សាយោបល់ ការសាកល្បង ការបីបាច់ថែរក្សា ការអប់រំ និងកម្មវិធីបណ្តុះបណ្តាលវិជ្ជាជីវៈ ក្នុងចំណោមវិធានការបែបនោះដទៃទៀត ។

២. ចំណោទបញ្ហានៃការស្រាវជ្រាវ

ជាគោលការណ៍ គេមិនអាចឲ្យជនដែលមិនដឹងខុសត្រូវពីភាពធ្ងន់ធ្ងរនៃអំពើរបស់ខ្លួនឲ្យទទួលទោសនោះទេ ។ ដោយសង្កេតឃើញថាអនីតិជនជាជនដែលមានសមត្ថភាពយល់ដឹងពីអំពើនៅមានកម្រិតឡើយ ដូច្នេះហើយទើបមានសំនួរចោទឡើង ថាតើមានវិធានការបែបណាចំពោះអនីតិជនប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌ ? តើអនីតិជនដែលមានអាយុចាប់ពី១៤ ឆ្នាំ ដល់ក្រោម១៨ ឆ្នាំត្រូវទទួលខុសត្រូវព្រហ្មទណ្ឌយ៉ាងដូចម្តេច ? ហើយក្រៅពីនេះតើគួរអនុវត្តនីតិវិធីបែបណាចំពោះអនីតិជនប្រព្រឹត្តបទល្មើស ?

ដោយសារតែមាននូវចំណោទបញ្ហាទាំងអស់នេះហើយទើបនៅក្នុងការសិក្សាស្រាវជ្រាវរបស់យើងខ្ញុំបានធ្វើការសម្រេចចិត្តយ៉ាងមុតមាំថាត្រូវតែជ្រើសរើសយកប្រធានបទស្តីពី " **យុត្តិធម៌សម្រាប់អនីតិជនក្នុងរឿងក្តីព្រហ្មទណ្ឌ** " នេះឡើងមកសរសេរក្នុងន័យថាដើម្បីបកស្រាយរាល់ចម្ងល់ដែលបានចោទសួរខាងលើ។

៣. គោលបំណងនៃការស្រាវជ្រាវ

នៅក្នុងការសិក្សាស្រាវជ្រាវសារណានេះដែរ គឺធ្វើឡើងក្នុងគោលបំណងដើម្បីស្វែងយល់អំពីភាពមិនច្បាស់លាស់មួយចំនួន ក៏ដូចជាបកស្រាយបំភ្លឺអំពីចំណោទបញ្ហាគតិយុត្តិដូចដែលបានលើកឡើងពីខាងលើស្រាប់ ។ លើសពីនេះទៅទៀត គឺដើម្បីពង្រីក និងពង្រឹងសមត្ថភាពផ្ទាល់ខ្លួនបន្ថែមទៀត ដែលទាក់ទងនឹងវិស័យព្រហ្មទណ្ឌនេះ ។ ហើយចំពោះសមិទ្ធផល ដែលបានមកពីការសិក្សាស្រាវជ្រាវនេះ ក៏ជាផ្នែកមួយនៃការចូលរួមចំណែកក្នុងការអភិវឌ្ឍន៍វិស័យព្រហ្មទណ្ឌ និងទុកជាឯកសារសម្រាប់ឲ្យសិស្ស និស្សិតជំនាន់ក្រោយ និងចំពោះសាធារណៈជនទាំងឡាយ ដែលមានបំណងចង់ធ្វើការសិក្សា និង ស្វែងយល់អំពីប្រធានបទមួយនេះ អាចយល់កាន់តែច្បាស់លាស់ថែមទៀត ។

៤. ដែនកំណត់នៃការស្រាវជ្រាវ

ដើម្បីធ្វើការឆ្លើយតបទៅ នឹងប្រធានបទ ដែលបានលើកឡើងក្នុងចំណោទបញ្ហាខាងលើនេះ សារណានេះ ត្រូវបានធ្វើការសិក្សាស្រាវជ្រាវទៅលើឯកសារជាមូលដ្ឋាន គឺរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ១៩៩៣ ក្រមព្រហ្មទណ្ឌ ឆ្នាំ២០១០ ក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧ ច្បាប់ស្តីពីយុត្តិធម៌ អនីតិជន ឆ្នាំ២០១៦ និងអនុសញ្ញាស្តីពីសិទ្ធិកុមារ និងឯកសាររួមផ្សំដែលពាក់ព័ន្ធទាំងឡាយ ដែលបានលើកឡើងនៅក្នុងឯកសារយោងស្រាប់ ដើម្បីសរសេរសារណានេះឡើង ។ នៅក្នុងការសរសេរសារណានេះ គឺបានលើកឡើងតែពីការពាក់ព័ន្ធទាំងឡាយណា ដែលទាក់ទងជាមួយនឹងយុត្តិធម៌សម្រាប់អនីតិជន នីតិវិធីដែលត្រូវយកមកអនុវត្តចំពោះអនីតិជន និងទោសដែលអនីតិជនត្រូវទទួលប៉ុណ្ណោះ ។

៥. វិធីសាស្ត្រស្រាវជ្រាវ

សារណានេះ ត្រូវបានរៀបរៀងឡើងដោយប្រើប្រាស់នូវ វិធីសាស្ត្របែបពិពណ៌នា និងវិភាគ ។ យើងខ្ញុំបានធ្វើការសិក្សាស្រាវជ្រាវដោយ ធ្វើការប្រមូលព័ត៌មានទាំងឡាយ ក៏ដូចជាឯកសារពាក់ព័ន្ធទៅនឹងប្រធានបទនៃសារណានេះដើម្បីឲ្យកាន់តែមានភាពត្រឹមត្រូវច្បាស់លាស់ និងមានប្រសិទ្ធិភាពខ្ពស់ ។ ព័ត៌មានទាំងឡាយត្រូវបានជ្រើសរើស និង ដកស្រង់ចេញពីប្រភពល្អៗ ដូចជា ជាការបកស្រាយរបស់នីតិករ អ្នកមានបទពិសោធន៍នៅក្នុងវិស័យនេះផ្ទាល់ មតិយោបល់ពីអ្នកមានជំនាញការខាងច្បាប់ព្រហ្មទណ្ឌ ច្បាប់សំខាន់ៗរបស់ព្រះរាជាណាចក្រកម្ពុជា និងឯកសារដែលពាក់ព័ន្ធមួយចំនួនទៀតផងដែរ ។

៦. សារៈសំខាន់នៃការស្រាវជ្រាវ

សមិទ្ធផលដែលទទួលបានពីការស្រាវជ្រាវនេះ និងក្លាយទៅជាទុនមួយសម្រាប់ជាឯកសារជំនួយស្មារតីដល់ប្អូនៗ ក៏ដូចជាសិស្សានុសិស្ស និស្សិតជំនាន់ក្រោយ និងសាធារណៈជនដទៃទៀត ដើម្បីយកទៅធ្វើការសិក្សាស្វែងយល់ និងជាចំណេះដឹងបន្ថែម ក៏ដូចជាអនុញ្ញាតឲ្យប្អូនៗអាចយល់បានពីផ្នែកមួយនៃនីតិព្រហ្មទណ្ឌអំពី យុត្តិធម៌សម្រាប់អនីតិជនក្នុងរឿងក្តីព្រហ្មទណ្ឌនេះផងដែរ ។

៧. រចនាសម្ព័ន្ធនៃការស្រាវជ្រាវ

ចំពោះរចនាសម្ព័ន្ធនៃការស្រាវជ្រាវនេះ ត្រូវបានធ្វើការបែងចែកជា ៣ ជំពូក ៖

ជំពូកទី១ : សិទ្ធិ និងការទទួលបានការការពាររបស់អនីតិជន

ជំពូកទី២ : សមត្ថកិច្ចរបស់ស្ថាប័នតុលាការចំពោះអនីតិជន

ជំពូកទី៣ : ការទទួលទោស ការដោះលែង និងការលើកលែងទោសចំពោះអនីតិជន។

ជំពូកទី ១

សិទ្ធិ និងការទទួលបាន
ការការពាររបស់អតីតិជន

ជំពូកទី ១
សិទ្ធិ និងការទទួលបានការពាររបស់អនីតិជន

ផ្នែកទី១ : សញ្ញាណទូទៅ

១.១. និយមន័យ

- **យុត្តិធម៌អនីតិជន** សំដៅដល់ការការពារសិទ្ធិអនីតិជនតាមរយៈយន្តការ វិធាន និងនីតិវិធីទាំងឡាយដែលត្រូវគោរព និងអនុវត្តដោយហ្មត់ចត់ ព្រមទាំងវិធាននៃការកំណត់ទោសក្នុងករណីអនីតិជនប្រព្រឹត្តបទល្មើស[1] ។
- **អាជ្ញាធរមានសមត្ថកិច្ច** សំដៅដល់បុគ្គល ឬស្ថាប័នដែលអនុវត្តដោយស្របច្បាប់នូវមុខងាររបស់ខ្លួនដែលពាក់ព័ន្ធនឹងរឿងក្តីអនីតិជន ។
- **អនីតិជន** សំដៅដល់ជនដែលមានអាយុតិចជាង១៨(ដប់ប្រាំបី)ឆ្នាំ នៅពេលប្រព្រឹត្តបទល្មើស ។
- **អ្នកតំណាងដែលច្បាប់បានកំណត់** សំដៅដល់អ្នកមានអំណាចមេបា អ្នកអាណាព្យាបាលសម្រាប់អនីតិជន និងអ្នកអាណាព្យាបាលទូទៅ ។
- **នីតិវិធីកុមារមេត្រី** សំដៅដល់ដំណើរការ និងនីតិវិធីដែលពាក់ព័ន្ធនឹងការលើកទឹកចិត្តឲ្យអនីតិជនចូលរួមក្នុងរឿងក្តីតាមរយៈការប្រើប្រាស់ភាសា និងអាកប្បកិរិយាក្នុងកម្រិតដែលអនីតិជនអាចយល់បាន និងក្នុងបរិយាកាសដែលផ្តល់ឲ្យអនីតិជននូវសុវត្ថិភាព សន្តិសុខ សិទ្ធិនិងតម្រូវការជាមូលដ្ឋាន ។
- **ភ្នាក់ងារសង្គមកិច្ច** សំដៅដល់មន្ត្រីរបស់ក្រសួង មន្ទីរ ការិយាល័យទទួលបន្ទុកវិស័យសង្គមកិច្ចរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឬបុគ្គលផ្សេងទៀតដែលទទួលបានការបណ្តុះបណ្តាលជំនាញផ្នែកកុមារ និងច្បាប់ពាក់ព័ន្ធនឹងអនីតិជន ហើយត្រូវទទួលបានការតែងតាំង ឬទទួលស្គាល់ពីរដ្ឋមន្ត្រីក្រសួងទទួលបន្ទុកវិស័យសង្គមកិច្ច ។

១.២. គោលដៅ

យើងមើលឃើញថាច្បាប់ ជាឧបករណ៍មួយយ៉ាងសំខាន់ដែលប្រើសម្រាប់គ្រប់គ្រងមនុស្សក្នុងសង្គមមួយ ដែលមានប្រជាពលរដ្ឋជាច្រើនលាន់នាក់រស់នៅ ហើយបុគ្គលម្នាក់មានចិត្តគំនិតខុសគ្នាទៅតាមទង្វើរ ការប្រព្រឹត្តរបស់មនុស្សម្នាក់ៗនោះ ដោយសារតែមនុស្សមានគំនិតបញ្ញាស្មារតីនៃការយល់ដឹងផ្សេងគ្នានេះដែលជាហេតុនាំឲ្យរដ្ឋជាតួអង្គដ៏សំខាន់ ក្នុងការបង្កើតនូវក្បួនច្បាប់វិន័យដើម្បីសំដៅនូវវិធីសាស្ត្រដែលអាច នឹងដោះស្រាយរាល់បញ្ហាជម្លោះជូនប្រជា

[1] មាត្រា៤ នៃច្បាប់ស្តីពីយុត្តិធម៌អនីតិជន នាខែកក្កដា ឆ្នាំ២០១៦

ពលរដ្ឋរបស់ខ្លួន។ ដូច្នេះហើយទើបមាន(ច្បាប់ស្តីពីយុត្តិធម៌អនីតិជន)ច្បាប់នេះមានគោលដៅកំណត់អំពីវិធាន និងនីតិវិធីទាំងឡាយដែលត្រូវគោរព និងប្រព្រឹត្តតាមដោយហ្មត់ចត់ ដើម្បីកំណត់ឲ្យបានច្បាស់នូវអត្ថិភាពនៃបទល្មើសព្រហ្មទណ្ឌណាមួយដែលប្រព្រឹត្តដោយអនីតិជន ។ ដោយយោងតាមខ្លឹមសារនៃច្បាប់នេះ គឺផ្តោតសំខាន់ទៅលើយន្តការទាំងឡាយណាដែលផ្តល់ឧត្តមប្រយោជន៍ជូនទៅដល់អនីតិជន ក៏ដូចជាការប្រើប្រាស់នូវនីតិវិធីដោះស្រាយមួយដែលមានការគោរពទៅដល់សិទ្ធិសេរីភាព និងសេចក្តីថ្លៃថ្នូរដែលជាកត្តាមួយនាំឲ្យមានភាពមិនស្មើភាពគ្នាចំពោះមុខច្បាប់ រវាងការប្រព្រឹត្តនូវបទល្មើសដូចគ្នាដែលបង្កឡើងដោយនីតិជន និងអនីតិជន ។

១.៣. គោលបំណង

ច្បាប់ស្តីពីយុត្តិធម៌អនីតិជន មានគោលបំណងឲ្យមានការទទួលខុសត្រូវចំពោះទង្វើរបស់ខ្លួនជំរុញឲ្យមានភាពស្រុះស្រួលរវាងអនីតិជននឹងជនរងគ្រោះ ការការពារជនរងគ្រោះ និងសហគមន៍ ព្រមទាំងជួយគាំទ្រដល់ការស្តារនីតិសម្បទា ការធ្វើសមាហរណកម្មអនីតិជនទៅក្នុងសង្គម និងសហគមន៍ ។ ធានាការការពារផលប្រយោជន៍សង្គម និងសហគមន៍ ។ ជាពិសេសការលើកស្ទួយផ្នែកសិទ្ធិមនុស្សរបស់កុមារទំនាស់នឹងច្បាប់ ហើយនិងការពារសិទ្ធិរបស់អនីតិជន និងជនរងគ្រោះព្រមទាំងមានការធានាការពារសិទ្ធិ ឧត្តមប្រយោជន៍របស់អនីតិជនដែលប្រព្រឹត្តបទល្មើស[2]។

១.៤. វិសាលភាព

ច្បាប់ស្តីពីយុត្តិធម៌អនីតិជន មានវិសាលភាពគ្រប់គ្រងទៅលើប្រព័ន្ធយុត្តាធិការ និងការប្រព្រឹត្តទៅនៃប្រព័ន្ធយុត្តិធម៌របស់អនីតិជន[3]។ ច្បាប់នេះអនុវត្តន៍បានចំពោះអនីតិជនណាមួយដែលត្រូវបានចោទថាបានប្រព្រឹត្តបទល្មើស និងនៅពេលប្រព្រឹត្តបទល្មើសដែលត្រូវបានចោទប្រកាន់ចំពោះអនីតិជននោះត្រូវមានអាយុក្រោម ១៨(ដប់ប្រាំបី)ឆ្នាំ និងជនដែលមានអាយុឈានចូល១៨ឆ្នាំ នៅមុនពេលឈានអនុវត្តនីតិវិធីនានាមកលើខ្លួន ។ មិនត្រឹមតែប៉ុណ្ណោះទេ ការអនុវត្តន៍ចំពោះអនីតិជនដែលជាប់សង្ស័យ ឬជនត្រូវចោទ ឬជនជាប់ចោទដែលបានប្រព្រឹត្តបទល្មើសផ្ទុយនឹងច្បាប់ ឬជនដែលត្រូវបានតុលាការកាត់ទោសរួចហើយ ។ អនីតិជនដែលមានអាយុចាប់ពី ១៤(ដប់បួន)ឆ្នាំ ដល់ក្រោម ១៨ (ដប់ប្រាំបី)ឆ្នាំ[4] ។

ច្បាប់ស្តីពីយុត្តិធម៌អនីតិជននេះ ជាច្បាប់មួយដែលចែងបន្ថែម និង គ្របដណ្តប់ពីលើច្បាប់ដែលនៅជាធរមានស្រាប់ដូចជាក្រមព្រហ្មទណ្ឌ និងក្រមនីតិវិធីព្រហ្មទណ្ឌ ។ ម្យ៉ាងវិញទៀតក្នុងករណីនីតិជនប្រព្រឹត្តបទល្មើសក្នុងអំឡុង ពេលដែលខ្លួននៅជាអនីតិជនប៉ុន្តែនីតិវិធីប្រឆាំង នឹង

[2] មាត្រា១ វាក្យខណ្ឌ១នៃច្បាប់ស្តីពីយុត្តិធម៌អនីតិជន នាខែកក្កដា ឆ្នាំ២០១៦

[3] មាត្រា៣ នៃច្បាប់ស្តីពីយុត្តិធម៌អនីតិជន នាខែកក្កដា ឆ្នាំ២០១៦

[4] មាត្រា៣ នៃច្បាប់ស្តីពីយុត្តិធម៌អនីតិជនទំនាស់នឹងច្បាប់នាខែសីហា ឆ្នាំ២០១១

នីតិជននោះត្រូវបានចាប់ផ្តើមក្រោយពីជននោះឈានចូលអាយុ ១៨ (ដប់ប្រាំបី)ឆ្នាំ[5] ក្នុងករណីនេះ ដែលត្រូវអនុវត្តតាមច្បាប់ព្រហ្មទណ្ឌ និងច្បាប់ស្តីពីនីតិវិធីព្រហ្មទណ្ឌទូទៅ ។ ការអនុវត្តច្បាប់ស្តីពីយុត្តិធម៌អនីតិជនត្រូវមានវិសាលភាពអនុវត្តដោយឥតលម្អៀងចំពោះ អនីតិជនដែលល្មើសដោយមិនប្រកាន់ប្រភេទអ្វីទាំងអស់ដូចជាពូជសាសន៍ ពណ៌សម្បុរ ភេទ ភាសា សាសនា មតិនយោបាយ ឬមតិផ្សេងៗ ប្រភពសម្បត្តិ ស្ថានភាពកំណើត ឬស្ថានភាពដទៃទៀត ។

ផ្នែកទី២ : គោលការណ៍ និងសិទ្ធិជាមូលដ្ឋានរបស់អនីតិជន

២.១. គោលការណ៍ជាមូលដ្ឋាន

ច្បាប់ស្តីពីយុត្តិធម៌អនីតិជនភាគច្រើន ផ្តើមចេញជាមួយការចែងអំពីគោលការណ៍ណែនាំ ដែលមានដកស្រង់ចេញពីអនុសញ្ញាស្តីពីសិទ្ធិកុមារ និងលិខិតុបករណ៍អន្តរជាតិដទៃផ្សេងៗទៀត[6] ។ កត្តានេះហើយទើបធ្វើឲ្យមានការចែងជាច្បាប់បែបនេះ ក្នុងគោលដៅដើម្បីបញ្ជាក់ឲ្យច្បាស់អំពីរបៀបដែលរដ្ឋមានវិធានការចំពោះកុមារដែលប្រព្រឹត្តបទល្មើស ហើយវាមានលក្ខណៈខុសប្លែកគ្នានូវវិធីសាស្ត្រដាក់ទោស ដែលមានចែងនៅក្នុងប្រព័ន្ធយុត្តិធម៌អនីតិជន ។ គោលការណ៍ទាំងនេះក៏បានផ្តល់នូវគោលការណ៍ណែនាំដល់ស្ថាប័នតុលាការ និងអាជ្ញាធររដ្ឋបាលផ្សេងៗនៅពេលដែលអាជ្ញាធរ ទាំងនោះកំពុងអនុវត្តឆន្ទានុសិទ្ធិរបស់ខ្លួនតាមច្បាប់កំណត់ ។ ហេតុដូចនេះហើយទើបមានបញ្ញត្តិ អំពីគោលការណ៍ដែលទាក់ទងទៅ និងឧត្តមប្រយោជន៍របស់កុមារដែលមានគោលការណ៍ដូចតទៅ ៖

- គោលការណ៍សមាមាត្រ ដែលដកស្រង់ចេញពីអនុសញ្ញាស្តីពីសិទ្ធិកុមារ ដែលមានខ្លឹមសារថា វិធានការឆ្លើយតបណាមួយ ចំពោះកុមារទំនាស់នឹងច្បាប់ត្រូវតែសមាមាត្រ មិនត្រឹមតែប្រភេទនៃបទល្មើសដែលបានចោទប្រកាន់ប៉ុណ្ណោះទេ តែត្រូវសមាមាត្រជាមួយនឹងកាលៈទេសៈ និងភាពចាស់ទុំរបស់កុមារផងដែរ ។
- បឋមភាពនៃការឆ្លើយតបតាមរយៈការបង្វែរ ដែលមានខ្លឹមសារថា លើកលែងតែផលប្រយោជន៍ជាសាធារណៈដែលតម្រូវឲ្យដំណើរការនីតិវិធីព្រហ្មទណ្ឌ មិនត្រូវអនុវត្តចំពោះកុមារសោះឡើយប្រសិនបើ មានមធ្យោបាយសម្រាប់ប្រើជំនួសក្នុងការដោះស្រាយបញ្ហានោះ ។
- ការចែងអំពីសិទ្ធិកុមារ ដែលមានខ្លឹមសារថា សំដៅលើសិទ្ធិកុមារក្នុងការទទួលបាននូវកិច្ចការពារពិសេសនិងនីតិវិធីទាំងឡាយនៅគ្រប់ដំណាក់កាលនៃដំណើរការយុត្តិធម៌ព្រហ្មទណ្ឌ។
- សិទ្ធិកុមារ ដែលមានខ្លឹមសារថា កុមារមានសិទ្ធិចូលរួមក្នុងដំណើរការនីតិវិធី និងបញ្ចេញ

[5] មាត្រា៣៨ នៃក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា

[6] ចែងក្នុងច្បាប់របស់ប្រទេសអូស្ត្រាលី(NSW) កាណាដា ឡាវ ប៉ាពូ ញូហ្គានៀ ហ្វីលីពីន និងអាហ្រ្វិចខាងត្បូង

មតិរបស់ខ្លួនដោយសេរី និងទទួលបាននូវការគាំទ្រផ្លូវច្បាប់ និងការគាំទ្រផ្សេងៗទៀត (រួមទាំងសមាជិកគ្រួសារ) ដើម្បីជួយពួកគេនៅក្នុងគ្រប់ដំណាក់កាលទាំងអស់នៃដំណើរការនីតិវិធី ។

- លក្ខខណ្ឌ ដែលមានខ្លឹមសារថាចំពោះលក្ខខណ្ឌរាល់បញ្ហាដែលទាក់ទង នឹងយុត្តិធម៌អនីតិជនទាំងអស់ត្រូវដោះស្រាយក្នុងលក្ខណៈមួយ ដែលត្រឹមត្រូវមានយុត្តិធម៌ និងទាន់ពេលវេលា ។
- ការរៀបរាប់អំពីគោលបំណង ដែលមានខ្លឹមសារថា គឺជាការឆ្លើយតបតាមសហគមន៍ដែលជាការចាំបាច់ ហើយកាតព្វកិច្ចក្នុងការអនុវត្តការឃាត់ខ្លួន ការឃុំខ្លួន និងការដាក់ពន្ធនាគារ ត្រូវតែជាវិធានការចុងក្រោយបំផុត និងរយៈពេលខ្លី និងសមស្របបំផុត[7] ។

យោងតាមមាត្រា ៣៧ ចំណុច(ក)នៃអនុសញ្ញាស្តីពីសិទ្ធិកុមារ បានចែងថា គ្មានកុមារណាម្នាក់ត្រូវទទួលទារុណកម្មឬការប្រព្រឹត្តទៅលើខ្លួន ឬការផ្តន្ទាទោសយោរយៅ អមនុស្សធម៌ ឬបន្ទោកបន្ទាបឡើយ ។ ទោសប្រហារជីវិត ឬដាក់គុកអស់មួយជីវិតដោយគ្មានលទ្ធភាពដោះលែងមិនត្រូវដាក់ចំពោះបទល្មើសដែលប្រព្រឹត្តដោយមនុស្ស មានអាយុក្រោម១៨ឆ្នាំឡើយ ។ ហេតុនេះយើងត្រូវយកចិត្តទុកដាក់ និងពិចារណារាល់សកម្មភាពពាក់ព័ន្ធ នឹងឧត្តមប្រយោជន៍របស់អនីតិជន ជាពិសេសគឺជាការធានានូវសិទ្ធិរស់រានមានជីវិត និងការរីកចម្រើនលូតលាស់ជាអតិបរមា និងមិនរើសអើងចំពោះអនីតិជន មានជាអាទ៍ ជាតិសាសន៍ ភេទ ភាសា សាសនា សង្គម ឬពូជអំបូរ កំណើត ស្ថានភាពសេដ្ឋកិច្ច ឬនយោបាយ ។

យោងតាមមាត្រា៥ នៃច្បាប់ស្តីពីយុត្តិធម៌អនីតិជនបានចែងចំពោះគ្រប់បុគ្គលដែលបំពេញតួនាទីណាមួយពាក់ព័ន្ធ នឹងអនីតិជន ត្រូវធានាឲ្យមានការគោរពគោលការណ៍ដូចតទៅ ៖

- ត្រូវយកចិត្តទុកដាក់ និងពិចារណារាល់សកម្មភាពពាក់ព័ន្ធ នឹងឧត្តមប្រយោជន៍របស់អនីតិជន ជាពិសេសធានានូវសិទ្ធិរស់រានមានជីវិត និងការរីកចម្រើនលូតលាស់ជាអតិបរមា ។
- ត្រូវប្រព្រឹត្តប្រកបដោយមនុស្សធម៌ និងសេចក្តីថ្លៃថ្នូរទៅលើអនីតិជន ។
- ត្រូវផ្តល់ឱកាសឲ្យអនីតិជនសម្តែងមតិដោយសេរី ហើយទស្សនៈនោះត្រូវបានយកទៅពិចារណាថ្លឹងថ្លែងស្របទៅតាមអាយុ ការរីកចម្រើនផ្នែករូបកាយ បញ្ញាស្មារតី និងកម្រិតនៃការយល់ដឹងរបស់អនីតិជនចំពោះសកម្មភាពរបស់ខ្លួន ។
- ត្រូវអនុវត្តទៅតាមនីតិវិធីកុមារមេត្រី ។
- ត្រូវអនុវត្តការចាប់ខ្លួន ការឃាត់ខ្លួន ការឃុំខ្លួន និង ការសម្រេចផ្តន្ទាទោសអនីតិជនជាវិធានការចុងក្រោយ និងមានរយៈពេលខ្លីបំផុតដែលអាចធ្វើទៅបាន ។
- មិនត្រូវរើសអើងចំពោះអនីតិជន មានជាអាទ៍ ពូជសាសន៍ ពណ៌សម្បុរ ភេទ ភាសា ជំនឿ

[7] មាត្រា៣៧ ចំណុច(ខ) នៃអនុសញ្ញាស្តីពីសិទ្ធិកុមារ និងពិធីសារបន្ថែម

សាសនា ឋានៈសង្គម ធនធាន ដើមកំណើតជាតិ និន្នាការនយោបាយ ឬស្ថានភាពឯទៀត ។

- មិនត្រូវប្រើខ្នោះ និងឧបករណ៍ផ្សេងៗទៀត ដែលប៉ះពាល់ដល់បូរណភាពរូបរាងកាយរបស់អនីតិជន លើកលែងតែក្នុងករណីចាំបាច់បំផុតប៉ុណ្ណោះ ដែលវិធានការទាំងឡាយមិនអាចអនុវត្តបានឬគ្មានប្រសិទ្ធភាព
- មិនត្រូវប្រើទារុណកម្ម ទណ្ឌកម្ម ឬប្រព្រឹត្តកម្មផ្សេងទៀតដែលយោរយៅ អមនុស្សធម៌ ឬបន្ទាបបន្ថោកតាមគ្រប់រូបភាពទៅលើរូបកាយ និងផ្លូវចិត្តរបស់អនីតិជន ។
- មិនត្រូវបញ្ចេញ ឬផ្សព្វផ្សាយរូបភាព និងព័ត៌មានទាំងឡាយដែលពាក់ព័ន្ធ នឹងសកម្មភាពរបស់អនីតិជន និងដែលនាំបង្ហាញអំពីអត្តសញ្ញាណរបស់អនីតិជន ហើយដែលអាចមានឥទ្ធិពលលើសម្បទាកុមារក្នុងការទទួលបាននូវការអប់រំ ការងារ ការស្នាក់នៅ ឬសុវត្ថិភាព ។ ការផ្សព្វផ្សាយរឿងក្តីអាចធ្វើទៅបាន លុះត្រាតែមានការអនុញ្ញាតពីព្រះរាជអាជ្ញា ដើម្បីផលប្រយោជន៍សាធារណៈប៉ុណ្ណោះ ប៉ុន្តែមិនត្រូវបង្ហាញអំពីអត្តសញ្ញាណរបស់អនីតិជនឡើយ ។
- សន្ទតថាគ្មានទោស ដរាបណាតុលាការមិនទាន់កាត់ទោសជាស្ថាពរ ។

សម្រាប់ការឆ្លើយតបមកវិញ របស់អាជ្ញាធរនានាដែលមានសមត្ថកិច្ចចំពោះអនីតិជន ជានិច្ចជាកាលត្រូវសមាមាត្រ មិនត្រឹមតែទៅនឹងទម្ងន់នៃបទល្មើសទេ តែអាស្រ័យទៅលើកាលៈទេសៈផ្ទាល់របស់ អនីតិជនដូចជា អាយុ និងសេចក្តីត្រូវការរបស់អនីតិជននោះផងដែរហើយការចាប់ខ្លួន ការឃុំខ្លួន និងដាក់ពន្ធនាគារអនីតិជន អាចអនុវត្តន៍បានសម្រាប់តែវិធានការចុងក្រោយប៉ុណ្ណោះ ។

ចំពោះការប្រើប្រាស់កម្មវិធីសហគមន៍ និងកម្មវិធីសមស្របផ្សេងៗសម្រាប់ការបង្វែអនីតិជនចេញពីនីតិវិធីតុលាការត្រូវបានពិចារណាក្នុងរាល់ករណីសមស្រប ហើយក្នុងករណីនៃការបង្វែរមិនមានលក្ខណៈសមស្របទេនោះ ការឃុំខ្លួនអនីតីជនត្រូវប្រព្រឹត្តទៅបន្តសម្រាប់តែរយៈពេលចាំបាច់ដែលខ្លីបំផុត[8] ហើយត្រូវបំបែកអនីតិជន ដោយធ្វើការឃុំខ្លួនដោយឡែកពីមនុស្សពេញវ័យ។ ការបង្គាប់ឲ្យដាក់អនីតិជនក្នុងស្ថាប័ន ឬមណ្ឌលធ្វើឡើងតែក្នុងករណីពុំមានមធ្យោបាយជំនួសសមស្របប៉ុណ្ណោះ ។ ក្នុងករណីបែបនេះត្រូវផ្តល់ការថែទាំការពារនិងជំនួយឧបត្ថម្ភផ្នែកអប់រំ ផ្នែកចិត្តសាស្ត្រ និងផ្នែកពេទ្យតាមការចាំបាច់ដើម្បីសម្រួលដល់ការស្តារនីតិសម្បទា និងការធ្វើសមាហរណកម្មសង្គមរបស់អនីតិជន[9] ។ ចំណែកឯការប្រកាសដកសិទ្ធិសេរីភាពរបស់អនីតិជន ត្រូវធ្វើសម្រាប់តែក្នុងករណីចាំបាច់បំផុតដូចជា ករណីប្រព្រឹត្តបទល្មើសធ្ងន់ធ្ងរ ដែលពាក់ព័ន្ធនឹងអំពើហិង្សាប្រឆាំង

[8] មាត្រា៤ ចំណុច៩ នៃសេចក្តីព្រាងច្បាប់ស្តីពីយុត្តិធម៌អនីតិជនអនុម័តនាខែកញ្ញា ឆ្នាំ២០០៧

[9] មាត្រា៤ ចំណុច១០ នៃសេចក្តីព្រាងច្បាប់ស្តីពីយុត្តិធម៌អនីតិជន អនុម័តនាខែកញ្ញា ឆ្នាំ២០០៧

នឹងបុគ្គល ឬការប្រព្រឹត្តបទល្មើសធ្ងន់ធ្ងរផ្សេងៗទៀតដោយមិនរាងចាល និងធ្វើឡើងតែក្នុងករណីពុំមានការសម្រេចសមស្របផ្សេងទៀត ។

ដូចនេះចំពោះការដាក់ពន្ធនាគារអស់មួយជីវិតការដាក់ទណ្ឌកម្មលើរូបរាងកាយ និងទង្វើ ឬការដាក់ទណ្ឌកម្មយោរយៅ ឬបន្ទាបបន្ទោកដល់អនីតិជនត្រូវបានហាមឃាត់ ។

២.២. សិទ្ធិជាមូលដ្ឋាន

រាល់ដំណើរការនៃនីតិវិធីទាំងមូលត្រូវប្រព្រឹត្តទៅប្រកបដោយយុត្តិធម៌ និងដោយអនុញ្ញាតឲ្យមានការចូលរួមយ៉ាងពេញលេញ និងមានការសម្តែងមតិដោយសេរីពីសំណាក់អនីតិជន និងឪពុកម្តាយ ឬអ្នកអាណាព្យាបាលសម្រាប់អនីតិជន ។

អនីតិជនគ្រប់រូបដែលជាប់សង្ស័យ ឬត្រូវចោទ ឬជាប់ចោទថាប្រព្រឹត្តបទល្មើសត្រូវទទួលបាននូវសិទ្ធិជាមូលដ្ឋានក្នុងនីតិវិធីដូចតទៅ ៖

- សិទ្ធិមិនផ្តល់ចម្លើយនៅពេលដែលមាន ឬគ្មានវត្តមានមេធាវី
- សិទ្ធិមិនទទួលការបង្ខិតបង្ខំឲ្យឆ្លើយដាក់បន្ទុកលើខ្លួនឯង
- សិទ្ធិរក្សាការសម្ងាត់នៃជីវិតឯកជន
- សិទ្ធិទទួលបានការពិនិត្យសុខភាព និងការព្យាបាល
- សិទ្ធិទទួលបានដំណឹងអំពីបទចោទប្រកាន់
- សិទ្ធិក្នុងការជូនដំណឹងអំពីការចាប់ខ្លួនទៅដល់អ្នកតំណាងដែលច្បាប់បានកំណត់
- សិទ្ធិទទួលបានជំនួយពីមេធាវីដោយការជ្រើសរើស ឬដោយការចាប់តាំងដោយមិនយកកម្រៃ ស្របតាមលក្ខខណ្ឌដែលចែងដោយច្បាប់ស្តីពីលក្ខន្តិក:មេធាវី ចាប់តាំងពីដំណាក់កាលដំបូងបំផុតនៃនីតិវិធី
- សិទ្ធិឲ្យមានការចូលរួមពីអ្នកតំណាងដែលច្បាប់បានកំណត់ នៅគ្រប់ដំណើរការរឿងក្តី ប្រសិនបើការចូលរួមនេះមិនផ្ទុយនឹងឧត្តមប្រយោជន៍របស់អនីតិជន
- សិទ្ធិទទួលបានជំនួយពីអ្នកបកប្រែភាសាដោយមិនយកកម្រៃ កាលបើមានការចាំបាច់
- សិទ្ធិបង្ហាញភ័ស្តុតាង
- សិទ្ធិស្នើសុំឲ្យកោះហៅសាក្សី និងសួរសាក្សី
- សិទ្ធិស្នើសុំអនុញ្ញាតនៅក្រៅឃុំ[10]
- សិទ្ធិស្នើសុំឲ្យកែប្រែវិធានត្រួតពិនិត្យតាមផ្លូវតុលាការ
- សិទ្ធិទំនាក់ទំនងជាស្ថានទូត ស្ថានកុងស៊ុល ក្នុងករណីអនីតិជនជាជនបរទេស

[10] មាត្រា៦ វាក្យខណ្ឌ១៣ នៃច្បាប់ស្តីពីយុត្តិធម៌អនីតិជន ឆ្នាំ២០១៦

- សិទ្ធិផ្សេងៗទៀតដែលមានចែងនៅក្នុងបទដ្ឋានគតិយុត្តិជាធរមាន ។

គ្រប់ដំណើរការនៃនីតិវិធីទាំងមូល ដែលមានខាងលើនេះត្រូវគោរពនូវសិទ្ធិជីវភាពឯកជនរបស់អនីតិជនហើយត្រូវរក្សាទុកកំណត់ហេតុនានានៃរឿងក្តីជាការសម្ងាត់ ដើម្បីនឹងជៀសវាងនូវព្យសនកម្ម បណ្តាលមកពីការផ្សព្វផ្សាយជាសាធារណៈ ឬដោយសារការជេរប្រមាថ ។ ហេតុនេះហើយការផ្សព្វផ្សាយព័ត៌មាន ដែលទាក់ទងនឹងដំណើរការរឿងក្តីអនីតិជន មិនត្រូវបានឲ្យមានការអនុញ្ញាតនោះទេ លុះត្រាតែមានការអនុញ្ញាតជាមុនពីចៅក្រម ដែលត្រូវបានចាត់តាំងឲ្យកាន់រឿងក្តី។ ការអនុញ្ញាតរបស់អាជ្ញាធរ អាចធ្វើទៅបានលុះត្រាតែក្នុងគោលបំណងអប់រំស្រាវជ្រាវ ឬសិក្សានៅក្នុងបណ្ឌិតសភា ឬផលប្រយោជន៍សាធារណៈ:ប្រសិនបើចាំបាច់ ប៉ុន្តែក្នុងករណីដែលមានការអនុញ្ញាតមិនត្រូវឲ្យ មានពត៌មានណាមួយដែលបណ្តាលឲ្យបញ្ចេញ ឬផ្សព្វផ្សាយចេញនូវអត្តសញ្ញាណរបស់អនីតិជននោះឡើយ ។

ផ្នែកទី៣ : ការទទួលខុសត្រូវព្រហ្មទណ្ឌ និងរដ្ឋប្បវេណីរបស់អនីតិជន

៣.១. ការទទួលខុសត្រូវព្រហ្មទណ្ឌ

ការទទួលស្គាល់ថាកុមារដែលមានការសង្ស័យជាប់ចោទ ដែលគេស្គាល់ថាបានប្រព្រឹត្តបទល្មើសទំនាស់នឹងច្បាប់ព្រហ្មទណ្ឌ គឺត្រូវបានចាត់រាល់វិធានការសមស្របដើម្បីជម្រុញការស្តារកាយសម្បទា និងចិត្តសាស្ត្រឲ្យមានដូចដើមវិញ និងសមាហរណកម្មសង្គមដែលទាក់ទងទៅនឹងកុមាររងគ្រោះពីទម្រង់ណាមួយនៃការទុកចោលមិនយកចិត្តទុកដាក់ការកេងប្រវ័ញ្ច ឬការរំលោភបំពាន ការធ្វើទារុណកម្ម ឬទម្រង់ណាមួយនៃការប្រព្រឹត្តទៅខ្លួនកុមារ ឬការផ្តន្ទាទោសយោរយៅអមនុស្សធម៌ ឬបន្ទាបបន្ថោក ឬដោយសារជម្លោះប្រដាប់អាវុធជាដើម[11] ។ ការស្តារកាយសម្បទានិងសមាហរណកម្មទាំងនេះ ត្រូវបានប្រព្រឹត្តក្នុងបរិយាកាសមួយដែលលើកស្ទួយសុខភាព ការគោរពតម្លៃខ្លួនឯង និងសេចក្តីថ្លៃថ្នូររបស់កុមារ ។

ព្រហ្មទណ្ឌ គឺជានីតិវិធីទាំងឡាយណា ដែលចែងមកសម្រាប់ដាក់ទោសរាល់បុគ្គលទាំងឡាយណាដែលបានប្រព្រឹត្តផ្ទុយពីនីតិវិធីព្រហ្មទណ្ឌ ។ ដូច្នេះហើយនៅពេលមានបទល្មើសមួយកើតឡើងត្រូវតែមានការទទួលខុសត្រូវព្រហ្មទណ្ឌ ។ បុគ្គលម្នាក់ៗទទួលខុសត្រូវព្រហ្មទណ្ឌតែចំពោះអំពើផ្ទាល់របស់ខ្លួនប៉ុណ្ណោះ។ នេះគឺជាគោលការណ៍ឯកត្តកម្មនៃការទទួលខុសត្រូវព្រហ្មទណ្ឌ ដែលបានបញ្ជាក្តិនៅមាត្រា ២៤ នៃក្រមព្រហ្មទណ្ឌ មានន័យថាគឺជាគោលការណ៍មួយដែលបញ្ជាក់ពីការទទួលខុសត្រូវព្រហ្មទណ្ឌ សម្រាប់តែបុគ្គលណាម្នាក់ ដែលបានប្រព្រឹត្តល្មើសច្បាប់

[11] សៀវភៅសារណា នីតិវិធីសម្រាប់យុត្តិធម៌អនីតិជនទំនាស់នឹងច្បាប់ រៀបរៀងដោយ (ឈឹន មុន្នី និងហ្ងត ថារ៉ារិត) ឆ្នាំ ២០១២(ទំព័រ១១)

ព្រហ្មទណ្ឌ ត្រូវទទួលខុសត្រូវព្រហ្មទណ្ឌដោយខ្លួនឯងផ្ទាល់ មិនអាចមាននរណាម្នាក់អាចទទួលខុសត្រូវព្រហ្មទណ្ឌជំនួសបានទេ ឬមានសាច់ញ្ញាតិ ឪពុកម្តាយ ព្រមស្ម័គ្រចិត្តធ្វើការទទួលខុសព្រហ្មទណ្ឌជំនួសចារីដែលបានប្រព្រឹត្តបទល្មើសនោះបានទេ ។

ដូចនេះហើយគោលការណ៍ឯកត្តកម្មនៃការទទួលខុសត្រូវព្រហ្មទណ្ឌ គឺជាគោលការណ៍មួយ ដែលចង្អុលបង្ហាញលើបុគ្គលដែលប្រព្រឹត្តល្មើសនោះ ត្រូវតែទទួលខុសត្រូវព្រហ្មទណ្ឌ ហើយគោលការណ៍នេះ ជាគោលការណ៍ផ្តោតសំខាន់លើតែបុគ្គលល្មើស ដើម្បីមកទទួលខុសត្រូវតែប៉ុណ្ណោះ ។ ដោយហេតុនេះហើយរដ្ឋ មានវិធានការណ៍ចំពោះអនីតិជនដែលបានប្រព្រឹត្តល្មើសដែលជាកម្មវត្ថុនៃវិធានការតាមដាន វិធានការអប់រំ វិធានការការពារ និងវិធានការឧត្តម ប៉ុន្តែតុលាការអាចប្រកាសទោសព្រហ្មទណ្ឌទៅលើអនីតិជន បានលុះត្រាតែជននោះមានអាយុចាប់ពី ១៤(ដប់បួន)ឆ្នាំឡើងទៅ ប្រសិនបើកាល:ទេស:នៃបទល្មើស ឬបុគ្គលិកលក្ខណៈ:របស់អនីតិជនតម្រូវអាចដាក់ទោសព្រហ្មទណ្ឌបានទៀតផង បើមិនដូចនេះទេតុលាការមិនអាចប្រកាសទោសលើអនីតិជននោះបានទេ ។

៣.១.១. នីតិភាពនៃការទទួលខុសត្រូវព្រហ្មទណ្ឌ

នៅក្នុងប្រទេសនីមួយៗ ការអនុវត្តនីតិព្រហ្មទណ្ឌមានលក្ខណៈ:ខុសគ្នាខ្លាំងពីអាយុរបស់អនីតិជនដែលប្រព្រឹត្តបទល្មើស ដើម្បីឲ្យអនីតិជននោះទទួលខុសត្រូវព្រហ្មទណ្ឌ ។ នៅក្នុងការកំណត់នីតិភាពនៃការទទួលខុសត្រូវព្រហ្មទណ្ឌវាមានសារ:សំខាន់ខ្លាំងណាស់ ក្នុងការធានាថាច្បាប់បានចែងយ៉ាងច្បាស់ពីរបៀបដែលនឹងត្រូវប្រព្រឹត្តចំពោះ កុមារដែលបានប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌ ដែលមានអាយុតិចជាងអាយុអប្បបរមានៃការទទួលខុសត្រូវព្រហ្មទណ្ឌនោះ ។

ដោយអនុលោមតាមមាត្រា ៣៨ នៃក្រមព្រហ្មទណ្ឌ ឆ្នាំ២០១០ បានចែងថា នីតិភាពនៃការទទួលខុសត្រូវព្រហ្មទណ្ឌ ត្រូវបានកំណត់អាយុចាប់ពី ១៨(ដប់ប្រាំបី)ឆ្នាំឡើងទៅ ។ ជនណាឈានចូលអាយុនីតិភាពព្រហ្មទណ្ឌ ត្រូវទទួលខុសត្រូវខាងផ្នែកព្រហ្មទណ្ឌ ប្រសិនបើមានការប្រព្រឹត្តល្មើសច្បាប់ព្រហ្មទណ្ឌ ឬបានធ្វើទង្វើណាមួយឲ្យប៉ះពាល់ដល់ប្រយោជន៍អ្នកដទៃ និងប៉ះពាល់ដល់ជីវភាពបុគ្គលដែលនាំឲ្យ មានការកើតឡើងនូវបទល្មើសផ្ទុយនឹងច្បាប់ព្រហ្មទណ្ឌ ជននោះត្រូវតែទទួលទោសព្រហ្មទណ្ឌតាមទិដ្ឋភាពជាក់ស្តែងនៃអំពើល្មើស ។ ដោយឡែកអនីតិជនចាប់ពីអាយុ ១៤ (ដប់បួន)ឆ្នាំ ដល់ក្រោមអាយុ ១៨ (ដប់ប្រាំបី)ឆ្នាំ ត្រូវបានសន្មតថា មិនមានសមត្ថភាពទទួលខុសត្រូវព្រហ្មទណ្ឌពេញលេញនោះទេ និងត្រូវដោះស្រាយតាមរយ:វិធានការណ៍អប់រំ វិធានការណ៍តាមដាន វិធានការណ៍ស្តារនីតិសម្បទា វិធានការណ៍ការពារ និងវិធានការណ៍ឧបត្ថម្ភ ។ ប៉ុន្តែអនីតិជនអាចទទួលខុសត្រូវព្រហ្មទណ្ឌ ចំពោះបទល្មើសព្រហ្មទណ្ឌណាមួយបានត្រូវមានការបញ្ជាក់ទៅ

លើភ័ស្តុតាងបង្ហាញថាអនីតិជននោះមានសមត្ថភាពដឹងខុសត្រូវពេញលេញ ហើយកាល:ទេស:នៃបទល្មើស ឬបុគ្គលិកលក្ខណៈរបស់អនីតិជនបង្ហាញហេតុផលបែបនោះ[12] ។

៣.១.២. ការកំណត់អាយុនៃការទទួលខុសត្រូវព្រហ្មទណ្ឌ

គោលបំណងកំណត់អាយុនៃការទទួលខុសត្រូវខាងផ្នែកព្រហ្មទណ្ឌរបស់បុគ្គល ដែលមានអាយុរបស់ខ្លួនត្រូវជាប់សង្ស័យនោះ គឺជាអាយុនៅពេលដែលជននោះប្រព្រឹត្តបទល្មើសដែលត្រូវបានចោទ ។ ដោយយើងយោងតាមភស្តុតាងនៃការកំណត់អាយុរបស់បុគ្គលនោះដែលត្រូវផ្តោតទៅលើសំបុត្រកំណើត ឬសំបុត្របញ្ជាក់កំណើត ។[13] តែផ្ទុយទៅវិញប្រសិនបើក្នុងករណីពុំមានឯកសារដែលបានបញ្ជាក់ដូចខាងលើនោះទេ ឬមានបញ្ហាទាក់ទង នឹងលិខិតយថាភូតនៃឯកសារនោះដែលជាភស្តុតាងនៃអាយុរបស់បុគ្គលរូបនោះហើយត្រូវធ្វើយ៉ាងណា ដោយប្រើប្រាស់គ្រប់ការស្រាវជ្រាវដោយតាម រយៈមធ្យោបាយដែលអាចទុកចិត្តបានផ្សេងៗទៀតដូចជា វេជ្ជកោសល្យវិច្ច័យ លើកំណត់ត្រាសុខភាព កំណត់ត្រាផ្នែកពេទ្យ កំណត់ត្រាផ្នែកទន្តសាស្ត្រ កំណត់ត្រានៅសាលារៀន ឬការស្បថក្នុងការផ្តល់សក្ខីកម្មដោយជនជាសាច់ញាតិ ជាពិសេស ពីសំណាក់មន្ត្រីឃុំ សង្កាត់ សមាជិកសហគមន៍ ។ ប៉ុន្តែដោយយោងតាមច្បាប់ស្តីពីយុត្តិធម៌អនីតិជន បានកំណត់ថាក្នុងករណីមានការសង្ស័យអំពីអាយុ របស់អនីតិជន វិមតិសង្ស័យត្រូវបានជាប្រយោជន៍ដល់អនីតិជន ។ ហេតុដូចនេះហើយទើបបានជាមានចែងយ៉ាងច្បាស់ដើម្បីឧត្តមប្រយោជន៍ដល់អនីតិជនថាក្នុងករណីមានការសង្ស័យអំពីអាយុរបស់អនីតិជនត្រូវចោទនោះ វិមតិសង្ស័យនោះត្រូវបានជាប្រយោជន៍ដល់អនីតិជននោះជាដាច់ខាត[14] ។

៣.២. មូលហេតុនៃការមិនទទួលខុសត្រូវ ឬការសម្រាលការទទួលខុសត្រូវព្រហ្មទណ្ឌ

មូលហេតុនៃការមិនទទួលខុសត្រូវ ឬការសម្រាលការទទួលខុសត្រូវព្រហ្មទណ្ឌរបស់អនីតិជន ត្រូវអនុលោមតាមមាត្រា៣១ ដល់ មាត្រា៣៧ នៃក្រមព្រហ្មទណ្ឌរួមទាំងការបង្ខំដោយឪពុកម្តាយ ឬអាណាព្យាបាល ឬជនណាមួយ ។ ហេតុដូចនេះហើយដែលនាំឲ្យមានកត្តាជាច្រើនដែលជាកត្តាដែលបណ្តាល ឲ្យមានមូលហេតុនៃការមិនទទួលខុសត្រូវ ឬ ការសម្រាលការទទួលខុសត្រូវព្រហ្មទណ្ឌ ។

ដោយយោងតាមក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា បានបញ្ញត្តិពីការមិនទទួលខុសត្រូវព្រហ្មទណ្ឌដោយសារមូលហេតុ ៖

---

[12] សៀវភៅសារណា នីតិវិធីសម្រាប់យុត្តិធម៌អនីតិជនទំនាស់នឹងច្បាប់ រៀបរៀងដោយ (ឈឹន មុន្នី និងហ្ងត ថាវរិត) ឆ្នាំ២០១២(ទំព័រ១៤)

[13] មាត្រា៩ វាក្យខណ្ឌ២ នៃច្បាប់ស្តីពីយុត្តិធម៌អនីតិ ឆ្នាំ២០១៦

[14] មាត្រា៣៨ វាក្យខណ្ឌ៦ នៃរដ្ឋធម្មនុញ្ញរបស់ព្រះរាជាណាចក្រកម្ពុជា

• កាលបើជនណាម្នាក់ប្រព្រឹត្តបទល្មើស នៅពេលដែលជននោះកើតវិបល្លាសស្មារតី ដែលធ្វើឱ្យបាត់បង់ នូវការដឹងខុសត្រូវរបស់ខ្លួន ជននោះមិនទទួលខុសត្រូវព្រហ្មទណ្ឌទេ ។ កាលបើជនណាម្នាក់ប្រព្រឹត្តបទល្មើស នៅពេលដែលជននោះកើតវិបល្លាសស្មារតី ដែលបន្ថយនូវការ ដឹងខុសត្រូវរបស់ខ្លួន ជននោះនៅតែទទួលខុសត្រូវព្រហ្មទណ្ឌដដែល ។ ប៉ុន្តែតុលាការត្រូវគិតគូរអំពីបញ្ហានេះនៅពេលតុលាការធ្វើការអំពីកំណត់ទោស ។ កាលបើជនណាម្នាក់ប្រព្រឹត្តបទល្មើស នៅពេលដែលជននោះកើតវិបល្លាសស្មារតី ដោយសារការប្រើប្រាស់គ្រឿងស្រវឹង គ្រឿងញៀន ឬសារជាតិដែលច្បាប់ហាមឃាត់ មិនអាចរួចផុតពីការទទួលខុសត្រូវព្រហ្មទណ្ឌឡើយ ។

• មួយវិញទៀត ការអនុញ្ញាតដោយច្បាប់ ឬអាជ្ញាធរ កាលណាមានបុគ្គលណាដែលប្រព្រឹត្តអំពើដែលបានបញ្ញត្តិ ឬអនុញ្ញាតតាមច្បាប់ បុគ្គលនោះមិនប្រព្រឹត្តបទល្មើសទេ ។ បុគ្គលណាដែលប្រព្រឹត្តអំពើតាមបញ្ជារបស់អាជ្ញាធរស្របច្បាប់ បុគ្គលនោះមិនប្រព្រឹត្តបទល្មើសទេ លើកលែងតែអំពើនេះជាអំពើខុសច្បាប់យ៉ាងជាក់ច្បាស់ ។ ប៉ុន្តែចារី សហចារី អ្នកផ្តើមគំនិត ឬអ្នកសមគំនិតបានប្រព្រឹត្តបទល្មើសក្នុងបទប្រល័យពូជសាសន៍ បទឧក្រិដ្ឋប្រឆាំងនឹងមនុស្សជាតិ ឬបទឧក្រិដ្ឋសង្គ្រាម មិនអាចលើកលែងឱ្យផុតពីការទទួលខុសត្រូវព្រហ្មទណ្ឌរបស់ខ្លួនទេ ទោះបីជាក្នុងករណីមានមូលហេតុដូចខាងក្រោមក៏ដោយ : (ករណីទី១) ជនល្មើសនោះបានប្រព្រឹត្តអំពើដែលបញ្ញត្តិអនុញ្ញាត ឬមិនហាមឃាត់ ដោយច្បាប់ជាធរមាន ។ (ករណីទី២)បុគ្គលនោះបានប្រព្រឹត្តតាមបញ្ជារបស់អាជ្ញាធរស្របច្បាប់ ។

• ចំណែកឯការការពារស្របច្បាប់ ក៏ជាផ្នែកមួយដែលនាំឲ្យមិនទទួលខុសត្រូវព្រហ្មទណ្ឌ ឬត្រូវបានការសម្រាលនូវការទទួលខុសត្រូវព្រហ្មទណ្ឌដែល បើបុគ្គលណាដែលប្រព្រឹត្តបទល្មើសក្នុងសភាការការពារស្របច្បាប់ ហើយការការពារខ្លួនស្របច្បាប់ត្រូវមានលក្ខណៈដូចជា : បទល្មើសត្រូវចាត់ទុកថាត្រឹមត្រូវដោយការចាំបាច់ដើម្បីការពារខ្លួន ការពារអ្នកដទៃ ឬការពារទ្រព្យសម្បត្តិប្រឈមមុខនឹងការឈ្លានពានមួយដែលមិនត្រឹមត្រូវ ឬការប្រព្រឹត្តបទល្មើសនិងការឈ្លានពានត្រូវតែកើតឡើងក្នុងពេលជាមួយគ្នា និងគ្មានវិសមាមាត្ររវាងមធ្យោបាយការពារដែលប្រើប្រាស់ និងទម្ងន់នៃការឈ្លានពាន ។

• ក៏ដូចគ្នាផងដែលយើងឃើញថាសច្ចធារណ៍នៃការការពារស្របច្បាប់ ក៏ជាមូលហេតុដែលនាំឲ្យមិនទទួលខុសត្រូវព្រហ្មទណ្ឌ ឬការសម្រាលនូវការទទួលខុសត្រូវព្រហ្មទណ្ឌផងដែរ ដូចនេះយើងត្រូវសន្មតថាជាការការពារស្របច្បាប់នៅក្នុងករណីដូចតទៅ : (ករណីទី១) បទល្មើសត្រូវបានប្រព្រឹត្ត ដើម្បីរុញច្រានការចូលក្នុងពេលយប់ ដោយការកាប់គាស់ទម្លុះទម្លាយ ដោយហិង្សា ឬដោយកលល្បិចនៅក្នុងទីកន្លែងដែលមានមនុស្សនៅ ។ (ករណីទី២) បទល្មើសបានប្រព្រឹត្ត ដើម្បី

ការពារខ្លួនប្រឆាំងនឹងការលួច ឬការប្លន់ដែលអនុវត្តដោយហិង្សា ។ តែផ្ទុយទៅវិញសច្ចធារណ៍នៃការការពារស្របច្បាប់ពុំមានលក្ខណៈដាច់ខាតទេ ។ សច្ចធារណ៍នេះត្រូវរំលាយដោយសារភស្តុតាងផ្ទុយ ។

- ម្យ៉ាងវិញទៀត ស្ថានភាពចាំបាច់ក៏ជាមូលហេតុមិនអាចទទួលខុសត្រូវព្រហ្មទណ្ឌ ឬត្រូវសម្រាលទោសព្រហ្មទណ្ឌ ដោយសារតែបុគ្គលដែលស្ថិតនៅក្នុងស្ថានភាពចាំបាច់ត្រូវតែប្រព្រឹត្តបទល្មើសមានលក្ខខណ្ឌដូចជា : (ករណីទី១) បទល្មើសបានចាត់ទុកថា ត្រឹមត្រូវដោយការចាំបាច់ដើម្បីការពារខ្លួន ការពារអ្នកដទៃ ឬការពារទ្រព្យសម្បត្តិប្រឆាំង នឹងគ្រោះថ្នាក់ដែលកំពុងកើតមាន ឬដែលនឹងកើតមាន ។ (ករណីទី២) គ្មានវិសមាមាត្ររវាងមធ្យោបាយការពារ និងទម្ងន់នៃគ្រោះថ្នាក់ ។

- យើងឃើញថាអានុភាពនៃកម្លាំង ឬការបង្ខំជាមូលហេតុមួយដែលនាំឲ្យបុគ្គលដែលប្រព្រឹត្តបទល្មើសក្រោមអានុភាពនៃកម្លាំង ឬការបង្ខំដែលបុគ្គលនេះ មិនអាចទប់ទល់បានបុគ្គលនេះមិនទទួលខុសត្រូវព្រហ្មទណ្ឌទេ។ កម្លាំងនិងការបង្ខំអាចចេញមកពីព្រឹត្តិការណ៍ក្រៅឆន្ទៈរបស់មនុស្ស តែប៉ុណ្ណោះ។ កម្លាំងនិងការបង្ខំនេះត្រូវតែមិនអាចមើលឃើញជាមុនបាននិងមិនអាចជៀសវាងបាន

- អភ័យឯកសិទ្ធិគ្រួសារ សំដៅទៅលើភាពមិនអាចផ្តន្ទាទោសព្រហ្មទណ្ឌបាន ចំពោះជនដែលបានប្រព្រឹត្តបទល្មើសលួច (អំពើលួចទ្រព្យសម្បត្តិ) បើជននោះលួចទ្រព្យសម្បត្តិរបស់បុព្វញ្ញាតិ ឬបច្ឆាញ្ញាតិរបស់ខ្លួន[15] ។

ការមិនទទួលខុសត្រូវព្រហ្មទណ្ឌ គឺជាការបញ្ជាក់ថាបុគ្គលដែលមិនអាចទទួលខុសត្រូវព្រហ្មទណ្ឌ មិនត្រូវទទួលទណ្ឌកម្មព្រហ្មទណ្ឌណាមួយទេ ។

៣.៣. ការទទួលខុសត្រូវផ្នែករដ្ឋប្បវេណី

ជាគោលការណ៍ក្រមរដ្ឋប្បវេណីបានផ្តល់ នូវការការពារដល់ជនដែលមានសមត្ថភាពទាបហើយដែលមិនអាចវិនិច្ឆ័យ និងធ្វើសកម្មភាពតាមលក្ខណៈសមហេតុផលបាន ។ ទាក់ទងនឹងការទទួលខុសត្រូវខាងអំពើអនីត្យានុកូល អនីតិជនដែលមានអាយុក្រោម១៤(ដប់បួន)ឆ្នាំ ឬជនដែលមានវិបត្តិផ្នែកបញ្ញាស្មារតី ត្រូវរួចផុតពីការទទួលខុសត្រូវចំពោះអំពើអនីត្យានុកូល[16] ។ ផ្ទុយទៅវិញច្បាប់តម្រូវឲ្យមានការទទួលខុសត្រូវជាពិសេសមួយ ពីអ្នកគ្រប់គ្រងដែលជាការសង្គ្រោះមួយដល់ជនរងគ្រោះ ។

ក្នុងករណីដែលជនណាម្នាក់ បានប្រព្រឹត្តអំពើអនីត្យានុកូល ប៉ុន្តែជននោះស្ថិតក្នុងស្ថាន

[15] មាត្រា ៣៥៥ ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ២០០៩
[16] មាត្រា ៧៤៥ កថាខណ្ឌទី១ នៃក្រមរដ្ឋប្បវេណី

ភាព អសមត្ថភាពនោះអ្នកដែលមានករណីកិច្ចត្រួតពិនិត្យ ត្រូវទទួលខុសត្រូវសងការខូចខាតលើអំពើបំពានរបស់អសមត្ថជនទាំងនោះ ។ ក្រមរដ្ឋប្បវេណី បានចែងអំពីការទទួលខុសត្រូវរបស់អ្នកមានករណីកិច្ចត្រួតពិនិត្យជាពីរ ដូចខាងក្រោម[17] ៖

- ករណីទី១ : បុគ្គលដែលមានករណីយកិច្ចដែលបានកំណត់ដោយច្បាប់ ក្នុងការត្រួតពិនិត្យ អនីតិជនអាយុក្រោម១៨ឆ្នាំ ឬបុគ្គលដែលស្ថិតនៅក្នុងស្ថានភាពដែលមិនអាចយល់ដឹង និងវិនិច្ឆ័យបានអំពីការទទួលខុសត្រូវចំពោះអំពើរបស់ខ្លួន ដោយសារមានវិបត្តិផ្នែកបញ្ញាស្មារតី ឬមូលហេតុផ្សេងទៀត មានករណីយកិច្ចត្រូវសងការខូចខាតរបស់អ្នកដទៃ ដែលកើតឡើងដោយអំពើបំពានរបស់បុគ្គលដែលនៅក្រោមការត្រួតពិនិត្យរបស់ខ្លួននោះ ។
- ករណីទី២ : បុគ្គលដែលមានករណីកិច្ច ដែលបានកំណត់ដោយច្បាប់ក្នុងការត្រួតពិនិត្យ អនីតិជន អាយុចាប់ពី ១៤ឆ្នាំឡើងទៅ ត្រូវទទួលខុសត្រូវដោយសាមគ្គីភាពជាមួយអនីតិជន ចំពោះការខូចខាតរបស់អ្នកដទៃដែលកើតឡើងដោយអំពើអនីត្យានុកូលរបស់អនីតិជននោះ ។

ប៉ុន្តែបុគ្គលដែលមានករណីយកិច្ចត្រួតពិនិត្យ ដែលទទួលខុសត្រូវក្នុងការសងការខូចខាតតាមករណីទី២ ខាងលើនេះ អាចរួចខ្លួនពីការទទួលខុសត្រូវក្នុងការសងការខូចខាតបាន ដោយបញ្ជាក់បង្ហាញថាខ្លួនបានបំពេញករណីយកិច្ចត្រួតពិនិត្យជាប្រក្រតី ឬដោយត្រឹមត្រូវហើយ ។

ផ្នែកទី៤ : សមត្ថកិច្ចមន្ត្រីនគរបាលយុត្តិធម៌ និងការស៊ើបអង្កេត

មន្ត្រីនគរបាលយុត្តិធម៌មានអំណាចក្នុងករណីអនីតិជនដែលមានអាយុចាប់ពី ១៤ឆ្នាំ ដល់ក្រោម ១៨ឆ្នាំ បានប្រព្រឹត្តបទលហុ នោះមន្ត្រីនគរបាលយុត្តិធម៌ត្រូវធ្វើការអប់រំណែនាំព្រមានដោយផ្ទាល់មាត់ ឬជាលាយលក្ខណ៍អក្សរ រួចហើយប្រគល់អនីតិជននោះទៅឲ្យអ្នកតំណាងដែលច្បាប់បានកំណត់ជាបន្ទាន់ ។ ក្នុងករណីអនីតិជនបានសារភាពថាបានប្រព្រឹត្តបទល្មើស ហើយបទល្មើសនោះជាបទលហុនគរបាលយុត្តិធម៌អាចធ្វើការសម្រុះសម្រួលរវាងភាគីពាក់ព័ន្ធដើម្បីបញ្ចប់វិវាទ ។ បន្ទាប់មក មន្ត្រីនគរបាលយុត្តិធម៌ត្រូវធ្វើរបាយការណ៍ និងបញ្ជូនសំណុំរឿងទៅព្រះរាជអាជ្ញាដើម្បីចាត់ការតាមច្បាប់ ។ ក្នុងករណីដែលអនីតិជនត្រូវការកិច្ចការពារនិងថែទាំ មន្ត្រីនគរបាលយុត្តិធម៌ត្រូវបញ្ជូនអនីតិជននោះទៅមន្ទីរ ឬការិយាល័យទទួលបន្ទុកវិស័យសង្គមកិច្ចរាជធានី ខេត្ត ក្រុង ខណ្ឌ ដើម្បីចាត់វិធានការសមស្របទៅតាមសុខុមាលភាព និងស្ថានភាពសង្គមរបស់អនីតិជន ។ មន្ទីរ ឬការិយាល័យទទួលបន្ទុក វិស័យសង្គមកិច្ចរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ត្រូវធ្វើរបាយការណ៍អំពីការទទួលអនីតិជនពីនគរបាលយុត្តិធម៌ ជូនទៅព្រះរាជអាជ្ញា ។

[17] មាត្រា៧៤៦ ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា

៤.១. សមត្ថកិច្ចមន្ត្រីនគរបាលយុត្តិធម៌

ក្រោមការដឹកនាំ និងសម្របសម្រួលសកម្មភាពការងារដោយព្រះរាជអាជ្ញា មន្ត្រីនគរបាលយុត្តិធម៌មានភារៈកិច្ចធ្វើការត្រួតពិនិត្យបទឧក្រិដ្ឋ បទមជ្ឈឹម និង បទលហុដែលប្រព្រឹត្តដោយអនីតិជននិងប្រមូលភស្តុតាង កំណត់អត្តសញ្ញាណដើម្បីឃាត់ខ្លួន ឬចាប់ខ្លួនអនីតិជនប្រព្រឹត្តល្មើសនឹងច្បាប់ក្នុងករណីចាំបាច់ ។ ការចាប់ខ្លួននិងការស៊ើបអង្កេតករណីពាក់ព័ន្ធនឹងអនីតិជន ត្រូវធ្វើដោយមន្ត្រីជំនាញ ឬដោយមានជំនួយពីមន្ត្រីនគរបាលយុត្តិធម៌ ដែលបានទទួលការបណ្តុះបណ្តាលស្តីពីយុត្តិធម៌អនីតិជនប្រសិនបើអាចធ្វើទៅបាន។ ដូចនេះហើយក្នុងករណីណាមួយក៏ដោយ នគរបាលយុត្តិធម៌ដែលចាប់ខ្លួន ឬមន្ត្រីនគរបាលយុត្តិធម៌ដែលឃាត់ខ្លួនអនីតិជន ត្រូវប្រគល់របាយការណ៍និងកំណត់ហេតុលម្អិតស្តីពីការចាប់ ឬឃាត់ខ្លួន និងប្រគល់អនីតិជននោះទៅឲ្យផ្នែក ឬអង្គភាពដែលមាននគរបាលយុត្តិធម៌ជំនាញទទួលបន្ទុកការងារអនីតិជន[18] ។

៤.១.១. ការចាប់ខ្លួន

អនុលោមតាមមាត្រា១៥ នៃច្បាប់ស្តីពីយុត្តិធម៌អនីតិជនបានប្បញ្ញត្តិថា នគរបាលយុត្តិធម៌អាចចាប់ខ្លួនអនីតិជនដែលមានអាយុចាប់ពី ១៤ (ដប់បួន)ឆ្នាំ ដល់ក្រោម ១៨(ដប់ប្រាំបី)ឆ្នាំ តែក្នុងករណីដែលអនីតិជនប្រព្រឹត្តបទមជ្ឈិម ឬបទឧក្រិដ្ឋជាក់ស្តែងតែប៉ុណ្ណោះ ។ ប៉ុន្តែអនីតិជនដែលមានអាយុចាប់ពី ១៤(ដប់បួន)ឆ្នាំ ដល់ក្រោម ១៦(ដប់ប្រាំមួយ)ឆ្នាំ ការចាប់ខ្លួនអាចធ្វើទៅបានតែក្នុងករណីដែលអនីតិជននោះប្រព្រឹត្តបទមជ្ឈិមដោយចេតនា ។ រាល់ការចាប់ខ្លួនអនីតិជនត្រូវរាយការណ៍ជូនព្រះរាជអាជ្ញាភ្លាម ។ ការអនុវត្តការចាប់ខ្លួន របស់មន្ត្រីនគរបាលយុត្តិធម៌ត្រូវគោរពតាមនីតិវិធីដូចខាងក្រោម ៖

ក្នុងការចាប់ខ្លួនអនីតិជនត្រូវចៀសវាងក្នុងការធ្វើឲ្យអាម៉ាស់មុខ និងបាត់បង់សេចក្តីថ្លៃថ្នូររបស់អនីតិជន និងត្រូវបញ្ជូនអនីតិជនទៅឲ្យផ្នែក ឬអង្គភាពដែល មាននគរបាលយុត្តិធម៌ជំនាញទទួលបន្ទុកការងារអនីតិជនដែលនៅជិតបំផុត ។ ព្រមទាំងមិនប្រើប្រាស់ខ្នោះដៃ អាវុធ កាំភ្លើង ឬឧបករណ៍ប្រហាក់ប្រហែលសម្រាប់បង្ខំ ឬរារាំងឡើយ លើកលែងតែបានប្រើប្រាស់អស់គ្រប់មធ្យោបាយសម្រាប់ត្រួតត្រាផ្សេងៗទៀតរួចហើយ ឬប្រើគ្រប់មធ្យោបាយផ្សេងៗទៀតពុំសមស្របនឹងកាលទេស: ឬដើម្បីរារាំងសកម្មភាពដែលអនីតិជននោះអាចបង្ករគ្រោះថ្នាក់ធ្ងន់ធ្ងរលើខ្លួនឯង ឬលើបុគ្គលដទៃទៀត[19] ។ ក្នុងករណីមានការរារាំង ឬប្រើប្រាស់កម្លាំងមន្ត្រីនគរបាលយុត្តិធម៌ត្រូវចុះក្នុងកំណត់ហេតុ ហើយបញ្ជាក់ពីមូលហេតុ និងកាល:ទេស:ដែលត្រូវប្រើប្រាស់កម្លាំង ។ បន្ទាប់មក

[18] មាត្រា១៣ កថាខណ្ឌទី២ នៃច្បាប់ស្តីពីយុត្តិធម៌អនីតិជន ឆ្នាំ២០១៦

[19] មាត្រា ១៥ ចំណុចទី២ នៃច្បាប់ស្តីពីយុត្តិធម៌អនីតិជនទំនាស់នឹងច្បាប់ កែសម្រួលខែសីហា ឆ្នាំ២០១០

ត្រូវបញ្ជូនអនីតិជនទៅឲ្យផ្នែក ឬអង្គភាពនគរបាលយុត្តិធម៌ ជំនាញទាក់ទងនឹងអនីតិជនដែលនៅជិតបំផុត ។

ដោយយោងតាមមាត្រា ១៦ នៃច្បាប់ស្តីពីយុត្តិធម៌អនីតិជន ឆ្នាំ២០១៦ បានចែងបន្ថែមថា មន្ត្រីនគរបាលយុត្តិធម៌អាចធ្វើការឆែកឆេរលើខ្លួនបុគ្គលដែលជាអនីតិជនបាន ។ ការឆែកឆេរខ្លួនបុគ្គលត្រូវធ្វើឡើងដោយបុគ្គលដែលភេទដូចគ្នា និងមិនត្រូវជាប់ពាក់ព័ន្ធនឹងបទល្មើសពុំមានទំនាស់ឬមិនជាប់សាច់ញាតិ ឬមានទំនាក់ទំនងជិតស្និទ្ធជាមួយអនីតិជននោះឡើយលើកលែងតែក្នុងករណីមិនអាចចៀសវាងបាន ។ មន្ត្រីនគរបាលយុត្តិធម៌ត្រូវធ្វើកំណត់ហេតុ និងចុះនិទ្ទេសអំពីបញ្ហានេះ។

មន្ត្រីនគរបាលយុត្តិធម៌ ត្រូវជូនដំណឹងជាបន្ទាន់ទៅអ្នកតំណាងដែលច្បាប់បានកំណត់របស់ អនីតិជនបន្ទាប់ពីការចាប់ខ្លួន ឬឃាត់ខ្លួនអនីតិជននោះ ។ ក្នុងករណីមិនអាចផ្តល់ដំណឹងនេះជាបន្ទាន់ត្រូវជូនដំណឹងដល់អ្នកតំណាងដែលច្បាប់បានកំណត់ក្នុងរយៈពេលយ៉ាងខ្លីបំផុត ដែលអាចធ្វើទៅបានអំពី ៖

១. មូលហេតុនៃការចាប់ខ្លួន ឬឃាត់ខ្លួន និងប្រភេទនៃបទល្មើស

២. ទីកន្លែងដែលអនីតិជនកំពុងស្ថិតនៅ

៣. សិទ្ធិចូលរួមរបស់អ្នកតំណាងដែលច្បាប់បានកំណត់នៅក្នុងអង្គភាពនគរបាល ។

ក្នុងករណីមិនអាចទាក់ទងអ្នកតំណាងដែលច្បាប់បានកំណត់ របស់អនីតិជនបាន មន្ត្រីនគរបាលយុត្តិធម៌ត្រូវប្រឹងប្រែងទាក់ទងអ្នកទំនុកបម្រុងដែលជ្រើសរើសដោយអនីតិជន ឬដោយមន្ត្រីនគរបាលយុត្តិធម៌ ដោយមានការយល់ព្រមពីអនីតិជននោះ ។ មន្ត្រីនគរបាលយុត្តិធម៌ ត្រូវជូនដំណឹងភ្លាមផងដែរទៅភ្នាក់ងារសង្គមកិច្ច បន្ទាប់ពីអនីតិជននោះត្រូវបាននាំមកដល់អង្គភាពនគរបាលយុត្តិធម៌ ដើម្បីផ្តល់សេវាគាំទ្រផ្លូវចិត្ត និងសង្គមដល់អនីតិជននោះ[20] ។

មន្ត្រីនគរបាលយុត្តិធម៌ ត្រូវជូនដំណឹងភ្លាមទៅមេធាវីរបស់អនីតិជន ប្រសិនបើមាន ។ ក្នុងករណីដែលគ្មានការជ្រើស មន្ត្រីនគរបាលយុត្តិធម៌ត្រូវរកមេធាវីដោយមិនយកកម្រៃឲ្យអនីតិជននោះឲ្យ បានឆាប់បំផុតតាមដែលអាចធ្វើទៅបាន បន្ទាប់ពីអនីតិជននោះត្រូវបាននាំមកដល់អង្គភាពនគរបាលយុត្តិធម៌ ។ មន្ត្រីនគរបាលយុត្តិធម៌ត្រូវមានបញ្ជីឈ្មោះមេធាវីសម្រាប់ឲ្យអនីតិជនធ្វើការជ្រើសរើស ។ មន្ត្រីនគរបាលយុត្តិធម៌ត្រូវរកអ្នកបកប្រែភាសាដោយមិនយកកម្រៃឲ្យអនីតិជន ក្នុងករណីដែលអនីតិជននោះពុំមានអ្នកបកប្រែភាសាផ្ទាល់ខ្លួន ។

ក្រោយពីការចាប់ខ្លួនអនីតិជនភ្លាម។មន្ត្រីនគរបាលយុត្តិធម៌ត្រូវប្រាប់អនីតិជនអំពី ៖

[20] មានត្រា ១៨ កថាខណ្ឌទី៣ នៃច្បាប់ស្តីពីយុត្តិធម៌ ឆ្នាំ២០១៦

១. មូលហេតុនៃការចាប់ខ្លួន និងប្រភេទបទល្មើសដែលជាប់សង្ស័យថាបានប្រព្រឹត្ត

២. សិទ្ធិមិនផ្តល់ចម្លើយនៅពេលដែលមាន ឬគ្មានវត្តមានមេធាវី

៣. សិទ្ធិមិនទទួលការបង្ខិតបង្ខំឲ្យឆ្លើយដាក់បន្ទុកលើខ្លួនឯង

៤. សិទ្ធិរក្សាការសម្ងាត់នៃជីវិតឯកជន

៥. សិទ្ធិទទួលបានការពិនិត្យសុខភាព និងការព្យាបាល

៦. សិទ្ធិក្នុងការជូនដំណឹងអំពីការចាប់ខ្លួនទៅដល់អ្នកតំណាងដែលច្បាប់បានកំណត់

៧. សិទ្ធិទទួលបានជំនួយពីមេធាវីដោយការជ្រើសរើស ឬដោយការចាត់តាំងមិនយកកម្រៃស្របតាមលក្ខខណ្ឌដែលចែងដោយច្បាប់ស្តីពីលក្ខន្តិក:មេធាវី ចាប់តាំងពីដំណាក់កាលដំបូងបំផុតនៃនីតិវិធី

៨. សិទ្ធិទទួលបានជំនួយពីអ្នកបកប្រែភាសា ដោយមិនយកកម្រៃ កាលបើមានការចាំបាច់

៩. សិទ្ធិទំនាក់ទំនងជាមួយស្ថានទូត ស្ថានកុងស៊ុល ក្នុងករណីអនីតិជនជាជនបរទេស ។

៤.១.២. ការឃាត់ខ្លួន

ដើម្បីធានាថាទំនាក់ទំនងរវាងនគរបាលយុត្តិធម៌ និងកុមារត្រូវបានគ្រប់គ្រងដោយគោរពចំពោះស្ថានភាពផ្លូវច្បាប់របស់កុមារ និងលើកកម្ពស់សុខុមាលភាពរបស់កុមារ ព្រមទាំងចៀសវាងការធ្វើឲ្យប៉ះពាល់ដល់កុមារ ច្បាប់ស្តីពីយុត្តិធម៌អនីតិជនរបស់ប្រទេសភាគច្រើនជាទូទៅចែងនូវបទប្បញ្ញត្តិជាច្រើនដែលទាក់ទងនឹងអនីតិជន ។ ច្បាប់ស្តីពីយុត្តិធម៌អនីតិជនរបស់ប្រទេសទាំងនោះចែងបទប្បញ្ញត្តិដូចខាងក្រោមនេះ ៖

ការប្រើអំពើហិង្សាលើកុមារត្រូវបានហាមឃាត់ ហើយមានការកំហិតទៅលើការប្រើប្រាស់ការបង្ខំលើរូបកាយ ឬការប្រើខ្នោះដៃលើកលែងតែក្នុងកាល:ទេស:ពិសេសដែលមានចែងច្បាស់(ដូចជានៅពេលដែលចាំបាច់ត្រូវរារាំងកុមារមិនឲ្យរបួសខ្លួនគេ ឬរបួសដល់អ្នកដទៃ) ។ មធ្យោបាយជំនួសឲ្យការឃាត់ខ្លួនជាផ្លូវការ ត្រូវបានប្រើប្រាស់នៅក្នុងបទល្មើសតូចតាចដូចជាការចេញលិខិតកោះហៅ ឬការជូនដំណឹងជាលាយលក្ខអក្សរឲ្យបង្ហាញខ្លួននៅក្នុងតុលាការ ។ នគរបាលមានកាតព្វកិច្ចក្នុងការជូនដំណឹងភ្លាមៗដល់ឪពុកម្តាយ អ្នកអាណាព្យាបាល ឬអ្នកទំនុកបម្រុងផ្សេងទៀតតាមការជ្រើសរើសរបស់អនីតិជន បន្ទាប់ពីមានការឃាត់ខ្លួន ឬមិនត្រូវលើសរយ:ពេលដែលបានកំណត់(ជាទូទៅអតិបរមា២៤ម៉ោង) ។ កុមារដែលត្រូវឃុំខ្លួន នៅការឃុំឃាំងដោយនគរបាលត្រូវបំបែកចេញពីនីតិជន ឬបញ្ជូនទៅមណ្ឌលតាមដានពិសេសសម្រាប់កុមារ ។ មេធាវីជំនួយការមេធាវី និងភ្នាក់ងារសង្គមកិច្ចមន្ត្រីទទួលបន្ទុកការងារព្យួរទោសសាកល្បងត្រូវមានវត្តមានក្នុងអំឡុងពេលសួរចម្លើយ ។ អនីតិជនមិនត្រូវបានទទួលរងទារុណកម្ម ការបង្ខិតបង្ខំ ការគំរាមកំហែង

ការសម្លុតបំភិតបំភ័យ ឬទង្វើណាមួយផ្សេងទៀតដែលនាំឲ្យប៉ះពាល់ដល់សេចក្តីថ្លៃថ្នូររបស់អនីតិជន ឬទទួលរងអំពើអមនុស្សធម៌ណាមួយឡើយ ។ ការឃាត់ខ្លួន ការឃុំខ្លួនដោយមន្ត្រីនគរបាលត្រូវបានប្រើសម្រាប់តែវិធានការចុងក្រោយប៉ុណ្ណោះ ពេលខ្លះចែងអំពីការហាមឃាត់យ៉ាងច្បាស់មិនឲ្យនគរបាលឃាត់ខ្លួន និងឃុំខ្លួនសម្រាប់បទល្មើសតូចតាចទេ។

ការឃាត់ខ្លួនអនីតិជន គឺមិនត្រូវបានឃាត់ខ្លួនឡើយចំពោះអនីតិជនដែលមានអាយុតិចជាង ១៤(ដប់បួន)ឆ្នាំ ។ មន្ត្រីនគរបាលយុត្តិធម៌អាចឃាត់ខ្លួនអនីតិជនចាប់ពីអាយុ ១៤(ដប់បួន)ឆ្នាំ ដល់ក្រោម ១៨(ដប់ប្រាំបី)ឆ្នាំ បានប្រសិនបើមន្ត្រីនគរបាលយុត្តិធម៌ជឿជាក់ថាអនីតិជន អាចរត់គេចខ្លួន ឬបំផ្លាញ ភស្តុតាង ឬបង្កគ្រោះថ្នាក់ដល់សុវត្ថិភាពសាក្សី ជនរងគ្រោះ ឬសន្តិសុខសាធារណៈ ឬក្នុងគោលការណ៍ការពារសុវត្ថិភាពអនីតិជននោះ ។ ប៉ុន្តែអនីតិជនដែលមានអាយុចាប់ពី ១៤(ដប់បួន)ឆ្នាំ ដល់ក្រោម ១៦(ដប់ប្រាំមួយ)ឆ្នាំ ការឃាត់ខ្លួនអាចធ្វើទៅបានតែក្នុងករណីដែលអនីតិជន នោះប្រព្រឹត្តបទមជ្ឈិមដោយចេតនា ។ រាល់ការឃាត់ខ្លួនអនីតិជន ត្រូវរាយការណ៍ជូនព្រះរាជអាជ្ញាភ្លាម ។ ចំណែកឯថិរវេលានៃការឃាត់ខ្លួនអនីតិជន ឬកុមារវិញក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា បានចែងថា សម្រាប់កុមារចាប់ពីអាយុ ១៤ឆ្នាំ ដល់ក្រោម ១៨ឆ្នាំ ដែលជាប់សង្ស័យពាក់ព័ន្ធនឹងបទឧក្រិដ្ឋ មន្ត្រីនគរបាលយុត្តិធម៌អាចឃាត់ខ្លួនបានរយៈពេល៣៦ម៉ោង និងសម្រាប់បទមជ្ឈិមអាចឃាត់ខ្លួនបានរយៈពេល២៤ម៉ោង ។ ចំពោះថិរវេលានៃការឃាត់ខ្លួនអនីតិជន ឬកុមារពីអាយុចាប់ពី ១៦ឆ្នាំ ដល់ក្រោម ១៨ឆ្នាំ ដែលជាប់សង្ស័យពាក់ព័ន្ធនឹងបទឧក្រិដ្ឋ មន្ត្រីនគរបាលយុត្តិធម៌អាចឃាត់ខ្លួនបានរយៈពេល ៤៨ម៉ោង និងសម្រាប់បទមជ្ឈិម មន្ត្រីនគរបាលយុត្តិធម៌អាចឃាត់ខ្លួនបាន រយៈពេល ៣៦ម៉ោង ។ ការឃាត់ខ្លួននេះ ជាវិធានការចុងក្រោយប៉ុណ្ណោះ ។ ការឃាត់ខ្លួនអាចធ្វើតែក្នុងករណីអនីតិជនបានប្រព្រឹត្តបទមជ្ឈិម ឬបទឧក្រិដ្ឋតែប៉ុណ្ណោះ ។ រយៈពេលនៃការឃាត់ខ្លួន មន្ត្រីនគរបាលយុត្តិធម៌ត្រូវគោរពតាមបទប្បញ្ញត្តិដែលមានចែងក្នុងក្រមនីតិវិធីព្រហ្មទណ្ឌ ។

នៅពេលឃាត់ខ្លួនជនណាម្នាក់ មន្ត្រីនគរបាលយុត្តិធម៌ ត្រូវធ្វើកំណត់ហេតុនៃការឃាត់ខ្លួន ហើយព័ត៌មានក្នុងកំណត់ហេតុនោះ ត្រូវមានដូចតទៅ ៖

- ឈ្មោះ និងឋានៈរបស់មន្ត្រីនគរបាលយុត្តិធម៌
- អត្តសញ្ញាណនៃបុគ្គលដែលត្រូវឃាត់ខ្លួន
- មូលហេតុនៃការឃាត់ខ្លួន
- ថ្ងៃ ខែ ឆ្នាំ និងម៉ោងដែលផ្តើមឃាត់ខ្លួន
- ការឲ្យដំណឹងអំពីសិទ្ធិក្នុងការសន្ទនាជាមួយមេធាវី ឬបុគ្គលណាម្នាក់ បន្ទាប់ពីស្ថិតក្រោម

ការឃាត់ខ្លួនរបស់នគរបាលរយៈពេល ២៤ម៉ោង ។

៤.២. ការសាកសួរ និងការស្តាប់ចម្លើយរបស់មន្ត្រីនគរបាលយុត្តិធម៌

នៅមុនពេលនីតិវិធីមុនការស្តាប់ចម្លើយរបស់មន្ត្រីនគរបាលយុត្តិធម៌ អនីតិជនត្រូវទទួលបាន ឱកាសសន្ទនា ឬ ទំនាក់ទំនងជាមួយអ្នកមានអំណាចមេបា អ្នកអាណាព្យាបាលសម្រាប់អនីតិជន និងអ្នកអាណាព្យាបាលទូទៅ ឬ អ្នកទំនុកបម្រុង ឬ ភ្នាក់ងារសង្គមកិច្ច និង មេធាវីជាលក្ខណៈឯកជន និងជាសម្ងាត់ ប្រសិនបើមានការស្នើសុំ លើកលែងតែជនទាំងនេះមានការទាក់ទិនក្នុងរឿងជាមួយ ។ ការជួបសន្ទនា ឬ ទាក់ទងគ្នាជាមួយឪពុកម្តាយ អ្នកទំនុកមង្រុង មេធាវីមានរយៈពេល ៣០(សាមសិប)នាទី និងត្រូវធ្វើមុនពេលស្តាប់ចម្លើយ ប្រសិនបើអាចធ្វើទៅបាន[21] ។

មុនពេលផ្តើមស្តាប់ចម្លើយ មន្ត្រីនគរបាលយុត្តិធម៌ ត្រូវប្រាប់ដល់អនីតិជនអំពីសិទ្ធិជាមូលដ្ឋានជាពិសេស គឺសិទ្ធិមិនផ្តល់ចម្លើយនៅពេលដែលមាន ឬគ្មានវត្តមានមេធាវី ។ ការធ្វើការសាកសួរ និងការស្តាប់ចម្លើយចំពោះអនីតិជនត្រូវធ្វើឡើងដោយ ការគោរពភាពជាឯកជននៃអនីតិជន និងត្រូវរក្សាការសម្ងាត់រាល់ការទទួលបានពីការសាកសួរនោះ ។ ការស្តាប់ចម្លើយត្រូវប្រព្រឹត្តដោយមានវត្តមានរបស់មេធាវី ដោយប្រើប្រាស់នីតិវិធីកុមារមេត្រីមានលក្ខណៈជាឯកជន និងជាការសម្ងាត់[22] ។ អ្នកតំណាងដែលច្បាប់បានកំណត់ ឬអ្នកទំនុកបម្រុងរបស់អនីតិជន និងភ្នាក់ងារសង្គមកិច្ចដែលមានសិទ្ធិ ហើយអាចផ្តល់ជំនួយដល់អនីតិជន មានសិទ្ធិចូលរួមក្នុងការស្តាប់ចម្លើយអនីតិជនបាន ។ មន្ត្រីនគរបាលយុត្តិធម៌អាចមិនអនុញ្ញាតឲ្យ ឪពុកម្តាយ ឬអ្នកអាណាព្យាបាលចូលរួមស្តាប់ចម្លើយបាន ប្រសិនបើវត្តមានរបស់អ្នកទាំងនេះផ្ទុយនឹងឧត្តមប្រយោជន៍របស់អនីតិជន ។ ការមិនអនុញ្ញាតនោះត្រូវមានការពិភាក្សាជាមួយនឹងមេធាវី ឬភ្នាក់ងារសង្គមកិច្ច និងអនីតិជន។ ប្រសិនបើមិនអនុញ្ញាតឲ្យ ឪពុកម្តាយ ឬអ្នកអាណាព្យាបាលចូលរួមបាន ត្រូវឲ្យអនុញ្ញាតឲ្យអ្នកទំនុកបម្រុងអនីតិជនចូលរួមជំនួសប្រសិនបើមាន ។ ក្នុងករណីអវត្តមានឪពុកម្តាយ ឬអ្នកអាណាព្យាបាល ឬអ្នកទំនុកបម្រុង ឬមេធាវីរបស់អនីតិជន ឬបុគ្គលិកសង្គមកិច្ចក្នុងពេលស្តាប់ចម្លើយមន្ត្រីនគរបាលត្រូវចុះនិទ្ទេសក្នុងកំណត់ហេតុ ដោយបញ្ជាក់ពីមូលហេតុនៃវត្តមាននោះហើយបញ្ចូលក្នុងសំណុំរឿងរបស់អនីតិជន។បន្ទាប់ពីបញ្ចប់ការស្តាប់ចម្លើយភ្លាមអនីតិជនមានសិទ្ធិអានកំណត់ហេតុស្តាប់ចម្លើយបាន។ ក្នុងករណីអនីតិជនមិនអាចអានបាន មន្ត្រីនគរបាលយុត្តិធម៌ ឬអ្នកបកប្រែត្រូវអានកំណត់ហេតុ ស្តាប់ចម្លើយឲ្យអនីតិជនស្តាប់ ។ មន្ត្រីនរគបាលយុត្តិធម៌ត្រូវអនុញ្ញាតឲ្យមេធាវី ឬឪពុកម្តាយ ឬអ្នកអាណាព្យាបាល ឬអ្នកទំនុកបម្រុងអនីតិជន ឬភ្នាក់ងារសង្គមកិច្ចអាន

[21] មាត្រា ២១ នៃច្បាប់ស្តីពីយុត្តិធម៌អនីតិជន ឆ្នាំ២០១៦

[22] មាត្រា ២២ កថាខណ្ឌទី២ នៃច្បាប់ស្តីពីយុត្តធម៌អនីតិជន ឆ្នាំ២០១៦

កំណត់ហេតុស្តាប់ចម្លើយ ។ អនីតិជនអាចសុំកែប្រែ ឬបន្ថែមបន្ថយចម្លើយលើកំណត់ហេតុស្តាប់ចម្លើយបាន មុននឹងចុះហត្ថលេខា ឬផ្ទិតមេដៃលើកំណត់ហេតុ និងក្នុងករណីអនីតិជន ឬអ្នកចូលរួមណាមួយមិនព្រមចុះហត្ថលេខា ឬផ្ទិតមេដៃលើកំណត់ហេតុមន្ត្រីនគរបាលយុត្តិធម៌ត្រូវចុះនិទ្ទេសនៅក្នុងកំណត់ហេតុនោះ[23]។ វិធានដែលបានបញ្ញត្តិនៅក្នុងមាត្រា២២ នៃច្បាប់ស្តីពីយុត្តិធម៌អនីតិជន ឆ្នាំ២០១៦ នេះមានលក្ខណៈដាច់ខាតត្រូវតែគោរពតាម បើមិនដូច្នេះទេនឹងនាំឲ្យមានមោឃៈភាពនៃនីតិវិធី ។

៤.៣. រយៈពេលនៃការឃាត់ខ្លួនរបស់មន្ត្រីនគរបាលយុត្តិធម៌

មន្ត្រីនគរបាលយុត្តិធម៌មិនអាចធ្វើការឃាត់ខ្លួនអនីតិជន ដែលបានប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌបានទេ លើកលែងតែជាវិធានការចុងក្រោយ ហើយនិងក្នុងករណីដែលមន្ត្រីនគរបាលជឿជាក់អនីតិជនទំនងនឹងធ្វើការរត់គេចខ្លួន ឬលុបបំបាត់ភស្តុតាងនានា ឬអនីតិជន អាចនឹងធ្វើការបង្កគ្រោះថ្នាក់ដល់សុវត្ថិភាពសាក្សី ឬជនរងគ្រោះ ឬបង្កគ្រោះថ្នាក់ចំពោះសន្តិសុខសាធារណៈ។ ផ្ទុយទៅវិញ មន្ត្រីនគរបាលយុត្តិធម៌ត្រូវបញ្ចប់ការស៊ើបសួរឲ្យបានលឿន តាមលទ្ធភាពដែលអាចធ្វើបានដើម្បីធានាថាឃាត់ខ្លួនប្រព្រឹត្តទៅក្នុងរយៈពេលខ្លីបំផុតដែលអាចធ្វើទៅបាន ។ ករណីចាំបាច់ មន្ត្រីនគរបាលយុត្តិធម៌ត្រូវបន្តការស៊ើបសួរក្នុងកម្រិតដែលអាចធ្វើទៅបាន ហើយត្រូវដោះលែងអនីតិជនឲ្យទៅឪពុកម្តាយរបស់អនីតិជន ឬអាណាព្យាបាលសម្រាប់អនីតិជន ឬនីតិជនដែលទទួលខុសត្រូវថែរក្សានៅក្នុងលក្ខខណ្ឌដែលអនីតិជន និងឪពុកម្តាយរបស់អនីតិជន ឬអាណាព្យាបាលសម្រាប់អនីតិជន ឬនីតិជនដែលព្រមទទួលខុសត្រូវរបស់អនីតិជនចំពោះមន្ត្រីនគរបាលយុត្តិធម៌ ហើយបុគ្គលនោះត្រូវបង្ហាញខ្លួននៅទីស្នាក់ការរបស់មន្ត្រីនគរបាលយុត្តិធម៌ ឬចំពោះមុខព្រះរាជអាជ្ញា ឬចៅក្រមស៊ើបសួរ ប្រសិនបើរឿងក្តីតម្រូវយ៉ាងណានោះ ។ មន្ត្រីនគរបាលយុត្តិធម៌អាចតម្រូវឲ្យមានលក្ខខណ្ឌមួយចំនួនសម្រាប់មុនការដោះលែងដូចជា: តម្រូវឲ្យអនីតិជននៅផ្ទះក្នុងរយៈពេលណាមួយ ហើយតម្រូវឲ្យរាយការណ៍ដល់នគរបាលនៅពេលវេលាជាក់លាក់ណាមួយ ព្រមទាំងហាមមិនឲ្យអនីតិជនសេពគ្រឿងស្រវឹង និងមិនឲ្យសេពគប់ជាមួយជនមួយចំនួននៅពេលខ្លះរាល់លក្ខខណ្ឌទាំងអស់ រួមបញ្ចូលទាំងការហាមមិនឲ្យទៅជួបជនរងគ្រោះ និងមិនឲ្យធ្វើដំណើរទៅទីកន្លែងណាមួយ ឬលក្ខខណ្ឌដែលសមស្របតាមស្ថានភាពណាមួយ ។ ដោយយោងតាមគោលការណ៍ជាក់ស្តែង ករណីដែលចាំបាច់បំផុតដែលនាំឲ្យមានការឃាត់ខ្លួននោះ មន្ត្រីនគរបាលយុត្តិធម៌មិនត្រូវឃាត់ខ្លួនអនីតិជនដោយប្រើថិរវេលាលើសពី ៤៨ម៉ោងគិតចាប់ពីម៉ោងចាប់ខ្លួនអនីតិជន។

[23] មាត្រា ២២កថាខណ្ឌទី៩ នៃច្បាប់ស្តីពីយុត្តិធម៌អនីតិជន ឆ្នាំ២០១៦

ជំពូកទី ២

សមត្ថកិច្ចរបស់ស្ថាប័ន
គុណភាពចំពោះអនីតិជន

ជំពូកទី ២

សមត្ថកិច្ចរបស់ស្ថាប័នតុលាការចំពោះអនីតិជន

ផ្នែកទី១ : ការចោទប្រកាន់របស់អយ្យការចំពោះអនីតិជន

១.១. សមត្ថកិច្ចរបស់អង្គការអយ្យការ

បណ្តឹងអាជ្ញាត្រូវអនុវត្តក្នុងនាមផលប្រយោជន៍ទូទៅដោយអយ្យការ ។ អយ្យការធ្វើការចោទប្រកាន់បទល្មើសព្រហ្មទណ្ឌដែលពាក់ព័ន្ធនិងអនីតិជន ។ ការចោទប្រកាន់ករណីទាំងឡាយដែលពាក់ព័ន្ធនឹងអនីតិជន ត្រូវឲ្យតំណាងអយ្យការដែលទទួលបានការចាត់តាំងពិសេសឲ្យកាន់រឿងក្តីអនីតិជន ទោះជាការចាត់តាំងនោះឲ្យធ្វើតែរឿងអនីតិជនដាច់ខាត ឬមិនដាច់ខាតក្តី ។ តំណាងអយ្យការដែលនឹងត្រូវចាត់ឲ្យកាន់រឿងក្តីអនីតិជនត្រូវទទួលបានការបណ្តុះបណ្តាលជំនាញឯកទេសផ្នែកសិទ្ធិកុមារ ច្បាប់និងបទប្បញ្ញត្តិផ្សេងៗទាក់ទងនឹងយុត្តិធម៌អនីតិជន[24] ។

១.១.១. ការផ្ទៀងផ្ទាត់អាយុរបស់អនីតិជន

នៅពេលដែលបានទទួលសំណុំរឿងពីមន្ត្រីនគរបាលយុត្តិធម៌រួចហើយ តំណាងអង្គការអយ្យការត្រូវត្រួតពិនិត្យសំណុំឯកសារ និងបណ្តឹងដែលខ្លួនបានទទួលដើម្បីផ្ទៀងផ្ទាត់អាយុពិតប្រាកដរបស់អនីតិជនមុននឹងធ្វើការចោទប្រកាន់ ឬមិនចោទប្រកាន់ករណីដែលអនីតិជនអាយុតិចជាង ១៤(ដប់បួន)ឆ្នាំ ។

ក្នុងករណីមានវិមតិសង្ស័យអំពីអាយុរបស់អនីតិជន ព្រះរាជអាជ្ញាត្រូវបើកការស៊ើបអង្កេតបឋមឲ្យបានឆាប់បំផុត ដើម្បីស្វែងរកឲ្យឃើញអាយុពិតប្រាកដរបស់អនីតិជននោះ ។ ក្នុងករណីការស៊ើបអង្កេតបឋមនោះមិនអាចឈានដល់ការសន្និដ្ឋាន អំពីអាយុពិតប្រាកដរបស់អនីតិជន ព្រះរាជអាជ្ញាត្រូវធ្វើដីកាសន្និដ្ឋានបញ្ជូនសំណុំរឿងនេះទៅឲ្យចៅក្រមស៊ើបសួរ ។

១.១.២. ការសួរចម្លើយដោយតំណាងអយ្យការ

នៅមុនពេលធ្វើការសាកសួរអនីតិជនតំណាងអង្គការអយ្យការ ត្រូវជូនដំណឹងជាមុនទៅឪពុកម្តាយរបស់អនីតិជន ឬអ្នកអាណាព្យាបាលសម្រាប់អនីតិជនដើម្បីឲ្យពួកគេអាចចូលរួមក្នុងការសាកសួរ ។ ហើយព្រះរាជអាជ្ញាត្រូវប្រាប់អនីតិជន និងអ្នកចូលរួមស្តាប់ចម្លើយអំពីសិទ្ធិដែលមានចែកក្នុងមាត្រា៦ (សិទ្ធិជាមូលដ្ឋានក្នុងនីតិវិធី) នៃច្បាប់ស្តីពីយុត្តិធម៌អនីតិជន ឆ្នាំ២០១៦ ជាពិសេសការប្រើភាសា និងអាកប្បកិរិយាសមស្របទៅនឹងកម្រិតនៃការយល់ដឹងរបស់អនីតិជន មុនពេលធ្វើការស្តាប់ចម្លើយ ។ ក្នុងករណីដែលគ្មានការជ្រើសរើសព្រះរាជអាជ្ញាត្រូវចាត់តាំងមេធាវីដោយមិនយកកម្រៃឲ្យអនីតិជននោះ ។ ការស្តាប់ចម្លើយអនីតិជនត្រូវធ្វើជាសម្ងាត់ និងប្រើប្រាស់

[24] មាត្រា ២៤ កថាខណ្ឌទី២នៃច្បាប់ស្តីពីយុត្តិធម៌អនីតិជន អនុម័តថ្ងៃទី១៤ ខែកក្កដា ឆ្នាំ២០១៦

នីតិវិធីកុមារមេត្រី។ ការស្តាប់ចម្លើយនេះត្រូវមានវត្តមានមេធាវី ភ្នាក់ងារសង្គមកិច្ច អ្នកតំណាងដែលច្បាប់បានកំណត់ ឬអ្នកទំនុកបម្រុងរបស់អនីតិជន។ ព្រះរាជអាជ្ញាអាចមិនអនុញ្ញាតឲ្យអ្នកតំណាងដែលកំណត់ចូលរួមស្តាប់ចម្លើយបាន ប្រសិនបើវត្តមានអ្នកទាំងនោះផ្ទុយនឹងឧត្តមប្រយោជន៍របស់អនីតិជន ។ ការមិនអនុញ្ញាតនេះ ត្រូវមានការពិគ្រោះយោបល់ជាមួយមេធាវី ឬភ្នាក់ងារសង្គមកិច្ច និង អនីតិជន ។ ក្នុងករណីអវត្តមានជនណាមួយខាងលើព្រះរាជអាជ្ញាត្រូវចុះនិទ្ទេសក្នុងកំណត់ហេតុស្តាប់ចម្លើយដោយបញ្ជាក់អំពីមូលហេតុ។

បន្ទាប់ពីបញ្ចប់ការស្តាប់ចម្លើយ ភ្លាមអនីតិជនមានសិទ្ធិអានកំណត់ហេតុស្តាប់ចម្លើយបាន។ ក្នុងករណីអនីតិជនមិនអាចអានកំណត់ហេតុស្តាប់ចម្លើយបាន ក្រឡាបញ្ជី ឬអ្នកបកប្រែត្រូវអានកំណត់ហេតុស្តាប់ចម្លើយឲ្យអនីតិជនស្តាប់ ។ អនីតិជនអាចសុំកែប្រែ ឬបន្ថែមបន្ថយចម្លើយលើកំណត់ហេតុស្តាប់ចម្លើយបាន មុននឹងចុះហត្ថលេខា ឬផ្ទិតម្រាមដៃ ។

ព្រះរាជអាជ្ញាត្រូវអនុញ្ញាឲ្យមេធាវី ឬឪពុកម្តាយរបស់អនីតិជន ឬអ្នកអាណាព្យាបាលសម្រាប់ អនីតិជន ឬអ្នកទំនុកបម្រុង ឬភ្នាក់ងារសង្គមកិច្ចអានកំណត់ហេតុស្តាប់ចម្លើយបាន ។ មេធាវី អ្នកតំណាងដែលច្បាប់បានកំណត់ ឬអ្នកទំនុកបម្រុងរបស់អនីតិជន ភ្នាក់ងារសេដ្ឋកិច្ចដែលមានវត្តមាន ត្រូវចុះហត្ថលេខា ឬផ្ទិតម្រាមដៃលើកំណត់ហេតុ ។ ក្នុងករណីដែលអនីតិជន ឬអ្នកចូលរួមណាមួយមិនព្រមចុះហត្ថលេខាឬផ្ទិតម្រាមដៃលើកំណត់ហេតុ ព្រះរាជអាជ្ញាត្រូវចុះនិទ្ទេសក្នុងកំណត់ហេតុស្តាប់ចម្លើយ ។ វិធាននេះមានលក្ខណៈដាច់ខាតត្រូវតែគោរពតាម បើមិនដូច្នេះទេនឹងនាំឲ្យមានមោឃៈភាពនៃនីតិវិធី ។

១.១.៣. ការកម្ចាស់រឿងទុកឥតចាត់ការចំពោះអនីតិជន

ក្នុងករណីអនីតិជនមានអាយុក្រោម ១៤ឆ្នាំ(ដប់បួន)ឆ្នាំ គិតមកត្រឹមថ្ងៃដែលសង្ស័យថាបានចូលរួមប្រព្រឹត្តបទល្មើស នោះព្រះរាជអាជ្ញាត្រូវសម្រេចតម្កល់រឿងទុកឥតចាត់ការ និងត្រូវអនីតិជនទៅឲ្យឪពុកម្តាយ ឬអាណាព្យាបាលវិញ ។ ក្នុងករណីដែលអនីតិជនត្រូវការកិច្ចការពារនិងថែទាំ ព្រះរាជអាជ្ញាត្រូវបញ្ជូនអនីតិជននោះទៅមន្ទីរទទួលបន្ទុកវិស័យសង្គមកិច្ចរាជធានី ខេត្ត ដើម្បីចាត់វិធានការសមស្របទៅតាមសុខុមាលភាព និងស្ថានភាពសង្គមរបស់អនីតិជន[25] ។

១.២. អំណាចរបស់តំណាងអយ្យការក្នុងការបង្ខែ

ចំពោះអនីតិជនមានអាយុចាប់ពី ១៤(ដប់បួន)ឆ្នាំ ដល់ក្រោម១៨(ដប់ប្រាំបី)ឆ្នាំ បានប្រព្រឹត្តបទលហុ ឬបទមជ្ឈិម ព្រះរាជអាជ្ញាត្រូវពិចារណាជាបឋមទៅលើការបង្ខែរដូចមានចែងក្នុងជំពូកទី១០(ការបង្ខែ) នៃច្បាប់ស្តីពីយុត្តិធម៌អនីតិជន ក្នុងករណីព្រះរាជអាជ្ញាសម្រេចបង្ខែ បទប្បញ្ញត្តិនៃ

[25] មាត្រា ២៧ កថាខណ្ឌទី២ នៃច្បាប់ស្តីពីយុត្តិធម៌អនីតិជន ឆ្នាំ២០១៦

ជំពូកទី១០ (ការបង្ខែ) នេះត្រូវយកមកអនុវត្ត ។ ក្នុងករណីនេះព្រះរាជអាជ្ញាត្រូវសម្រេចផ្ទាកនីតិវិធីចោទប្រកាន់ដោយដីកាសម្រេច ។ ប្រសិនបើការរៀបចំផែនការបង្ខែត្រូវការពេលវេលា ព្រះរាជអាជ្ញាផ្ទាកនីតិវិធីចោទប្រកាន់ និងបង្គាប់ឲ្យប្រគល់អនីតិជនទៅឪពុកម្តាយ ឬអ្នកណាព្យាបាល ឬមន្ទីរទទួលបន្ទុកវិស័យសង្គមកិច្ចរាជធានី ខេត្ត ដើម្បីទទួលបានការគ្រប់គ្រង និងថែទាំ ដើម្បីរង់ចាំអនុវត្តផែនការបង្ខែ ។

ព្រះរាជអាជ្ញាជូនដំណឹងដល់ជនរងគ្រោះ ឬអ្នកតំណាងស្របច្បាប់របស់ជនរងគ្រោះ ក្នុងករណីជនរងគ្រោះជាអនីតិជន និងមេធាវីរបស់អនីតិជនអំពីការសម្រេចផ្ទាកនីតិវិធីចោទប្រកាន់។ ជនរងគ្រោះ ឬអ្នកតំណាងស្របច្បាប់របស់ជនរងគ្រោះ អាចប្តឹងទាមទារសំណងទៅតុលាការរដ្ឋប្បវេណី ។ ព្រះរាជអាជ្ញា ត្រូវសម្រេចចេញដីកាតម្កល់រឿងទុកឥតចាត់ការ ក្នុងករណីដែលការអនុវត្តផែនការបង្ខែទទួលបានជោគជ័យដោយផ្អែកលើលទ្ធផលនៃរបាយការណ៍ដែលបញ្ជាក់រួមគ្នាពីភ្នាក់ងារសង្គមកិច្ច និងអ្នកទទួលបន្ទុកអនុវត្តផែនការបង្ខែ ។ ក្នុងករណីអនីតិជនអនុវត្តផែនការបង្ខែមិនបានជោគជ័យ ព្រះរាជអាជ្ញាអាចចេញដីកាសម្រេចបង្ខែជាថ្មី ដោយពិចារណាទៅលើមូលហេតុដែលនាំបរាជ័យក្នុងការអនុវត្តផែនការបង្ខែទស្សនៈរបស់អនីតិជន អ្នកតំណាងដែលច្បាប់បានកំណត់ និងការពិគ្រោះយោបល់ជាមួយភ្នាក់ងារសង្គមកិច្ច ឬចាត់វិធានការតាមនីតិវិធី ។

១.២.១. ការផ្សព្វផ្សាយអំពីការចោទប្រកាន់

ក្នុងករណីណាក៏ដោយ ការសម្រេចចោទប្រកាន់របស់ព្រះរាជអាជ្ញាត្រូវជូនដំណឹងភ្លាមដោយផ្ទាល់ និងជាលាយលក្ខណ៍អក្សរទៅអនីតិជន ហើយប្រសិនបើសមស្របត្រូវជូនដំណឹងតាមរយៈអ្នកតំណាងដែលច្បាប់បានកំណត់ ឬអ្នកទំនុកបម្រុង និងមេធាវីរបស់អនីតិជនដើម្បីរៀបចំមធ្យោបាយការពារអនីតិជន ។

១.២.២. ការបំបែកសំណុំរឿង

ដោយអនុលោមតាមមាត្រា ៣០ នៃច្បាប់ស្តីពីយុត្តិធម៌អនីតិជន បានបញ្ជាក្តីថា ប្រសិនបើព្រះរាជអាជ្ញាពិនិត្យសំណុំរឿងឃើញថា អំពើប្រព្រឹត្តនោះមានសហាការី អ្នកផ្តើមគំនិត ឬអ្នកសមគំនិតជា អនីតិជនផង និងជានីតិជនផង ព្រះរាជអាជ្ញាអាចសម្រេចចេញដីការបំបែកសំណុំរឿងរវាងអនីតិជន និងនីតិជនឲ្យដាច់ដោយឡែកពីគ្នា ។

ផ្នែកទី២ : ការស៊ើបសួរដោយចៅក្រមស៊ើបសួរចំពោះអនីតិជន

២.១. សមត្ថកិច្ចនៃការស៊ើបសួរ

ចៅក្រមស៊ើបសួរត្រូវលើកយករឿងក្តីរបស់អនីតិជនមកចាត់ការជាអាទិភាព ពិសេសរឿងក្តីដែលអនីតិជនកំពុងជាប់ឃុំបណ្តោះអាសន្ន ។

២.១.១. ការបើកការស៊ើបសួរ និងការបង្ហាញខ្លួនរបស់អនីតិជនពេលស៊ើបសួរ

បន្ទាប់ពីបានទទួលដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួររបស់តំណាងអយ្យការ ចៅក្រមស៊ើបសួរត្រូវបើកការស៊ើបសួរភ្លាម ។ ជនត្រូវចោទជាអនីតិជន ត្រូវមានមេធាវីអមជានិច្ចក្នុងអំឡុងពេលស្តាប់ចម្លើយនៅចំពោះមុខលក្ខខណ្ឌដែលចែងដោយច្បាប់ស្តីពីលក្ខន្តិក:មេធាវី ។ ចៅក្រមស៊ើបសួរវិញ ត្រូវទុកពេលវេលាសមស្របឲ្យមេធាវីអាចពិនិត្យមើលសំណុំរឿង និងពិភាក្សាជាមួយអនីតិជន មុនពេលចាប់ផ្តើមសួរចម្លើយ ។

នៅពេលអនីតិជនបង្ហាញខ្លួនលើកដំបូង ចៅក្រមស៊ើបសួរត្រូវពិនិត្យអត្តសញ្ញាណអនីតិជន ហើយប្រាប់អនីតិជនឲ្យបានដឹងអំពីរឿងរ៉ាវដែលចោទប្រកាន់ និងប្រាប់អំពីឈ្មោះបទល្មើសដែលបានកំណត់ដោយច្បាប់ ព្រមទាំងប្រាប់អំពីសិទ្ធិទាក់ទងនឹងដំណាក់កាលស៊ើបសួរ ។ ម្យ៉ាងវិញទៀតចៅក្រមស៊ើបសួរត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរទៅឪពុកម្តាយ ឬអាណាព្យាបាលរបស់អនីតិជន ឬអ្នកទំនុកបម្រុង និងភ្នាក់ងារសង្គមកិច្ចអំពីការដាក់ឲ្យស្ថិតនៅក្រោមការពិនិត្យ ។

២.១.២. ការស្តាប់ចម្លើយអនីតិជន

ចៅក្រមស៊ើបសួរត្រូវស្តាប់ចម្លើយអនីតិជនដោយផ្ទាល់ និងមានក្រឡាបញ្ជីជាជំនួយការ ។ ការស្តាប់ចម្លើយត្រូវធ្វើជាការសម្ងាត់ និងប្រើប្រាស់នីតិវិធីកុមារមេត្រី ។ ការស្តាប់ចម្លើយនេះត្រូវមានវត្តមានមេធាវីការពារ ឪពុកម្តាយ ឬអ្នកអាណាព្យាបាល ឬអ្នកទំនុកបម្រុងរបស់អនីតិជន និងភ្នាក់ងារសង្គមកិច្ច ។ ម្យ៉ាងវិញទៀត ចៅក្រមស៊ើបសួរអាចមិនអនុញ្ញាតឲ្យឪពុកម្តាយ ឬអាណាព្យាបាលអនីតិជនចូលរួមស្តាប់ចម្លើយបាន ប្រសិនបើវត្តមានអ្នកទាំងនោះផ្ទុយនឹងឧត្តមប្រយោជន៍របស់អនីតិជន ។ ការមិនអនុញ្ញាតនេះត្រូវមានការពិគ្រោះយោបល់ជាមួយមេធាវី ឬភ្នាក់ងារសង្គមកិច្ច និងអនីតិជន ។ ហើយចៅក្រមស៊ើបសួរត្រូវចុះនិទ្ទេសក្នុងកំណត់ហេតុស្តាប់ចម្លើយ ដោយបញ្ជាក់អំពីមូលហេតុក្នុងករណីអវត្តមានរបស់ឪពុកម្តាយ ឬអ្នកអាណាព្យាបាលអនីតិជន ឬអ្នកទំនុកបម្រុងអនីតិជន និងភ្នាក់ងារសង្គមកិច្ច។ បន្ទាប់ពីបញ្ចប់ការស្តាប់ចម្លើយភ្លាមអនីតិជន មានសិទ្ធិអានកំណត់ហេតុស្តាប់ចម្លើយបាន ។ ក្នុងករណីអនីតិជនមិនអាចអានកំណត់ហេតុស្តាប់ចម្លើយបាន ក្រឡាបញ្ជីត្រូវអានកំណត់ហេតុស្តាប់ចម្លើយឲ្យអនីតិជនស្តាប់ ។ អនីតិជនអាចសុំកែប្រែ ឬបន្ថែមបន្ថយចម្លើយលើកំណត់ហេតុស្តាប់ចម្លើយបាន មុននិងចុះហត្ថលេខា ឬផ្ទិតម្រាមដៃ ។ ចៅក្រមស៊ើបសួរត្រូវអនុញ្ញាតឲ្យមេធាវី ឬឪពុកម្តាយ ឬអ្នកអាណាព្យបាលអនីតិជន ឬអ្នកទំនុកបម្រុងអនីតិជន ឬភ្នាក់ងារសង្គមកិច្ចអាចអានកំណត់ហេតុស្តាប់ចម្លើយបាន ប្រសិនបើមានមានការស្នើសុំ ។ ក្នុងករណីដែលអនីតិជន ឬអ្នកចូលរួមណាមិនព្រមចុះហត្ថលេខាឬផ្ទិតម្រាមដៃលើកំណត់ហេតុ ចៅក្រមស៊ើបសួរត្រូវចុះនិទ្ទេសក្នុងកំណត់ហេតុស្តាប់ចម្លើយនោះ។ មួយវិញទៀតក្នុង

ករណីអវត្តមាន ចៅក្រមស៊ើបសួរត្រូវលើកពេលស្តាប់ចម្លើយ និងត្រូវកោះហៅមេធាវី ដើម្បីចូលរួមក្នុងការស្តាប់ចម្លើយ លើកលែងតែក្នុងករណីបន្ទាន់ដែលបណ្តាលមកពីគ្រោះថ្នាក់ដល់ស្លាប់ ឬបាត់បង់តម្រុយនៃភស្តុតាង ។ ប្រភេទនៃការបន្ទាន់ត្រូវចុះនិទ្ទេសនៅក្នុងកំណត់ហេតុ ។ ពិសេសវត្តមាន ឬអវត្តមានរបស់មេធាវី មិនរាំងចៅក្រមស៊ើបសួរក្នុងការសម្រេចអំពីការមិនឃុំខ្លួន ឬឃុំខ្លួនជាបណ្តោះអាសន្នឡើយ ។

២.១.៣. ការព្យួរការសិក្សា និងការងារសម្រាប់អនីតិជន

ចៅក្រមស៊ើបសួរអាចបង្គាប់ទៅគ្រឹះស្ថានសិក្សា ឬនិយោជក មិនឲ្យព្យួរការសិក្សា ឬការព្យួរការងាររបស់អនីតិជន ប្រសិនបើអនីតិជនមិនត្រូវបានឃុំខ្លួនបណ្តោះអាសន្នទេ។ ក្នុងករណីអនីតិជនត្រូវបានឃុំខ្លួនបណ្តោះអាសន្ន ឬត្រូវអនុវត្តផែនការបង្វែរគ្រឹះស្ថាន ឬនិយោជកអាចព្យួរការងារ ឬព្យួរការងាររហូតដល់មានសេចក្តីសម្រេចតុលាការជាស្ថាពរ។ ក្នុងករណីតុលាការសម្រេចសេចក្តីថាគ្មានទោសទេ នោះគ្រឹះស្ថានសិក្សា ឬនិយោជកត្រូវអនុញ្ញាតឲ្យអនីតិជនចូលសិក្សា ឬធ្វើការជាធម្មតាឡើងវិញ ។

២.២. អំណាចរបស់ចៅក្រមស៊ើបសួរ

២.២.១. អំណាចក្នុងការបង្វែរ

នៅពេលបានទទួលដីកាសន្និដ្ឋានបញ្ជូនឲ្យស៊ើបសួរ ហើយអនីតិជនដែលមានអាយុពី១៤(ដប់បួន) ឆ្នាំដល់ក្រោម ១៨(ដប់ប្រាំបី)ឆ្នាំ ដែលតំណាងអង្គការអយ្យការចោទប្រកាន់ថាបានប្រព្រឹត្តបទលហុ ឬបទមជ្ឈិម ចៅក្រមស៊ើបសួរត្រូវគិតជាបឋមពីការបង្វែរ ពិចារណាលើរបាយការណ៍ស្តីពីការប៉ាន់ប្រមាណស្ថានភាពអនីតិជន និង ត្រូវពិនិត្យលើលក្ខខណ្ឌអប្បបរមានៃការបង្វែរ ។

រាល់បទមជ្ឈិមដែលមានស្ថានទម្ងន់ ដូចមានចែងនៅក្រមព្រហ្មទណ្ឌ ចៅក្រមស៊ើបសួរអាចពិចារណាពីការបង្វែរបាន បើមានលក្ខខណ្ឌទាំងបីដូចខាងក្រោម ៖

១. ភាពចលាចលដល់សណ្តាប់ធ្នាប់សាធារណៈដែលបណ្តាលមកពីបទល្មើស បានបញ្ចប់

២. ការខូចខាតត្រូវបានជួសជួល

៣. អនីតិជនជាប់ចោទបានបង្ហាញការធានាក្នុងការចូលទៅរួមរស់ទៅក្នុងសង្គមវិញ[26] ។

ក្នុងករណីដែលបានបំពេញបានគ្រប់គ្រាន់នូវលក្ខខណ្ឌអប្បបរមានៃការបង្វែរ ចៅក្រមស៊ើបសួរមុននឹងសម្រេចចិត្តធ្វើការបង្វែរ ឬមិនបង្វែរត្រូវពិចារណាលក្ខណៈវិនិច្ឆ័យសម្រាប់ធ្វើការ

[26] សៀវភៅសារណា នីតិវិធីសម្រាប់យុត្តិធម៌អនីតិជនទំនាស់នឹងច្បាប់ រៀបរៀងដោយ (ឈឹន មុន្នី និងហ្ជត ថាវរិត) ឆ្នាំ ២០១២ (ទំព័រ៣៥)

បង្ហែ។ នៅពេលដែលយល់ឃើញថាត្រូវបង្ហែ ចៅក្រមស៊ើបសួរត្រូវផ្អាកនីតិវិធីនៃការស៊ើបសួរ ដោយដោយដីកាសម្រេច និងបង្គាប់ឲ្យដោះលែងអនីតិជនដែលបានឃុំខ្លួន ប្រសិនបើអនីតិជននោះត្រូវបានឃុំខ្លួនបណ្តោះអាសន្ន។ ចៅក្រមស៊ើបសួរអាចបង្គាប់ឲ្យប្រគល់អនីតិជននោះទៅឲ្យឪពុកម្តាយ ឬអ្នកអាណាព្យាបាល ឬមន្ទីរទទួលបន្ទុកបរិស័យសង្គមកិច្ចរាជធានី ខេត្ត ដើម្បីទទួលបានការគ្រប់គ្រងនិងថែទាំ ដើម្បីរង់ចាំអនុវត្តផែនការបង្ហែ ទោះបីផែនការបង្ហែត្រូវការពេលវេលារៀបចំក៏ដោយ ។

ចៅក្រមស៊ើបសួរត្រូវជូនដំណឹងដល់ជនរងគ្រោះ ឬអ្នកតំណាងស្របច្បាប់របស់ជនរងគ្រោះ ក្នុងករណីជនរងគ្រោះជាអនីតិជននិងមេធាវីរបស់អនីតិជនអំពីការសម្រេចផ្អាកនីតិវិធីនៃការស៊ើបសួរ។ ជនរងគ្រោះ ឬអ្នកតំណាងស្របច្បាប់របស់ជនរងគ្រោះ អាចប្តឹងទាមទារសំណងទៅតុលាការរដ្ឋប្បវេណី។ ចៅក្រមស៊ើបសួរត្រូវចេញដីកាដំណោះស្រាយលើកលែងចោទប្រកាន់ ក្នុងករណីដែលការអនុវត្តផែនការបង្ហែរទទួលបានជោគជ័យ ដោយផ្អែកលើលទ្ធផលរបាយការណ៍ដែលបានបញ្ជាក់រួមគ្នាពីភ្នាក់ងារសង្គមកិច្ច និងអ្នកទទួលបន្ទុកអអនុវត្តផែនការបង្ហែ ។ ក្នុងករណីដែលអនីតិជនអនុវត្តផែនការបង្ហែរមិនបានជោគជ័យ ចៅក្រមស៊ើបសួរអាចចេញដីកាសម្រេចបង្ហែរជាថ្មីដោយពិចារណាទៅលើមូលហេតុដែលនាំឲ្យបរាជ័យក្នុងការអនុវត្តផែនការបង្ហែរទស្សនៈ:របស់អនីតិជន អ្នកតំណាងដែលច្បាប់បានកំណត់ និងពិគ្រោះយោបល់ជាមួយភ្នាក់ងារសង្គមកិច្ច ឬចាត់វិធានការតាមនីតិវិធី ។

២.២.២. អំណាចក្នុងការឃុំខ្លួនបណ្តោះអាសន្ន

ការឃុំខ្លួនអនីតិជនបណ្តោះអាសន្ន ជាវិធានការចុងក្រោយ ។ បន្ថែមលើបទប្បញ្ញត្តិស្តីពីលក្ខខណ្ឌ មូលហេតុនៃការឃុំខ្លួនបណ្តោះអាសន្ន ដែលមានចែងនៅក្នុងក្រមនីតិវិធីព្រហ្មទណ្ឌ ចៅក្រមស៊ើបសួរមុននឹងសម្រេចអំពីការឃុំខ្លួនបណ្តោះអាសន្ន ត្រូវពិចារណាលើរបាយការណ៍ប៉ាន់ប្រមាណសុខុមាលភាព និងស្ថានភាពសង្គមរបស់អនីតិជនផងដែលប្រសិនបើមាន។ ចៅក្រមស៊ើបសួរអាចអនុវត្តការឃុំខ្លួនអនីតិជនបណ្តោះអាសន្នបាន តែក្នុងករណីចោទប្រកាន់ពីបទឧក្រិដ្ឋ ឬបទមជ្ឈិមដែលច្បាប់កំណត់ផ្តន្ទាទោសដាក់ពន្ធនាគារស្មើ ឬលើសពី ១(មួយ)ឆ្នាំ ។ មុននឹងសម្រេចឃុំខ្លួនអនីតិជនបណ្តោះអាសន្ន ចៅក្រមស៊ើបសួរត្រូវពនិត្យលើមូលហេតុ នៃការឃុំខ្លួនបណ្តោះអាសន្ន[27]។ អនីតិជនអាយុក្រោម ១៤(ដប់បួន) ឆ្នាំមិនបានឃុំខ្លួនបណ្តោះអាសន្នឡើយ ។ ក្នុងករណីអនីតិជនដែលកំពុងជាប់ឃុំត្រូវបានរកឃើញថាមានអាយុក្រោម ១៤(ដប់បួន)ឆ្នាំ ចៅក្រមស៊ើបសួរត្រូវចេញដីកាដំណោះស្រាយលើកលែងចោទប្រកាន់ និងបង្គាប់ឲ្យដោះលែងអនីតិជន

[27] មាត្រា ២០៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០១០

នោះជាបន្ទាន់ ទោះបីមានបណ្តឹងឧទ្ធរណ៍របស់ព្រះរាជអាជ្ញា ក៏ដោយហើយប្រគល់អនីតិជននោះទៅឪពុកម្តាយ អ្នកអាណាព្យាបាលសម្រាប់អនីតិជន។

ក្នុងករណីដែលអនីតិជនត្រូវការកិច្ចការពារ និងថែទាំចៅក្រមស៊ើបសួរត្រូវបញ្ជូនអនីតិជននោះទៅមន្ទីរទទួលបន្ទុកវិស័យសង្គមកិច្ចរាជធានី ខេត្ត ដើម្បីចាត់វិធានការសមស្របទៅតាមសុខុមាលភាព និងស្ថានភាពសង្គមរបស់អនីតិជន។ ក្នុងករណីយល់ឃើញថាអនីតិជនត្រូវការកិច្ចការពារ និងថែទាំនោះមន្ទីរ ឬការិយាល័យត្រូវចាត់វិធានការស្នើសុំព្យួរ ឬសុំដកហូតអំណាចមេបា ឬបញ្ឈប់អ្នកអាណាព្យាបាលសម្រាប់អនីតិជន ឬអ្នកអាណាព្យាបាលសម្រាប់អនីតិជន ឬអ្នកអាណាព្យាបាលទូទៅ ក្នុងករណីដែលអនីតិជនមានអ្នកតំណាងដែលច្បាប់បានកំណត់ ដើម្បីតុលាការសម្រេចអំពីការព្យួរ ឬការដកហូត ឬការបញ្ឈប់អ្នកតំណាងដែលបានកំណត់ និងសិទ្ធិអាណាព្យាបាលលើអនីតិជននោះ ។ ក្នុងករណីដែលអនីតិជនគ្មានឪពុកម្តាយ ឬអ្នកអាណាព្យាបាល មន្ទីរ ឬការិយាល័យត្រូវសុំទៅតុលាការដើម្បីសម្រេច អំពីសិទ្ធិអាណាព្យាបាលលើអនីតិជននោះ ។ ជនរងគ្រោះ ឬអ្នកតំណាងស្របច្បាប់ អាចដាក់ពាក្យប្តឹងទាមទារសំណងទៅតុលាការរដ្ឋប្បវេណីបាន។

២.២.៣. អំណាចក្នុងការដាក់ឲ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ

ចៅក្រមស៊ើបសួរអាចដាក់អនីតិជនត្រូវចោទប្រកាន់ ឲ្យនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការបានគ្រប់ពេលវេលាជំនួសឲ្យការឃុំខ្លួនបណ្តោះអាសន្ន ប្រសិនបើអនីតិជនត្រូវចោទនោះត្រូវបានចោទប្រកាន់អំពីបទល្មើសដែលត្រូវផ្តន្ទាទោសដាក់ពន្ធនាគារ ។ បន្ថែមលើបទប្បញ្ញត្តិស្តីពីការត្រួតពិនិត្យតាមផ្លូវតុលាការនៃក្រមនីតិវិធីព្រហ្មទណ្ឌ ចៅក្រមស៊ើបសួរអាចបង្គាប់អនីតិជនដែលនៅក្រៅឃុំឲ្យគោរពកាតព្វកិច្ចមួយ ឬច្រើនដូចជា[28] ៖

- ដាក់អនីតិជនឲ្យស្ថិតនៅក្រោមការគ្រប់គ្រងផ្ទាល់ពីឪពុកម្តាយ អ្នកអាណាព្យាបាលសម្រាប់អនីតិជន ឬអ្នកអាណាព្យាបាលទូទៅ ឬអ្នកទំនុកបម្រុងរបស់អនីតិជន ឬក្រុមគ្រួសារណាមួយសមស្រប
- ដាក់អនីតិជនឲ្យស្ថិតនៅក្រោមការគ្រប់គ្រង និងការថែទាំនៅក្នុងមណ្ឌលណាមួយរបស់រដ្ឋ ឬមណ្ឌលណាមួយរបស់អង្គការមិនមែនរដ្ឋាភិបាលដែលមាននីតិសម្បទាទទួល និងថែទាំអនីតិជន
- បង្គាប់មិនឲ្យអនីតិជនចេញដើរហួសម៉ោងកំណត់ ឬសេពគ្រឿងស្រវឹង
- បង្គាប់ឲ្យអនីតិជនមិនត្រូវផ្លាស់ប្តូរលំនៅឋានដោយគ្មានការអនុញ្ញាតពី ចៅក្រមស៊ើបសួរឡើយ

[28] មាត្រា ៤០ នៃច្បាប់ស្តីពីយុត្តិធម៌អនីតិជន ឆ្នាំ២០១៦

- បង្គាប់ឲ្យអនីតិជនមិនត្រូវទៅកាន់ទីកន្លែងខ្លះដែលកំណត់ដោយយោងតាមក្រមស៊ើបសួរ
- បង្គាប់ឲ្យអនីតិជនត្រូវចូលបង្ហាញខ្លួនតាមការកំណត់នៅអង្គភាពនគរបាល ឬកងរាជអាវុធហត្ថ ដែលចាត់តាំងដោយយោងតាមក្រមស៊ើបសួរ
- បង្គាប់ឲ្យអនីតិជនត្រូវឆ្លើយតប នឹងការកោះហៅពីគ្រប់បុគ្គលដែលចាត់តាំងដោយយោងតាមក្រមស៊ើបសួរ
- បង្គាប់ឲ្យអនីតិជនប្រគល់គ្រប់ឯកសារបញ្ជាក់ អំពីអត្តសញ្ញាណជូនដល់ការិយាល័យក្រឡាបញ្ជី
- បង្គាប់ឲ្យអនីតិជនមិនត្រូវបើកបរយានយន្ត
- បង្គាប់ឲ្យអនីតិជនមិនត្រូវទទួល ឬជួបបុគ្គលដែលចង្អុលបង្ហាញដោយយោងតាមក្រមស៊ើបសួរឡើយ
- បង្គាប់ឲ្យអនីតិជនមិនត្រូវកាន់កាប់ ឬយកអាវុធគ្រប់ប្រភេទតាមខ្លួន
- បង្គាប់ឲ្យអនីតិជនមិនត្រូវធ្វើសកម្មភាពខាងវិជ្ជាជីវៈខ្លះ ។ ឬ
- ដាក់វិធានការផ្សេងៗទៀតដែលតុលាការយល់ឃើញថាសមស្រប ។

ប្រសិនបើអនីតិជនគេចវេសដោយចេតនាពីកាតព្វកិច្ចត្រួតពិនិត្យតាមផ្លូវតុលាការ យោងតាមក្រមស៊ើបសួរអាចសម្រេចឃុំខ្លួនអនីតិជននោះបណ្តោះអាសន្នបាន ដោយអនុលោមតាមក្រមនីតិវិធីព្រហ្មទណ្ឌ។

យោងតាមក្រមស៊ើបសួរអាចបង្គាប់ ឲ្យដោះលែងអនីតិជនឲ្យនៅក្រៅឃុំជាបណ្តោះអាសន្នបានគ្រប់ពេលវេលា ដោយគំនិតផ្ទួចផ្តើមខ្លួនឯង ឬតាមការស្នើសុំរបស់ព្រះរាជអាជ្ញា ឬតាមពាក្យសុំរបស់អនីតិជនត្រូវចោទ ឬរបស់ឪពុកម្តាយ ឬអ្នកអាណាព្យាបាល ឬរបស់មេធាវី ដោយមានការយល់ព្រមពីអនីតិជន យោងតាមក្រមស៊ើបសួរត្រូវសម្រេចក្នុងរយៈពេល ៥(ប្រាំ)ថ្ងៃ គិតពីថ្ងៃទទួលបានពាក្យសុំ ។ អនីតិជនត្រូវចោទអាចដាក់ពាក្យសុំឲ្យនៅក្រៅឃុំសារជាថ្មីម្តងទៀត ទៅយោងតាមក្រមស៊ើបសួរ ឬសភាស៊ើបសួរក្នុងរយៈពេល ១៥(ដប់ប្រាំ)ថ្ងៃ បន្ទាប់ពីមានសេចក្តីសម្រេចបដិសេធសេចក្តីសម្រេចលើកមុន ។

២.២.៤. ថ្នាក់ពេលនៃការឃុំខ្លួនបណ្តោះអាសន្ន

ការឃុំខ្លួនបណ្តោះអាសន្នទាក់ទង នឹងអនីតិជនដែលមានអាយុចាប់ពី ១៤(ដប់បួន) ឆ្នាំ ដល់ក្រោម ១៨(ដប់ប្រាំបី)ឆ្នាំ ត្រូវធ្វើឡើងក្នុងរយៈពេលសមស្រប និងខ្លីបំផុតដោយអនុលោមតាមនីតិវិធីព្រហ្មទណ្ឌ[29] ។ ត្រង់ចំណុចនេះប្រធានមណ្ឌលស្តារនីតិសម្បទាជាអ្នកទទួលខុសត្រូវក្នុងការ

[29] មាត្រា ២១៣ និងមាត្រា២១៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌ

អនុវត្ត មិនឲ្យមានការឃុំខ្លួនអនីតិជនលើសរយៈពេលដែលច្បាប់កំណត់ឡើយ ។ បើក្នុងករណីរកឃើញថាអនីតិជនត្រូវបានឃុំខ្លួនលើសច្បាប់កំណត់ ឬផ្ទុយនឹងបទបញ្ញាត្តិខាងលើ ប្រធានមណ្ឌលស្ថានីតិសម្បទាត្រូវរាយការណ៍ជាបន្ទាន់ជូនព្រះរាជអាជ្ញាអមសាលាដំបូងដើម្បីចាត់ការ ។

២.៣. ដីកាដំណោះស្រាយរបស់ចៅក្រមស៊ើបសួរ

មុននឹងចេញដីកាដំណោះស្រាយ ចៅក្រមស៊ើបសួរត្រូវពិនិត្យ និងពិចារណាលើរបាយការណ៍ស្តីពីការប៉ាន់ប្រមាណសុខុមាលភាព និងស្ថានភាពសង្គមរបស់អនីតិជន។ ក្នុងករណីរបាយការណ៍ស្តីពីការប៉ាន់ប្រមាណសុខុមាលភាព និងស្ថានភាពសង្គមរបស់អនីតិជនមិនទាន់មានលក្ខណៈគ្រប់គ្រាន់ចៅក្រមស៊ើបសួរត្រូវបង្គាប់ឲ្យភ្នាក់ងារសង្គមកិច្ច ផ្តល់របាយការណ៍បន្ថែមក្នុងរយៈពេលឆាប់បំផុតដែលអាចធ្វើទៅបាន ដោយមិនឲ្យលើសរយៈពេល ១០(ដប់)ថ្ងៃនៃការធ្វើការ ។

ចៅក្រមស៊ើបសួរចេញដីកាលើកលែងចោទប្រកាន់ក្នុងករណីដូចខាងក្រោម ៖

- អំពើប្រព្រឹត្តមិនមែនជាបទឧក្រិដ្ឋ បទមជ្ឈិម ឬបទលហុ
- អនីតិជនដែលបានប្រព្រឹត្តអំពើនោះនៅតែគេមិនស្គាល់
- គ្មានភស្តុតាងដាក់បន្ទុកគ្រប់គ្រាន់លើអនីតិជនត្រូវចោទ

ដីកាដំណោះស្រាយលើកលែចោទប្រកាន់ មានអានុភាពនាំឲ្យដោះលែងអនីតិជនដែលជាប់ឃុំ ទោះបីមានបណ្តឹងឧទ្ធរណ៍របស់ព្រះរាជអាជ្ញាក៏ដោយ[30] ។ ចៅក្រមស៊ើបសួរត្រូវបង្គាប់ឲ្យប្រគល់អនីតិជនទៅឲ្យឪពុកម្តាយ ឬអ្នកអាណាព្យាបាល ។ ក្នុងករណីដែលអនីតិជនត្រូវការកិច្ចការពារ និងថែទាំចៅក្រមស៊ើបសួរត្រូវបញ្ជូនអនីតិជននោះទៅមន្ទីរទទួលបន្ទុកវិស័យសង្គមកិច្ចរាជធានី ខេត្តដើម្បីចាត់វិធានការសមស្របទៅតាមសុខុមាលភាព និងស្ថានភាពសង្គមរបស់អនីតិជន។

ក្នុងករណីយល់ឃើញថា អនីតិជនត្រូវការកិច្ចការពារ និងថែទាំនោះមន្ទីរ ឬការិយាល័យត្រូវចាត់វិធានការស្នើសុំព្យួរ ឬសុំដកហូតអំណាចមេបា ឬបញ្ឈប់អ្នកអាណាព្យាបាលសម្រាប់អនីតិជន ឬអ្នកអាណាព្យាបាលទូទៅ ក្នុងករណីអនីតិជនមានអ្នកតំណាងដែលច្បាប់បានកំណត់ដើម្បីតុលាការសម្រេចអំពីការព្យួរ ឬការដកហូត ឬបញ្ឈប់អ្នកតំណាងដែលច្បាប់បានកំណត់ និងសិទ្ធិអាណាព្យាបាលលើអនីតិជននោះ ។ បើករណីអនីតិជនគ្មានអ្នកតំណាងដែលច្បាប់បានកំណត់ មន្ទីរ ឬការិយាល័យ ត្រូវសុំទៅតុលាការដើម្បីសម្រេចអំពីសិទ្ធិអាណាព្យាបាលលើអនីតិជននោះ ។

២.៤. ការប្តឹងទៅសភាស៊ើបសួរ និងការបញ្ជូនរឿងទៅសភាស៊ើបសួរនៃសាលាឧទ្ធរណ៍

មុននឹងសម្រេចប្តឹងទៅសភាសស៊ើបសួរ នៃសាលាឧទ្ធរណ៍ចំពោះដីកាលើកលែងចោទប្រកាន់ ដីកាសម្រេចឃុំខ្លួន ដីកាសម្រេចមិនឃុំខ្លួន ដីកាដោះលែងឲ្យនៅក្រៅឃុំ និងដីកាបង្ខែ

[30] មាត្រា៤២ កថាខណ្ឌទី២ នៃច្បាប់ស្តីពីយុត្តិធម៌អនីតិជន ឆ្នាំ២០១៦

របស់ចៅក្រមស៊ើបសួរ ព្រះរាជអាជ្ញាត្រូវពិចារណាជាចម្បងអំពីឧត្តមប្រយោជន៍របស់អនីតិជន ។

ការណាមានបណ្តឹងឧទ្ធរណ៍ ក្រឡាបញ្ជីនៃចៅក្រមស៊ើបសួរ ត្រូវរៀបចំបែបបទបញ្ជូនសំណុំរឿងទៅសភាស៊ើបសួរនៅក្នុងរយៈពេល ៥(ប្រាំ)ថ្ងៃ បន្ទាប់ពីបានទទួលបណ្តឹងឧទ្ធរណ៍ លើកលែងតែក្នុងកាលៈទេសៈដែលមិនអាចជំនះបាន ។ ចំពោះបែបបទ និងនីតិវិធីនៃបណ្តឹងឧទ្ធរណ៍ចំពោះដីកាសម្រេចរបស់ចៅក្រមស៊ើបសួរ ដែលមិនមានចែងក្នុងច្បាប់ស្តីយុត្តិធម៌អនីតិជនទេ ត្រូវអនុវត្តតាមក្រមនីតិវិធីព្រហ្មទណ្ឌ ។

ផ្នែកទី៣ : ការជំនុំជម្រះចំពោះអនីតិជនរបស់សាលាដំបូង

៣.១. សមត្ថកិច្ចនៃការជំនុំជម្រះរឿងក្តីអនីតិជននៃសាលាដំបូងរាជធានី ខេត្ត

៣.១.១. សមត្ថកិច្ចនៃការជំនុំជម្រះ

ការជំនុំជម្រះករណីទាំងឡាយដែលពាក់ព័ន្ធនឹងអនីតិជនល្មើសនឹងច្បាប់ ជាសមត្ថកិច្ចរបស់តុលាការជំនុំជម្រះក្តីនៃសាលាដំបូងរាជធានី ខេត្ត ដែលមានសមត្ថកិច្ចជំនាញទាក់ទងនឹងអនីតិជនជំនុំជម្រះបទឧក្រិដ្ឋ បទមជ្ឈិម និងបទលហុដែលមានជនជាប់ចោទជាអនីតិជន ។ ចំពោះសមត្ថកិច្ចជំនុំជម្រះលើរឿងក្តីអនីតិជន ត្រូវមានសមូហភាពដោយមានចៅក្រម ៣(បី)រូប ចំពោះបទឧក្រិដ្ឋ ព្រមទាំងបទមជ្ឈិម និងបទលហុដែលជាប់ទាក់ទងនឹងបទឧក្រិដ្ឋ និងបទមជ្ឈិម ។ ចំពោះការជំនុំជម្រះបទលហុ ចំពោះរឿងក្តី អនីតិជន គឺមានតែចៅក្រមម្នាក់ដែលធ្វើការសម្រេចសេចក្តី ។

៣.១.២. ការផ្តល់អាទិភាពលើរឿងក្តីអនីតិជន

តុលាការត្រូវលើកយករឿងក្តីរបស់អនីតិជនមកចាត់ការជាអាទិភាព ជាពិសេសរឿងក្តីអនីតិជនដែលកំពុងជាប់ឃុំខ្លួនបណ្តោះអាសន្ន[31] ។ ដើម្បីជាឧត្តមប្រយោជន៍របស់អនីតិជនក្នុងពេលរង់ចាំការជំនុំជម្រះតុលាការត្រូវពិនិត្យពិចារណា ដោះលែងអនីតិជនដែលជាប់ឃុំបណ្តោះអាសន្នឲ្យមានសេរីភាព ។ ក្នុងករណីដែលរឿងក្តីត្រូវបានលើកពេលជំនុំជម្រះ តុលាការត្រូវពិចារណាផងដែរ អំពីការដោះលែងអនីតិជនដែលជាប់ឃុំបណ្តោះអាសន្នឲ្យមានសេរីភាព ។

៣.១.៣. សវនាការជាអសាធារណៈ

ការពិភាក្សាដេញដោល និងការប្រកាសសាលក្រមរឿងក្តីអនីតិជន ត្រូវធ្វើឡើងក្នុងសវនាការជាអសាធារណៈ ។ មានតែបុគ្គលដែលមានសិទ្ធិ កាតព្វកិច្ច ឬផលប្រយោជន៍ដែលពាក់ព័ន្ធនឹងរឿងក្តីប៉ុណ្ណោះដែលមានសិទ្ធិចូលរួមក្នុងសវនាការ រួមមានអនីតិជនដែលបានប្រព្រឹត្តបទល្មើសជនរងគ្រោះ និងមេធាវី ព្រមទាំងភ្នាក់ងារសង្គមកិច្ច ។ ចំណែកឯឪពុកម្តាយ ឬអ្នកអាណាព្យាបាល ឬអ្នកទំនុកបម្រុងរបស់អនីតិជន អាចអនុញ្ញាតឲ្យចូលរួមក្នុងសវនាការបាន លើកលែងតែមាន

[31] មាត្រា ៤៥ កថាខណ្ឌទី១ នៃច្បាប់ស្តីពីយុត្តិធម៌អនីតិជន ឆ្នាំ២០១៦

សំណូមពរពីអនីតិជនផ្ទុយពីនោះ ឬតុលាការយល់ឃើញថាការចូលរួមរបស់បុគ្គលទាំងនោះ មិនបម្រើឧត្តមប្រយោជន៍របស់អនីតិជន ។

៣.១.៤. ពេលសវនាការ

នៅក្នុងពេលសវនាការ តុលាការត្រូវរៀបចំឲ្យមានលក្ខណៈនីតិវិធីកុមារមេត្រី ។ ក្នុងកាលៈទេសៈពិសេសមេធាវីរបស់អនីតិជន បុគ្គលិកសង្គមកិច្ច ឬព្រះរាជអាជ្ញាអាចស្នើសុំឲ្យតុលាការប្រើប្រាស់របាំងក្នុងពេលសវនាការ ឬប្រើប្រាស់វិធីសមស្របណាមួយក្នុងការផ្តល់ចម្លើយ ។ ហើយមុនពេលសវនាការ តុលាការត្រូវពិនិត្យរបាយការណ៍ និងយោបល់ស្តីពីការប៉ាន់ប្រមាណសុខុមាលភាព និងស្ថានភាពសង្គមរបស់អនីតិជន ដែលផ្តល់ដោយភ្នាក់ងារសង្គមកិច្ច ។ ក្នុងករណីដែលរបាយការណ៍ និងយោបល់ស្តីពីការប៉ាន់ប្រមាណសុខុមាលភាព និងស្ថានភាពសង្គមរបស់អនីតិជនមិនទាន់បានរៀបចំ ហើយតុលាការត្រូវការព័ត៌មានបន្ថែម តុលាការត្រូវបង្គាប់ឲ្យភ្នាក់ងារសង្គមកិច្ចរៀបចំ និងបំពេញបន្ថែមនូវរបាយការណ៍ និងយោបល់នោះតាមតម្រូវការ ។

៣.១.៥. ការផ្សះផ្ទុតពីបទចោទ

បើក្នុងករណីតុលាការរកឃើញថា អនីតិជនជាប់ចោទមានអាយុក្រោម ១៤(ដប់បួន)ឆ្នាំ នៅពេលប្រព្រឹត្តបទល្មើស តុលាការត្រូវសម្រេចឲ្យអនីតិជនរួចផុតពីបទចោទប្រកាន់ ហើយបង្គាប់ឲ្យដោះលែងអនីតិជនដែលជាប់ឃុំជាបន្ទាន់ ទោះបីមានបណ្តឹងឧទ្ធរណ៍ពីព្រះរាជអាជ្ញាក៏ដោយ ហើយប្រគល់ អនីតិជននោះឲ្យទៅឪពុកម្តាយ ឬអ្នកអាណាព្យាបាល ឬអ្នកទំនុកនបម្រុងរបស់អនីតិជន ។

ប្រសិនបើក្នុងករណីតុលាការរកឃើញថា អនីតិជននោះពិតជាបានប្រព្រឹត្តបទល្មើស តុលាការត្រូវសម្រេចអំពីសំណងរដ្ឋប្បវេណី ប្រសិនបើមានបណ្តឹងរដ្ឋប្បវេណី ។ មួយវិញទៀតបើតុលាការរកឃើញថា អំពើដែលចោទប្រកាន់មកលើអនីតិជនដែលមានអាយុចាប់ពី ១៤(ដប់បួន)ឆ្នាំ ដល់ក្រោម ១៨(ដប់ប្រាំបី)ឆ្នាំ មិនមែនជាបទល្មើស ឬអនីតិជនជាប់ចោទគ្មានកំហុសទេ តុលាការត្រូវសម្រេចឲ្យរួចខ្លួនពីបទចោទ និងបង្គាប់ឲ្យដោះលែងអនីតិជននោះភ្លាម ទោះបីមានបណ្តឹងឧទ្ធរណ៍ពីព្រះរាជអាជ្ញាក៏ដោយ ហើយប្រគល់អនីតិជននោះឲ្យទៅឪពុកម្តាយ ឬអ្នកអាណាព្យាបាល ប្រសិនបើអនីតិជននោះមិនត្រូវបានជាប់ឃុំពីបទល្មើសផ្សេងទៀតទេ ។ ហើយគ្រប់ករណីទាំងអស់បើអនីតិជនត្រូវការកិច្ចការពារ និងថែទាំនោះតុលាការសម្រេចបញ្ជូនអនីតិជននោះទៅមន្ទីរទទួលបន្ទុកវិស័យសង្គមកិច្ចរាជធានី ខេត្ត ដើម្បីចាត់វិធានការសមស្របទៅតាមសុខុមាលភាព និងស្ថានភាពសង្គមរបស់អនីតិជន។ ក្នុងករណីយល់ឃើញថាអនីតិជនត្រូវការកិច្ចការ និងថែទាំ នោះមន្ទីរ ឬការិយាល័យត្រូវចាត់វិធានការស្នើសុំព្យួរ ឬសុំដកហូតអំណាចមេបា ឬ

បញ្ឈប់អ្នកអាណាព្យាបាលសម្រាប់អនីតិជន ឬអ្នកអាណាព្យាបាលទូទៅ ក្នុងករណីដែលអនីតិជនមានអ្នកតំណាងដែលច្បាប់កំណត់និងសិទ្ធិអាណាព្យាបាលលើអនីតិជននោះ។ ក្នុងករណីដែលអនីតិជនគ្មានអ្នកតំណាងដែលច្បាប់បានកំណត់ មន្ទីរ ឬការិយាល័យត្រូវសុំ ទៅតុលាការដើម្បីសម្រេចអំពីសិទ្ធិអាណាព្យាបាលលើអនីតិជននោះ ។

៣.២. ជំនួយរបស់មេធាវី

ជំនួយរបស់មេធាវីត្រូវតែមានដាច់ខាតនៅក្នុងសវនាការ ។ បើគ្មានការជ្រើសរើសដោយអនីតិជនមេធាវីត្រូវបានចាត់តាំងដោយមិនយកកម្រៃ តាមគំនិតផ្តើមរបស់ប្រធានតុលាការ នៅក្នុងលក្ខខណ្ឌដែលមានចែងនៅក្នុងច្បាប់ស្តីពីលក្ខន្តិក:មេធាវី ។ សោហ៊ុយសម្រាប់ធ្វើការ ចម្លងសំណុំរឿងជាបន្ទុករបស់រដ្ឋ ។ តុលាការត្រូវផ្តល់ពេលវេលាសមស្រប និងលិខិតចម្លងសំណុំរឿងទៅឲ្យមេធាវីសម្រាប់រៀបចំការការពារ ។ សោហ៊ុយសម្រាប់ធ្វើការចម្លងសំណុំរឿងជាបន្ទុករបស់មេធាវីដែលត្រូវបានជ្រើសរើសដោយអនីតិជន ។

៣.៣. ការផ្តល់ព័ត៌មានអំពីសិទ្ធិដល់អនីតិជនដោយតុលាការ

នៅពេលចាប់ផ្តើមសវនាការ តុលាការត្រូវប្រាប់អនីតិជនដោយប្រើប្រាស់ភាសាដែលអនីតិជនអាចយល់បាន អំពីសិទ្ធិដូចខាងក្រោម ៖

- សិទ្ធិបានដឹងអំពើដែលបានចោទប្រកាន់
- សិទ្ធិមានមេធាវីការពារ
- សិទ្ធិមានអ្នកបកប្រែភាសាមិនគិតកម្រៃ
- សិទ្ធិមានវត្តមាននៅពេលជំនុំជម្រះក្តី
- សិទ្ធិទទួលបានការការពារពីតុលាការនូវទង្វើមិនគប្បី ឬការសួរដេញដោលមិនសមរម្ស
- សិទ្ធិបង្ហាញភស្តុតាង សិទ្ធិសុំសួរសាក្សី និងសិទ្ធិសុំកោះហៅសាក្សី
- សិទ្ធិប្តឹងដិតចិត្តចៅក្រមជំនុំជម្រះក្តី
- សិទ្ធិធ្វើសំណូមពរចុងក្រោយ និង
- សិទ្ធិប្តឹងឧទ្ធរណ៍ ។

៣.៤. ការឆ្លើយសារភាពរបស់អនីតិជននៅពេលសវនាការ

តុលាការត្រូវពិនិត្យ ថ្លឹងថ្លែង និងបញ្ជាក់ថាចម្លើយសារភាពទទួលយកពិរុទ្ធភាពរបស់អនីតិជននៅពេលសវនាការ ត្រូវបានធ្វើឡើងដោយស្ម័គ្រចិត្ត គ្មានការគំរាមកំហែង ឬបង្ខិតបង្ខំ និងយល់បានអំពីផលវិបាកនៃការសារភាពនេះ។ ចម្លើយសារភាពដែលបានមកពីការគំរាមកំហែង បង្ខិតបង្ខំ ឬ ការមិនយល់ដឹងអំពីផលវិបាកនៃការសារភាពមិនត្រូវចាត់ទុកជាភស្តុតាងនៃពិរុទ្ធភាព

ឡើយ ។

ការសារភាពទទួលយកផែនការបង្ខូរ មិនត្រូវចាត់ទុកជាភស្តុតាងសម្រាប់ពិរុទ្ធភាព ក្នុងបទល្មើសដដែល សម្រាប់នីតិវិធីព្រហ្មទណ្ឌបន្តបន្ទាប់នោះឡើយ ។ ក្នុងពេលសវនាការតុលាការត្រូវផ្ទៀងផ្ទាត់ពីភាពស៊ីចង្វាក់នៃចម្លើយសារភាព និងភស្តុតាងផ្សេងទៀតនៃបទល្មើស ។

៣.៥. ការប្រកាសសាលក្រម

សាលក្រមត្រូវប្រកាសនៅពេលសវនាការ ក្រោយពីធ្វើការពិភាក្សាដេញដោល ឬ នៅពេលសវនាការលើកក្រោយ ។ ជាគោលការណ៍ សាលក្រមត្រូវប្រកាសជាអសាធារណៈនៅចំពោះមុខអនីតិជន អ្នកតំណាងដែលច្បាប់បានកំណត់ អ្នកទំនុកបម្រុង មេធាវី ភ្នាក់ងារសង្គមកិច្ច និងភាគីដែលមានប្រយោជន៍នៅក្នុងរឿងក្តី ។ សាលក្រមអាចប្រកាសកំបាំងមុខអនីតិជនបាន ក្នុងករណីដែលការប្រកាសសាលក្រមចំពោះមុខធ្វើឲ្យខូចដល់ឧត្តមប្រយោជន៍របស់អនីតិជននោះ ។ ហើយការជូនដំណឹងអំពីសាលក្រមត្រូវចាត់ថាចំពោះមុខ និងសាលក្រមកំបាំងមុខដល់អនីតិជននេះ ត្រូវអនុវត្តតាមក្រមនីតិវិធីព្រហ្មទណ្ឌ ។

ផ្នែកទី៤ : តុលាការជាន់ខ្ពស់ចំពោះរឿងក្តីអនីតិជន

៤.១. សមត្ថកិច្ចតុលាការជាន់ខ្ពស់ចំពោះរឿងក្តីអនីតិជន

តុលាការជាន់ខ្ពស់ជំនុំជម្រះលើបណ្តឹងឧទ្ធរណ៍ និងបណ្តឹងសារទុក្ខ។ ការជំនុំជម្រះលើបណ្តឹង ឧទ្ធរណ៍ដែលពាក់ព័ន្ធនិងរឿងក្តីអនីតិជន គឺជាសមត្ថកិច្ចរបស់សាលាឧទ្ធរណ៍។ រីឯការជំនុំជម្រះលើបណ្តឹងសារទុក្ខដែលពាក់ព័ន្ធនិងរឿងក្តីអនីតិជន គឺជាសមត្ថកិច្ចរបស់តុលាការកំពូល ។

ក្រុមប្រឹក្សាជំនុំជម្រះនៃសាលាឧទ្ធរណ៍ និងតុលាការកំពូលត្រូវមានសមាសភាពជាចៅក្រមជំនាញទាក់ទងនិងអនីតិជនយ៉ាងតិច ១ (មួយ) រូប[32] ។ ហើយសាលាឧទ្ធរណ៍ និងតុលាការកំពូលត្រូវលើកយករឿងក្តីរបស់អនីតិជនមកជំនុំជម្រះ ជាអាទិភាពពិសេសរឿងក្តីដែលអនីតិជនកំពុងជាប់ឃុំបណ្តោះអាសន្ន។ ចំពោះរឿងក្តីដែលអនីតិជនជាប់ឃុំត្រូវលើកយកមកជំនុំជម្រះក្នុងអំឡុងពេល ៣ (បី) ខែយ៉ាងយូរគិតពីថ្ងៃទទួលសំណុំរឿងលើកលែងតែមានមូលហេតុសត្យានុម័តដែលមិនអាចជម្នះបាន ។ ដើម្បីជាឧត្តមប្រយោជន៍របស់អនីតិជនក្នុងពេលរងចាំការជំនុំជម្រះ សាលាឧទ្ធរណ៍ និងតុលាការកំពូល គប្បីពិចារណាជាអាទិភាពអំពីការដោះលែងឲ្យនៅក្រៅឃុំបណ្តោះអាសន្នឲ្យមានសេរីភាព ។

៤.២. អំណាចរបស់តុលាការជាន់ខ្ពស់ក្នុងការបង្ខូរ

នៅដំណាក់កាលនៃការជំនុំជម្រះលើអនីតិជន ដែលមានងាយុចាប់ពី ១៤ (ដប់បួន) ឆ្នាំ

[32] មាត្រា ៥៥ នៃច្បាប់ស្តីពីយុត្តិធម៌អនីតិជន ឆ្នាំ២០១៦

ដល់ ក្រោម ១៨ (ដប់ប្រាំបី) ឆ្នាំ ជាប់ចោទពីបទលហុ បទមជ្ឈិម សាលាឧទ្ធរណ៍ ឬ តុលាការកំពូល ត្រូវពិចារណាជាបឋម ទៅលើការបង្ហែ្ល ។

រាល់បទមជ្ឈិមដែលមានស្ថានទម្ងន់ទោសដូចមានចែងក្នុងក្រមព្រហ្មទណ្ឌសាលាឧទ្ធរណ៍ ឬតុលាការកំពូលអាចពិចារណាលើការបង្ហែ្លបាន បើមានលក្ខខណ្ឌទាំងបីដូចខាងក្រោម៖

- ភាពចលាចលដល់សណ្តាប់ធ្នាប់សាធារណៈដែលបណ្តាលមកពីបទល្មើសបាន បញ្ចប់
- ការខូចខាតត្រូវបានជួសជុលរួច
- អនីតិជនជាប់ចោទបានបង្ហាញការធានាក្នុងការចូលរួមរស់ក្នុងសង្គមវិញ ។

ក្នុងករណីយល់ឃើញថាត្រូវធ្វើការបង្ហែ្ល និងក្រោយពិចារណាលើ របាយការណ៍របស់ភ្នាក់ងារសង្គមកិច្ចដែលបានចូលរួមក្នុងរឿងក្តី សាលាឧទ្ធរណ៍ ឬតុលាការកំពូល ត្រូវសម្រេចសេចក្តីឲ្យបង្ហែ្ល និងបង្គាប់ឲ្យដោះលែងអនីតិជនដែលកំពុងជាប់ឃុំនោះភ្លាម ទោះមានបណ្តឹងសារទុក្ខពីព្រះរាជអាជ្ញាក៏ដោយ ហើយត្រូវប្រគល់អនីតិជននោះទៅឲ្យឪពុកម្តាយ ឬអ្នកអាណាព្យាបាល ឬអ្នកទំនុកបម្រុងអនីតិជន ។ តុលាការអាចចេញសាលក្រមសម្រេចអំពីសំណងរដ្ឋប្បវេណី ក្នុងករណីមានការប្តឹងសុំ ។ ក្នុងករណីដែល អនីតិជនត្រូវការកិច្ចការពារ និងថែទាំ សាលាឧទ្ធរណ៍ ឬតុលាការកំពូល ត្រូវបញ្ជូនអនីតិជននោះ ទៅមន្ទីរទទួលបន្ទុកវិស័យសង្គមកិច្ចរាជធានី-ខេត្ត ដើម្បីចាត់វិធានការសមស្របទៅតាមសុខុមាលភាព និងស្ថានភាពសង្គមរបស់អនីតិជន ។ ក្នុងករណីយល់ឃើញថាអនីតិជនត្រូវការកិច្ចការពារនិងថែទាំ នោះមន្ទីរ ឬការិយាល័យត្រូវចាត់វិធានការស្នើសុំព្យួរ ឬសុំដកហូតអំណាចមេបា ឬបញ្ឈប់អ្នកអាណាព្យាបាលសម្រាប់អនីតិជន ឬអ្នកអាណាព្យាបាលទូទៅ ក្នុងករណីដែលអនីតិជនមានអ្នកតំណាងដែលច្បាប់បានកំណត់ ដើម្បីតុលាការសម្រេចអំពីការព្យួរ ឬការដកហូត ឬការបញ្ឈប់អ្នកតំណាងដែលច្បាប់បានកំណត់និងសិទ្ធិអាណាព្យាបាលលើអនីតិជននោះ ។ ក្នុងករណីដែលអនីតិជនគ្មានអ្នកតំណាងដែលច្បាប់បានកំណត់ មន្ទីរ ឬការិយាល័យត្រូវសុំទៅតុលាការដើម្បីសម្រេចអំពីសិទ្ធិអាណាព្យាបាលលើអនីតិជននោះ ។

ក្នុងករណីអនីតិជនអនុវត្តបានជោគជ័យ នូវផែនការបង្ហែ្លដោយមានរបាយការណ៍បញ្ជាក់ រួមគ្នារបស់ភ្នាក់ងារសង្គមកិច្ច និង អ្នកទទួលបន្ទុកអនុវត្តផែនការបង្ហែ្ល តុលាការត្រូវចេញសាលក្រមសម្រេចឲ្យអនីតិជនមិនទទួលខុសត្រូវព្រហ្មទណ្ឌ ។ ក្នុងករណីអនុវត្តផែនការបង្ហែ្លទទួលបរាជ័យ តុលាការអាចចេញដីកាសម្រេចបង្ហែ្លជាថ្មី ដោយពិចារណាទៅលើមូលហេតុដែលនាំឲ្យបរាជ័យក្នុងការអនុវត្តផែនការបង្ហែ្លទស្សនៈរបស់អនីតិជន អ្នកតំណាងដែលច្បាប់បានកំណត់ និងការពិគ្រោះយោបល់ជាមួយភ្នាក់ងារសង្គមកិច្ច ឬចាត់វិធានការតាមនីតិវិធី ។

៤.៣. នីតិវិធីរបស់តុលាការជាន់ខ្ពស់

ការជំនុំជម្រះនៅសាលាឧទ្ធរណ៍ និងតុលាការកំពូល លើរឿងក្តីរបស់អនីតិជនត្រូវប្រើប្រាស់នីតិវិធីកុមារមេត្រី និងត្រូវមានមេធាវីការពារព្រមទាំងពិនិត្យរបាយការណ៍ និងយោបល់ស្តីពីការប៉ាន់ប្រមាណសុខុមាលភាព និងស្ថានភាពសង្គមរបស់អនីតិជន ដែលផ្តល់ដោយភ្នាក់ងារសង្គមកិច្ច។ ក្នុងករណីដែលរបាយការណ៍ និងយោបល់ស្តីពីការប៉ាន់ប្រមាណសុខុមាលភាព និងស្ថានភាពសង្គមរបស់ អនីតិជនមិនទាន់បានរៀបចំ ហើយតុលាការត្រូវការព័ត៌មានបន្ថែម តុលាការត្រូវបង្គាប់ឲ្យភ្នាក់សង្គមកិច្ចរៀបចំ និងបំពេញបន្ថែមនូវរបាយការណ៍ និងយោបល់នោះតាមតម្រូវការ ។ បើអនីតិជនមិនមានលទ្ធភាពពឹងពាក់មេធាវីបាសនតុលាការត្រូវចាត់វិធានការឲ្យអនីតិជននោះ ។ ចំពោះការពិភាក្សាដេញដោល និងប្រកាសដីការឿងក្តីអនីតិជនត្រូវឡើងក្នុងសវនការជាសម្ងាត់ ។

ផ្នែកទី៥ : ការបង្វែរអនីតិជនចេញពីប្រព័ន្ធតុលាការ

អាជ្ញាធរទទួលបន្ទុកបង្វែររួមមាន តំណាងអង្គការអយ្យការ ចៅក្រមស៊ើបសួរ ចៅក្រមជំនុំជម្រះនៃសាលាដំបូង និងក្រុមប្រឹក្សាជំនុំជម្រះនៃសាលាឧទ្ធរណ៍[33] ។

៥.១. គោលបំណង និងគោលការណ៍នៃការបង្វែរ

ការបង្វែរអនីតិជនមានគោលបំណងដូចខាងក្រោម ៖

- លើកទឹកចិត្តអនីតិជនឲ្យទទួលស្គាល់កំហុស និងការខូចខាតដែលខ្លួនបានបង្កឡើង
- ជម្រុញឲ្យមានការសះជារវាងជនរងគ្រោះជាមួយនឹងអនីតិជន
- លើកទឹកចិត្តឲ្យមានការជួសជុលការខូចខាត ឬសំណងជម្ងឺចិត្តដល់ជនរងគ្រោះ
- អប់រំ និងកែប្រែអាកប្បកិរិយារបស់អនីតិជន
- ឆ្លើយតបនឹងសេចក្តីត្រូវការផ្ទាល់របស់អនីតិជន ដើម្បីធ្វើសមាហរណកម្មទៅក្នុងគ្រួសារ ឬសហគមន៍ ឬសង្គមវិញ
- ចៀសវាងការមានស្លាកស្នាមអាក្រក់ ក្នុងអារម្មណ៍និងបញ្ចៀសការទទួលបាននូវបទពិសោធន៍អាក្រក់នៃការប្រព្រឹត្តបទល្មើសពីជនដទៃក្នុងពេលអនុវត្តទោសនិងចៀសវាងការប្រព្រឹត្តបទល្មើសជាថ្មី
- បង្កាការរើសអើងលើអនីតិជន និងចៀសវាងមានប្រវត្តិថាជាប់ទោសក្នុងបញ្ជីថ្កោលទោស

មួយវិញទៀតគោលការណ៍នៃការបង្វែរ បានបញ្ជាក់ថាអាជ្ញាធរទទួលបន្ទុកបង្វែរ មុននឹងសម្រេចបង្វែរ ឬមិនបង្វែរ ត្រូវពិនិត្យជាបឋមលើលក្ខខណ្ឌអប្បបរមានៃការបង្វែរ និងពិចារណាលើ

[33] មាត្រា ៦១ នៃច្បាប់ស្តីពីយុត្តិធម៌អនីតិជន ឆ្នាំ២០១៦

លក្ខណៈវិនិច្ឆ័យសម្រាប់ធ្វើការបង្ហែ ។

៥.២. នីតិវិធីនៃការបង្ហែ

នៅពេលសម្រេចធ្វើការបង្ហែរឿងក្តីណាមួយ អាជ្ញាធរ ទទួលបន្ទុកបង្ហែរគ្រប់លំដាប់ថ្នាក់ ត្រូវបង្ហង់រឿងក្តីនិងចេញដីកាបង្ហែ ។ ដីកាបង្ហែរនេះត្រូវបញ្ជូនទៅអង្គការអយ្យការដែលនៅអម ដើម្បីអនុវត្ត ។ អង្គការអយ្យការ ដែលទទួលបន្ទុកអនុវត្តត្រូវចេញដីកាបង្គាប់ឲ្យសន្និសីទសហគមន៍ ធ្វើការប្រជុំរៀបចំផែនការបង្ហែរសម្រាប់ឲ្យអនីតិជនអនុវត្ត ។ ក្រោយពីអង្គការអយ្យការទទួលបាន លទ្ធផលពីកិច្ចប្រជុំសន្និសីទសហគមន៍ ដោយអនីតិជនព្រមព្រៀងទទួលយកផែនការបង្ហែរដែល រៀបចំឡើងដោយសន្និសីទសហគមន៍ និងយល់ឃើញថាសមស្របសម្រាប់អនីតិជន ហើយនោះ តំណាងអង្គការអយ្យការត្រូវចេញដីកាបង្គាប់ឲ្យអនីតិជនអនុវត្តផែនការបង្ហែរនោះ និងចាត់តាំង បុគ្គលទទួលបន្ទុកអនុវត្តផែនការបង្ហែរឲ្យគ្រប់គ្រង និងត្រួតពិនិត្យអនីតិជនដែលត្រូវអនុវត្តផែនការ បង្ហែ។ ក្នុងករណីតំណាងអង្គការអយ្យការយល់ឃើញថាផែនការបង្ហែរមិនសមស្របសម្រាប់អនីតិ ជន និងដោយមានការពិគ្រោះយោបល់ជាមួយភ្នាក់ងារសង្គមកិច្ច តំណាងអង្គការអយ្យការអាចកែ ប្រែផែនការបង្ហែរបាន ដើម្បីជាឧត្តមប្រយោជន៍របស់អនីតិជន ។

៥.៣. លក្ខខណ្ឌអប្បបរមានៃការបង្ហែ

ការបង្ហែត្រូវមានលក្ខខណ្ឌអប្បបរមាដូចខាងក្រោម ៖

ក. មានភស្តុតាគ្រប់គ្រាន់ដើម្បីចោទប្រកាន់ ឬបង្ហាញអំពីពិរុទ្ធភាពរបស់អនីតិជន ។

ខ. អនីតិជនសារភាពទទួលកំហុសដោយស្ម័គ្រចិត្ត គ្មានការបង្ខិតបង្ខំ និងមានការសុំ ទោសជនរងគ្រោះ

គ. បទល្មើសដែលបានប្រព្រឹត្តជាបទលហុ ឬបទមជ្ឈិម ឬបទមជ្ឈិមដែលមានស្ថាន ទម្ងន់ទោសដូចមានចែងនៅក្នុងក្រមព្រហ្មទណ្ឌ បើមានលក្ខខណ្ឌទាំងបីដូចតទៅ ៖

១. ភាពចលាចលដល់សណ្តាប់ធ្នាប់សាធារណៈ ដែលបណ្តាលមកពីបទល្មើសបាន បញ្ចប់

២. ការខូចខាតត្រូវបានជួសជុលរួច

៣. អនីតិជនជាប់ចោទបានបង្ហាញការធានាក្នុងការចូលទៅរួមរស់ទៅក្នុងសង្គមវិញ

ឃ. អនីតិជនយល់ព្រមឲ្យធ្វើការបង្ហែ បន្ទាប់ពីបានទទួលការពិគ្រោះយោបល់ជាមួយ ភ្នាក់ងារសង្គមកិច្ច ឬមេធាវីអំពីសិទ្ធិរបស់អនីតិជន និងពិចារណាផងដែរអំពីអានុភាព និងផលប៉ះ ពាល់នៅពេលអនុវត្តវិធានបង្ហែ ។

៥.៤. លក្ខណៈវិនិច្ឆ័យសម្រាប់ការបង្វែរ

ក្នុងករណីរឿងក្តីបំពេញទៅតាមលក្ខខណ្ឌអប្បបរមានៃការបង្វែរ ដូចមានចែងនៅក្នុងមាត្រា ៦៣ (លក្ខខណ្ឌអប្បបរមានៃការបង្វែរ) នៃច្បាប់ស្តីពីយុត្តិធម៌អនីតិជន អាជ្ញាធរទទួលបន្ទុកបង្វែរ មុននិងសម្រេចបង្វែរ ឬមិនបង្វែរ ត្រូវពិចារណាលើកត្តាដូចខាងក្រោម ៖

ក. កាល:ទេស:នៃបទល្មើស ។

ខ. ស្ថានភាពនៃបទល្មើស ។

គ. បុគ្គលិកលក្ខណៈ:របស់ អនីតិជនដូចជា អាយុ កម្រិតយល់ដឹង បញ្ញា អត្តចរិត ។

ឃ. ការទទួលឥទ្ធិពលពីគ្រួសារ និង បរិយាកាសជុំវិញការរស់នៅរបស់អនីតិជន ។

ង. ព្យសនកម្មជនរងគ្រោះ ។

ច. សុវត្ថិភាពរបស់ជនរងគ្រោះ សហគមន៍ និង សង្គម ។

៥.៥. ផែនការនៃការបង្វែរ

៥.៥.១. វិធានៃការបង្វែរ

ក្នុងករណីដែលត្រូវបង្វែរ អាជ្ញាធរទទួលបន្ទុកបង្វែរអាចសម្រេចជ្រើសរើសយកវិធានការមួយ ឬ ច្រើនដូចខាងក្រោម សម្រាប់ឲ្យអនីតិជនបំពេញកាតព្វកិច្ច ៖

- ចំណុចមួយ ឬច្រើនដែលមានចែងក្នុងក្រមនីតិវិធីព្រហ្មទណ្ឌ ស្តីពីកាតព្វកិច្ចនៃការត្រួតពិនិត្យតាមផ្លូវតុលាការ
- ទៅសាលារៀនដោយបានទៀងទាត់តាមផែនការកំណត់មិនលើសពី ៦ (ប្រាំមួយ) ខែ
- ចំណាយពេលវេលាជាក់លាក់ជាមួយក្រុមគ្រួសារមិនលើសពី ៦ (ប្រាំមួយ) ខែ
- តម្រូវអោយចូលរួមក្នុងការអប់រំបណ្តុះបណ្តាលវិជ្ជាជីវៈ ក្នុងថិរវេលាមិនលើសពី ៦ (ប្រាំមួយ) ខែ
- ធ្វើការងារសហគមន៍ដោយមិនលើសពី ១០០ (មួយរយ) ម៉ោង ។ ការងារសហគមន៍នេះ សម្រាប់តែអនីតិជនដែលមានអាយុចាប់ពី ១៦ (ដប់ប្រាំមួយ) ឆ្នាំ ឡើងទៅ ហើយមានលក្ខណៈជាការងារបណ្តុះបណ្តាល និង សម្រួលដល់ការបញ្ចូលខ្លួនទៅរស់នៅក្នុងសង្គមវិញ
- ចូលរួមក្នុងកម្មវិធីសហគមន៍ ឬមណ្ឌលដែលមានអត្ថប្រយោជន៍ សម្រាប់ជួយអនីតិជនមិនឲ្យប្រព្រឹត្តបទល្មើសសាជាថ្មី
- ឲ្យស្នាក់នៅទីកន្លែងណាណាមួយដោយកំណត់ពេលវេលាជាក់លាក់
- ជួសជុលសំណងការខូចខាតទៅជនរងគ្រោះ
- វិធានការសមស្របផ្សេងទៀតដែលបំពេញនូវគោលបំណងនៃការបង្វែរ ។

រាល់វិធានការបង្ខៃរដែលទាក់ទងនឹងការងារ ត្រូវអនុលោមតាមច្បាប់ស្តីពីការងារ និងអនុសញ្ញាអន្តរជាតិស្តីពីការងារដែលព្រះរាជាណាចក្រកម្ពុជាទទួលស្គាល់ ។

៥.៥.២. ការរៀបចំបង្កើតផែនការបង្ខៃ

ក្រោយពីបានទទួលដីកាសម្រេចបង្ខៃរពីអាជ្ញាធរទទួលបន្ទុកបង្ខៃរ ភ្នាក់ងារសង្គមកិច្ចត្រូវរៀបចំបង្កើតផែនការបង្ខៃរ។ ផែនការបង្ខៃរត្រូវសម្រេចក្នុងអំឡុងពេលមិនលើសពី ១ខែគិតពីថ្ងៃទទួលដំណឹងអំពីដីកាសម្រេចបង្ខៃរលើកលែងតែមានស្ថានភាពពិសេសដែលមិនអាចជម្នះបាន។

ក្នុងការបង្កើតផែនការបង្ខៃរជាឯកត្តបុគ្គលសម្រាប់អនីតិជនណាមួយ ភ្នាក់ងារសង្គមកិច្ចត្រូវពិចារណាទៅលើកត្តាដូចខាងក្រោម ៖

- ទស្សនៈរបស់អនីតិជន អ្នកតំណាងដែលច្បាប់បានកំណត់ និងជនដទៃទៀតដែលទទួលរងផលប៉ះពាល់នៃអំពើល្មើស អំពីភាពសមស្របនៃផែនការបង្ខៃរដែលត្រូវបានស្នើឡើង
- សាវតារ វប្បធម៌ សាសនា និងភាសារបស់អនីតិជន
- កម្រិតសិក្សា សមត្ថភាពខាងបញ្ញា កាលៈទេសៈ និងស្ថានភាពគ្រួសាររបស់អនីតិជន
- សមាមាត្ររវាងផែនការដែលបានស្នើ ឬជ្រើសរើសចំពោះស្ថានភាពរបស់អនីតិជន ចរិតនៃបទល្មើស និងផលប្រយោជន៍សង្គម និង
- អាយុ និងតម្រូវការអភិវឌ្ឍរបស់អនីតិជន ។

ផែនការបង្ខៃរសម្រាប់អនីតិជនត្រូវ ៖

- ផ្តល់នូវអត្ថប្រយោជន៍សម្រាប់អនីតិជន
- ធ្វើឲ្យអនីតិជនយល់ពីផលប៉ះពាល់នៃអាកប្បកិរិយារបស់ខ្លួន ចំពោះជនរងគ្រោះនៃបទល្មើស និងជនដទៃទៀត
- កែតម្រូវនូវកំហុសឆ្គងដែលបង្កឡើងដោយអំពើល្មើស ហើយអាចរួមបញ្ចូលទាំងសំណងការខូចខាត
- អនុវត្តនៅទីកន្លែងដែលអនីតិជនអាចអនុវត្តបាន
- ចៀសវាងការធ្វើអាជីវកម្មកេងប្រវ័ញ្ច ឬបណ្តាលឲ្យអន្តរាយ ឬធ្វើឲ្យមានគ្រោះថ្នាក់ដល់សុខភាពផ្លូវចិត្ត ឬផ្លូវកាយរបស់អនីតិជន
- មិនប៉ះពាល់ជាអវិជ្ជមានដល់ការសិក្សារបស់អនីតិជន បើអនីតិជនកំពុងសិក្សា និង
- មិនមានការពាក់ព័ន្ធ នឹងការដកហូតសេរីភាព នៅក្នុងទម្រង់នៃការដាក់ទោសណាមួយឡើយ។

៥.៥.៣. ការសម្រេចអំពីផែនការបង្វែរដោយអាជ្ញាធរទទួលបន្ទុកបង្វែរ

ភ្នាក់ងារសង្គមកិច្ច ត្រូវបញ្ជូនផែនការបង្វែរទៅអាជ្ញាធរទទួលបន្ទុកបង្វែរ ដើម្បីពិនិត្យនិងសម្រេច ។ ករណីអាជ្ញាធរទទួលបន្ទុកបង្វែរយល់ស្របចំពោះផែនការបង្វែរ អាជ្ញាធរទទួលបន្ទុកបង្វែរត្រូវចេញដីកាសម្រេចឲ្យអនុវត្តផែនការបង្វែរ ។

ករណីអាជ្ញាធរទទួលបន្ទុកបង្វែរមិនយល់ស្រប ចំពោះផែនការបង្វែរដែលរៀបចំដោយភ្នាក់ងារសង្គមកិច្ច អាជ្ញាធរទទួលបន្ទុកបង្វែរត្រូវបង្គាប់ឲ្យភ្នាក់ងារសង្គមកិច្ចរៀបចំឡើងវិញនូវផែនការបង្វែរថ្មី ។ ផែនការបង្វែរត្រូវសម្រេចក្នុងអំឡុងពេលមិនលើសពី ១(មួយ)ខែ គិតពីថ្ងៃទទួលដំណឹងអំពីដីកាបង្គាប់ លើកលែងតែមានស្ថានភាពពិសេសដែលមិនអាចជម្នះបាន ។

៥.៦. ការអនុវត្តផែនការបង្វែរ

៥.៦.១. ការអនុវត្ត

ភ្នាក់ងារសង្គមកិច្ច និង បុគ្គលទទួលបន្ទុកអនុវត្តផែនការបង្វែរ ត្រូវធានារ៉ាប់រងអនុវត្តសេចក្តីសម្រេច និងផែនការបង្វែររបស់អាជ្ញាធរទទួលបន្ទុកបង្វែរ ក្នុងការគ្រប់គ្រង និងត្រួតពិនិត្យលើ អនីតិជនដែលត្រូវអនុវត្តផែនការបង្វែរ ។

បុគ្គលទទួលបន្ទុកអនុវត្តផែនការបង្វែរ ត្រូវធ្វើរបាយការណ៍ស្តីពីលទ្ធផលជោគជ័យ ឬបរាជ័យ ឬឧបសគ្គដែលកើតមាន នៅក្នុងការអនុវត្តផែនការខាងលើទៅភ្នាក់ងារសង្គមកិច្ច ។ ភ្នាក់ងារសង្គមកិច្ចត្រូវបញ្ជូនរបាយការណ៍នោះរួមទាំងយោបល់របស់ខ្លួន ទៅអាជ្ញាធរទទួលបន្ទុកបង្វែរ ហើយចម្លងជូនទៅមន្ទីរទទួលបន្ទុកវិស័យសង្គមកិច្ចរាជធានី-ខេត្ត ។

៥.៦.២. ការកែប្រែវិធានការបង្វែរក្នុងពេលអនុវត្ត

ក្នុងអំឡុងពេលអនុវត្តផែនការបង្វែរ អាជ្ញាធរទទួលបន្ទុកបង្វែរអាចកែប្រែវិធានការបង្វែរបានតាមគំនិតផ្តួតផ្តើមរបស់ខ្លួន ឬតាមការស្នើសុំរបស់ភ្នាក់ងារសង្គមកិច្ចស្របទៅតាមស្ថានភាពជាក់ស្តែង ដើម្បីជាប្រយោជន៍របស់អនីតិជន ។ អាជ្ញាធរទទួលបន្ទុកបង្វែរត្រូវសម្រេចក្នុងរយៈពេល ៥(ប្រាំ) ថ្ងៃ នៃថ្ងៃធ្វើការ បន្ទាប់ពីថ្ងៃបានទទួលពាក្យស្នើសុំរបស់ភ្នាក់ងារសង្គមកិច្ច។ ក្នុងករណីអាជ្ញាធរទទួលបន្ទុកបង្វែរមិនបានសម្រេចក្នុងចិរវេលានេះ ត្រូវចាត់ទុកថាយល់ស្របតាមការស្នើសុំ ។ ការកែប្រែផែនការបង្វែរ មិនចាត់ទុកថាជាការបរាជ័យក្នុងការអនុវត្តផែនការបង្វែរឡើយ ។

៥.៦.៣. បរាជ័យក្នុងការអនុវត្តវិធានការបង្វែរ

បរាជ័យក្នុងការអនុវត្តវិធានការបង្វែរ សំដៅដល់ករណីដែលអនីតិជនមិនបានគោរពតាមកាតព្វកិច្ចនៅក្នុងវិធានការបង្វែរ ឬនៅក្នុងវិធានការបង្វែរដែលត្រូវបានកែប្រែ ។ ភ្នាក់ងារសង្គមកិច្ចត្រូវ ផ្តល់របាយការណ៍ស្តីពី លទ្ធផលនៃការមិនគោរពកាតព្វកិច្ចដែលបាន កំណត់នៅក្នុងវិធានការបង្វែរ ឬនៅក្នុងវិធានការបង្វែរដែលបានកែប្រែ រួមទាំងយោបល់ជូនទៅអាជ្ញាធរទទួលបន្ទុក

បង្ហៃរដើម្បីសម្រេច ដោយចម្លងជូនទៅមន្ទីរទទួលបន្ទុកបង្ហៃរវិស័យសង្គមកិច្ចរាជធានី-ខេត្ត ។ ក្រោយពិនិត្យរបាយការណ៍ខាងលើ អាជ្ញាធរទទួលបន្ទុកបង្ហៃត្រូវកោះហៅអនីតិជន ឪពុកម្តាយ ឬអ្នកអាណាព្យាបាល ឬអ្នកទំនុកបម្រុង ភ្នាក់ងារសង្គមកិច្ច បុគ្គលទទួលបន្ទុកអនុវត្តផែនការបង្ហៃ និងមេធាវីរបស់អនីតិជន ប្រសិនបើមាន ឲ្យចូលមកបង្ហាញខ្លួនក្នុងថិរវេលា មិនលើសពី ១៥ (ដប់ប្រាំ) ថ្ងៃ ។ អាជ្ញាធរទទួលបន្ទុកបង្ហៃ ត្រូវសាកសួរពីមូលហេតុដែលអនីតិជននោះមិនគោរពតាមវិធានការបង្ហៃ ។

ក្រោយពីបានពិចារណាអំពីទស្សនៈរបស់អនីតិជន ឪពុកម្តាយ ឬអ្នកអាណាព្យាបាល ឬអ្នកទំនុកបម្រុង និងបន្ទាប់ពីបានពិគ្រោះយោបល់ជាមួយភ្នាក់ងារសង្គមកិច្ច អាជ្ញាធរទទួលបន្ទុកបង្ហៃអាចចេញដីកាបង្ហៃថ្មី ឬបន្តចាត់ការតាមនីតិវិធីព្រហ្មទណ្ឌជាធរមាន ។ បទប្បញ្ញត្តិនៃមាត្រា ៦៦ (ការរៀបចំបង្កើតផែនការបង្ហៃ) ដល់មាត្រា ៧០ (ការកែប្រែវិធានការបង្ហៃ) ខាងលើនេះត្រូវយកមកអនុវត្តក្នុងករណីដែលអាជ្ញាធរទទួលបន្ទុកបង្ហៃចេញដីកាបង្ហៃថ្មី[34] ។ ក្នុងករណីអនីតិជនមិនបង្ហាញខ្លួនតាមការកោះហៅដោយគ្មានមូលហេតុសមស្រប អាជ្ញាធរទទួលបន្ទុកបង្ហៃត្រូវបន្តចាត់ការបន្តតាមនីតិវិធីព្រហ្មទណ្ឌជាធរមាន ។

៥.៧. ការបញ្ចប់នីតិវិធីបង្ហៃ

តំណាងអង្គការអយ្យការ ត្រូវសម្រេចចេញដីកាលើកលែងចោទប្រកាន់ក្នុងករណីការអនុវត្តផែនការបង្ហៃទទួលបានជោគជ័យ ។ លទ្ធផលជោគជ័យនេះត្រូវមានរបាយការណ៍បញ្ជាក់ រួមគ្នាពីភ្នាក់ងារសង្គមកិច្ច និងបុគ្គលទទួលបន្ទុកអនុវត្តផែនការបង្ហៃ ។ បើតំណាងអង្គការអយ្យការសម្រេចថាការបង្ហៃមិនទទួលបានជោគជ័យដោយមានរបាយការណ៍បញ្ជាក់រួមគ្នាពីភ្នាក់ងារសង្គមកិច្ច និងបុគ្គលទទួលបន្ទុកអនុវត្តផែនការបង្ហៃ តំណាងអង្គការអយ្យការត្រូវបន្តចាត់ការរឿងក្តីតាមនីតិវិធីតុលាការឲ្យបានឆាប់រហ័សបំផុត ។

[34] មាត្រា ៧១ កថាខណ្ឌទី៦ នៃច្បាប់ស្តីពីយុត្តិធម៌អនីតិជន ឆ្នាំ២០១៦

ជំពូកទី ៣

ការទទួលទោស ការដោះលែង និងការលើកលែងទោសចំពោះអនីតិជន

ជំពូកទី ៣

ការទទួលទោស ការដោះលែង និងការលើកលែងទោសចំពោះអនីតិជន

ផ្នែកទី ១ : ការផ្តន្ទាទោស និងការអនុវត្តទោស

ការដាក់ទោស គឺជាផ្នែកមួយដ៏សំខាន់មួយ ដែលច្បាប់ត្រូវអនុវត្តចំពោះកុមារត្រូវតែខុសឆ្ងាយពីច្បាប់ ដែលអនុវត្តចំពោះនីតិជន ។ អនុសញ្ញាស្តីពីសិទ្ធិកុមារ បានចែងថា ទោះបីកុមារត្រូវបានឲ្យទទួលខុសត្រូវចំពោះអំពើរបស់ខ្លួនក្តី ការធ្វើទោសបែបនេះ ត្រូវតែធ្វើក្នុងលក្ខណៈមួយដែលលើកកម្ពស់ដល់ការធ្វើសមាហរណកម្មកុមារចូលទៅក្នុងសង្គមជាតិវិញ ។ វិធីសាស្ត្រនៃការដាក់ទណ្ឌកម្មត្រង់ៗត្រូវបានហាមឃាត់ហើយការដាក់ទណ្ឌកម្មណាមួយ ត្រូវតែសមាមាត្រ មិនត្រឹមតែចំពោះបទល្មើសប៉ុណ្ណោះទេ តែថែមទាំងសមាមាត្រទៅនឹងប្រវត្តិ និងកាលៈទេសៈរបស់កុមារម្នាក់ៗទៀតផង ។ ចំណែកឯនៅក្នុងប្រទេសភាគច្រើនក្រមព្រហ្មទណ្ឌជាតិរបស់ខ្លួន បានចែងអំពីទោសអ្វីដែលសមស្របសម្រាប់អនុវត្តចំពោះបទល្មើសនីមួយៗ ។

១.១. ការផ្តន្ទាទោសចំពោះអនីតិជន

ជាទូទៅការផ្តន្ទាទោសចំពោះអនីតិជន រួមមានទាំងប្រភេទនៃទោសដែលអាចអនុវត្តបានដូចជា (ការជាកពិន័យ ការព្យួរទោសសាកល្បង ឬការដាក់ក្នុងពន្ធនាគារ) ក៏ដូចចំនួនអតិបរមា ឬរយៈពេលអតិបរមានៃទោសនោះ (ដូចជារយៈពេលជាប់ពន្ធនាគារ ១០ ឆ្នាំ) ។ ច្បាប់ស្តីពីយុត្តិធម៌អនីតិជន បានធ្វើការលុបចោលលើបទប្បញ្ញាតិទាំងនេះ ដោយចែងអំពីគោលការណ៍ដាក់ទោសខុសៗគ្នា មានដូចជា ជម្រើសនៃការដាក់ទោសដោយមិនឃុំឃាំងរួមទាំងឆន្ទានុសិទ្ធិ ឬភាពបត់បែនដែលមានលក្ខណៈកាន់តែធំធេងនៅពេលធ្វើសេចក្តីសម្រេចអំពីចំណាត់ការដ៏សមស្របបំផុត ។

ច្បាប់ស្តីពីយុត្តិធម៌អនីតិជន បានចែងរួមបញ្ចូលដូចជា គោលការណ៍ជាមូលដ្ឋាន ឬកត្តានានា សម្រាប់ធ្វើការពិចារណានៅពេលធ្វើសេចក្តីសម្រេចអំពីចំណាត់ការដ៏សមស្របបំផុត ត្រូវចែងឲ្យបានច្បាស់ ហើយជាពិសេសការប្រើប្រាស់ការឃុំខ្លួនអនីតិជនត្រូវបានកំហិត លើកលែងតែចំពោះបទល្មើសធ្ងន់ធ្ងរដែលត្រូវបានចែងជាពិសេស គឺការដកហូតសេរីភាព ត្រូវបើប្រាស់ជាវិធានការណ៍ចុងក្រោយបំផុតក្នុងរយៈពេលសមស្រប និងខ្លីបំផុតត្រូវតែចែងឲ្យច្បាស់ដែល ចំពោះបញ្ហានេះត្រូវតម្រូវឲ្យមានការពិចារណាដោយគិតពីឧត្តមប្រយោជ៍របស់អនីតិជន ។ តែផ្ទុយទៅវិញការដាក់ទណ្ឌកម្មលើរូបរាងកាយចំពោះអនីតិជនត្រូវបានហាមឃាត់ ប៉ុន្តែការដាក់ទណ្ឌកម្មនេះអាចធ្វើទៅបានលុះត្រាតែមានច្បាប់ចែងឲ្យបានច្បាស់លាស់ជាមុនសិន ។ ទោះបីមានការដាក់ទោសយ៉ាងណាក៏ដោយទោសប្រហារជីវិត ឬការឃុំខ្លួនមួយជីវិត ត្រូវបានហាមឃាត់ក្នុងការយកមកអនុវត្តចំពោះអនីតិជន ។

ដោយយល់ឃើញថាបញ្ហាក្នុងការផ្តន្ទាទោសដល់អនីតិជន គឺជាបញ្ហាដ៏ក្តៅគគុកមួយ ដែលអាចនឹងជះឥទ្ធិពលដល់សង្គមជាតិ ដែលបណ្តាលឲ្យមានការបង្អាក់នូវភាពរីកចម្រើននៃ វិស័យអប់រំ ដែលជាកត្តាមួយនាំឲ្យខ្វះខាតនូវធនធានមនុស្សដែលជាជំនាន់ក្រោយៗទៀត មិនត្រឹម តែប៉ុណ្ណោះទេ ការផ្តន្ទាទោសចំពោះអនីតិជនធ្វើឲ្យមានការប៉ះពាល់ដល់ការអភិវឌ្ឍន៍ខ្លួនរបស់ អនីតិជន ។ នេះហើយជាកត្តាដែលនាំឲ្យមានសេចក្តីប្រកាសស្តីពីទណ្ឌកម្មព្រហ្មទណ្ឌទៅលើអនីតិ ជន ដែលមានអាយុចាប់ពី ១៤ (ដប់បួន) ឆ្នាំ ដល់ក្រោម ១៨ (ដប់ប្រាំបី) ឆ្នាំ ។ តុលាការគ្រប់លំដាប់ ថ្នាក់ ត្រូវពិនិត្យពិចារណាលើ កាល:ទេស:នៃបទល្មើស និងបុគ្គលិកលក្ខណ:នៃជនជាប់ចោទដូច ជា ពិការភាព គ្មានទីជម្រកភាពក្រីក្រ បញ្ញាស្មារតីខ្សោយ មិនទទួលបានការអប់រំរៀនសូត្រ គ្មាន ការគ្រប់គ្រង ត្រូវបានគេបោះបង់ចោល មានការបង្ខិតបង្ខំពីបុគ្គលណាមួយដែលមានអំណាចលើ អនីតិជននោះ ធ្លាប់បានជួបប្រទះហេតុការណ៍ប៉ះទង្គិចផ្លូវចិត្ត មិនធ្លាប់បានប្រព្រឹត្តបទល្មើស មាន ការអភ័យទោសពីសំណាក់ជនរងគ្រោះ ភាពមិនប្រក្រតីពីកំណើតរបស់កុមារ គ្មានសញ្ញាបង្ហាញពី ការគំរាមកំហែងធំដុំដល់សង្គម ឬបរិយាកាសគ្រួសារដែលរំលោភបំពាន ។

បទល្មើសរបស់អនីតិជនប្រព្រឹត្តឡើងដោយសារមានការប្រមាថ ឬការរើសអើងពីបុគ្គល ណាមួយមកលើខ្លួនជាអាទ៍ ៖ ពូជសាសន៍ សាសនា ពិការភាព សញ្ជាតិ អាយុ ភេទ ឬនិន្នាការ នយោបាយកត្តាសម្រាប់ផ្សេងៗដែលតុលាការយល់ឃើញគប្បីលើកយកពិចារណា ។

១.២.ការអនុវត្តទោសចំពោះអនីតិជន

អនុសញ្ញាស្តីពីសិទ្ធិកុមារ និងវិធានរបស់អង្គការសហប្រជាជាតិសម្រាប់ការការពារអនីតិ ជនដែលត្រូវបានដកហូតសេរីភាពរបស់ខ្លួន ចែងអំពីក្រមដែលមានលក្ខណ:ពេញលេញនៃសិទ្ធិ កុមារដែលត្រូវបានដកហូតសេរីភាពរបស់ខ្លួន ។ បទដ្ឋានជាមូលដ្ឋានទាំងនេះគួរត្រូវបានបញ្ចូល ទៅក្នុងក្រមព្រហ្មទណ្ឌរបស់ច្បាប់ជាតិ។ ហេតុនេះហើយត្រូវចែងឲ្យបានច្បាស់លាស់អំពីគោល បំណង ឬវត្ថុបំណងនៃការយុំដែលផ្តោតលើការស្តារនីតិសម្បទាមិនមែនជាការដាក់ទណ្ឌកម្មទ។ បើ យោងតាមច្បាប់ស្តីពីយុត្តិធម៌ អនីតិជន ដែលបានផ្តល់ឲ្យនូវអនីតិជនដែលបានផ្តន្ទាទោស ត្រូវ ស្ថិតនៅជាលក្ខណ:ជាជនដែលត្រូវទទួលនូវគោលការណ៍ស្តារនីតិសម្បទាតែប៉ុណ្ណោះ ។ កត្តានេះ ហើយទើបធ្វើឲ្យមានការសម្រេចសេចក្តីថា តុលាការគ្រប់លំដាប់ថ្នាក់អាចសម្រេចប្រគល់ទណ្ឌិត ជាអនីតិជន ដែលត្រូវបានផ្តន្ទាទោសទៅមណ្ឌលយុវនីតិសម្បទារាជធានី-ខេត្តណាមួយ ដែលសម ស្របប្រសិនបើមានការសំណូមពរពីទណ្ឌិតជាអនីតិជន ។

ប្រសិនបើទណ្ឌិតជាអនីតិជនឈានចូលអាយុ ១៨(ដប់ប្រាំបី) ឆ្នាំ ក្នុងពេលបាន នឹងកំពុង អនុវត្តទោសនៅក្នុងមណ្ឌលយុវនីតិសម្បទា ទណ្ឌិតនោះត្រូវបានរក្សាទុកនៅក្នុងមណ្ឌលយុវនីតិ

សម្បទាបន្តរហូតដល់អាយុក្រោម ២៥ (ម្ភៃបួន) ឆ្នាំ ។ នៅពេលទណ្ឌិតឈានចូលអាយុ ២៥ (ម្ភៃបួន) ឆ្នាំ ទណ្ឌិតនោះត្រូវផ្ទេរអនុវត្តទោសបន្តនៅក្នុងមណ្ឌលឃុំខ្លួនសម្រាប់នីតិជន ។[35] បែបបទ និងនីតិវិធីនៃការផ្ទេរ ការប្រគល់ និងការទទួលទណ្ឌិត ត្រូវកំណត់ដោយប្រកាសអន្តរក្រសួងរវាងមន្ត្រីទទួលបន្ទុកវិស័យសង្គមកិច្ច រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ។

១.៣. ទោសដែលអាចអនុវត្តបានចំពោះអនីតិជន

ដើម្បីអនុវត្តបានចំពោះអនីតិជន យើងត្រូវធ្វើការតែងតាំងអាជ្ញាធរទទួលបន្ទុកធ្វើអធិការកិច្ចជាប្រចាំ និងតាមពេលវេលាកំណត់ក្នុងគ្រប់ទីកន្លែងឃុំខ្លួនទាំងអស់ រួមមានការចូលសួរសុខទុក្ខដោយសេរី និងមិនចាំបាច់ជូនដំណឹងឲ្យដឹងជាមុននោះទេ ។ តែផ្ទុយទៅវិញយោងតាមមាត្រា ១៦០ នៃក្រមព្រហ្មទណ្ឌ ឆ្នាំ២០១០ នៃព្រះរាជាណាចក្រកម្ពុជា បាននិយាយថាក្នុងករណីដែលតុលាការសម្រេចផ្តន្ទាទោសព្រហ្មទណ្ឌទៅលើអនីតិជនអាយុចាប់ពី ១៤ (ដប់បួន) ឆ្នាំ ឡើងទៅ មូលទោសលើបទល្មើសដែលចោទប្រកាន់ ត្រូវបានបន្ថយក្នុងលក្ខខណ្ឌដូចជា ៖

១. អតិបរមានៃទោសដាក់ពន្ធនាគារត្រូវបន្ថយពាក់កណ្តាល ។ ដូចជាករណីបទឃាតកម្ម ធម្មតាត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ១០ (ដប់) ឆ្នាំ ទៅ ១៥ (ដប់ប្រាំ) ឆ្នាំ ក៏ប៉ុន្តែចំពោះជនល្មើសជាអនីតិជនអាយុចន្លោះពី ១៤ (ដប់បួន) ឆ្នាំ ដល់ក្រោម ១៨ (ដប់ប្រាំបី) ឆ្នាំ ទោសដាក់ពន្ធនាគារគឺត្រូវកាត់បន្ថយពាក់កណ្តាល គឺមកត្រឹមតែពី ៥ឆ្នាំ ទៅ ៧ឆ្នាំកន្លះវិញ ។

២. ប្រសិនបើអតិបរមានៃទោសនោះ គឺជាទោសដាក់ពន្ធនាគារអស់មួយជីវិត អតិបរមាត្រូវបន្ថយមកដាក់ពន្ធនាគារ ២០ (ម្ភៃ) ឆ្នាំ ។

៣. អប្បបរមានៃទោសដាក់ពន្ធនាគារ ត្រូវបន្ថយពាក់កណ្តាល ប្រសិនបើអប្បបរមានេះលើសពី ១ (មួយ) ថ្ងៃ ។

៤. អប្បបរមា និងអតិបរមានៃទោសពិន័យជាប្រាក់ ត្រូវបន្ថយពាក់កណ្តាល ។

តែផ្ទុយទៅវិញចំពោះបទប្បញ្ញត្តិស្តីពីទោស ដែលអនុវត្តលើអនីតិជននៃច្បាប់ស្តីពីយុត្តិធម៌អនីតិជន ពុំមានចែងដែលទាក់ទងនឹងចំណុចដែលកំណត់ទោស ដែលអាចអនុវត្តចំពោះអនីតិជននោះទេ ។ តែផ្ទុយទៅវិញ រាល់ទោសដែលអនុវត្តចំពោះអនីតិជនត្រូវអនុវត្តតាមបទប្បញ្ញត្តិទាំងឡាយដែលមានចែងក្នុងក្រមព្រហ្មទណ្ឌ ។

ផ្នែកទី ២ : ការផ្តល់ និងការហានពីតិសម្បទាឡើងវិញ

បន្ទាប់ពីអនីតិជន បានអនុវត្តទោសរួចរាល់ចប់សព្វគ្រប់ហើយនោះ ឬពេលអាជ្ញាយុកាលនៃទោសត្រូវបានផុត ច្បាប់បានតម្រូវឲ្យមានលក្ខខណ្ឌនៃការផ្តល់ និង ការស្តារនីតិសម្បទា

[35] មាត្រា ៨២ កថាខណ្ឌទី២ នៃច្បាប់ស្តីពីយុត្តិធម៌អនីតិជន ឆ្នាំ២០១៦

ឡើងវិញចំពោះអនីតិជន ដែលប្រព្រឹត្តបទល្មើសដែលមានដូចតទៅ ៖

២.១. ការផ្តល់នីតិសម្បទាឡើងវិញតាមផ្លូវតុលាការ

ការផ្តល់ឲ្យមាននីតិសម្បទាឡើងវិញតាមផ្លូវតុលាការ អាចត្រូវបានផ្តល់ឲ្យ ឬមិនផ្តល់ឲ្យ ដោយសភាព្រហ្មទណ្ឌនៃសាលាឧទ្ធរណ៍ ដែលមានការប្រកាសផ្តន្ទាទោសដោយតុលាការ នៅក្នុងសមត្ថកិច្ចដែនដីសាលាឧទ្ធរណ៍នេះ ។

ពាក្យសុំអាចត្រូវធ្វើឡើងដោយ ទណ្ឌិតជានីតិជនដែលបានប្រព្រឹត្តបទល្មើសនៅពេលខ្លួនជាអនីតិជន ឬធ្វើឡើងដោយអ្នកតំណាងដែលច្បាប់បានកំណត់ ក្នុងករណីទណ្ឌិតជាអនីតិជន ។ ដោយតាមប្បញ្ញត្តិនៃមាត្រា ៧៤ នៃច្បាប់ស្តីពីយុត្តិធម៌អនីតិជន ឆ្នាំ២០១៦ បានចែងថា លក្ខខណ្ឌលើរយៈពេលទាក់ទងនឹងពាក្យសុំឲ្យមានការផ្តល់នីតិសម្បទាឡើងវិញ អាចនឹងដាក់ជូនសភាព្រហ្មទណ្ឌនៃសាលាឧទ្ធរណ៍ពិនិត្យបាន លុះត្រាតែផុតរយៈពេលដូចតទៅ ៖

- ២ (ពីរ) ឆ្នាំ ចំពោះបទឧក្រិដ្ឋ
- ៦ (ប្រាំមួយ) ខែ ចំពោះបទមជ្ឈិម
- ១ (មួយ) ខែ ចំពោះបទលហុ

រយៈពេលនេះចាប់ផ្តើមគិតពីការអនុវត្តទោសរួច ឬនៅពេលទោសត្រូវបានផុតអាជ្ញាយុកាល[36] ។ ការមិនបង់ប្រាក់ពិន័យ ប្រាក់ពាក់ព័ន្ធនៃនីតិវិធី ឬប្រាក់សំណង និងជម្ងឺចិត្តមិនមែនជាឧបសគ្គដល់ការឲ្យមាននីតិសម្បទាឡើងវិញនោះទេ ប្រសិនបើទណ្ឌិតផ្តល់ជូនភស្តុតាងថាខ្លួនស្ថិតនៅភាពអសាធនីយ៍[37] ។

អនីតិជន ឬអ្នកតំណាងដែលច្បាប់បានកំណត់ ត្រូវធ្វើពាក្យសុំឲ្យមានការផ្តល់នីតិសម្បទាឡើងវិញជូនទៅព្រះរាជអាជ្ញា ដែលមានសមត្ថកិច្ចខាងដែនដី ។ ហើយត្រូវចង្អុលបង្ហាញប្រភេទនៃទណ្ឌកម្មដែលខ្លួនបានរង និងបញ្ជាក់ពីទីកន្លែងដែលខ្លួនបានរស់នៅ តាំងពីពេលដែលខ្លួនត្រូវបានដោះលែងឲ្យមានសេរីភាពឡើងវិញ ។ បន្ទាប់ពីបានទទួលពាក្យសុំហើយនោះ ព្រះរាជអាជ្ញាចាប់ពីការស៊ើបអង្កេតអំពីសីលធម៌នៅគ្រប់ទីកន្លែងដែលទណ្ឌិតធ្លាប់បានរស់នៅ តាំងពីពេលដែលខ្លួនត្រូវបានដោះលែង ។

ព្រះរាជអាជ្ញា សុំឲ្យគេប្រគល់មកខ្លួនវិញ ៖

- លិខិតចម្លង នៃសេចក្តីសម្រេចផ្តន្ទាទោស
- លិខិតជូនដំណឹង អំពីកាលបរិច្ឆេទនៃការអនុវត្តទោសរួចហើយ

[36] មាត្រា ៧៥ កថាខណ្ឌទី ២ នៃច្បាប់ស្តីពីយុត្តិធម៌អនីតិជន ឆ្នាំ២០១៦, មាត្រា ១៥៤ , ១៥៥ និងមាត្រា ១៥២ នៃក្រមព្រហ្មទណ្ឌ ឆ្នាំ២០១០ (នៅពេលផុតអាជ្ញាយុកាលហើយ ទោសលែងអនុវត្តបានទៀតហើយ ។

[37] មាត្រា ៥៣៥ កថាខណ្ឌ ២ នៃក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា

➢ ព្រឹត្តិប័ត្រលេខ១ នៃបញ្ជីថ្កោលទោស ។

ព្រះរាជអាជ្ញានឹងបញ្ជូនសំណុំរឿង ដោយមានយោបល់ដែលមានសំអាងហេតុរបស់ខ្លួនភ្ជាប់ជាមួយទៅជូនអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ ។ បន្ទាប់ពីអគ្គព្រះរាជអាជ្ញា បានទទួលការបញ្ជូនសំណុំរឿងដោយព្រះរាជអាជ្ញាហើយនោះ អគ្គព្រះរាជអាជ្ញា ប្តឹងទៅសភាព្រហ្មទណ្ឌនៃសាលាឧទ្ធរណ៍ហើយជូនដំណឹងអំពីកាលបរិច្ឆេទនៃសវនាការដល់អ្នកប្តឹង និងមេធាវី ។ បន្ទាប់ពីបានទទួលពាក្យបណ្តឹងពីអគ្គព្រះរាជអាជ្ញាតុលាការ ត្រូវសម្រេចនៅពេលសវនាការសាធារណៈ ក្រោយពីបានស្តាប់ទណ្ឌិត មេធាវី និងអគ្គព្រះរាជអាជ្ញា ។

នៅក្នុងករណីដែលតុលាការបដិសេធពាក្យសុំ សាមីជនមិនអាចជូនពាក្យសុំថ្មីទៀតទេ មុនផុត រយៈពេល ២ (ពីរ) ឆ្នាំ បានឡើយ ។ ប៉ុន្តែប្រសិនបើពាក្យសុំលើកទី ១ ត្រូវតុលាការបដិសេធមកពីមិនគោរពរយៈពេលដែលមានក្នុង មាត្រា ៧៤ នៃច្បាប់ស្តីពីយុត្តិធម៌អនីតិជន ពាក្យសុំថ្មីអាចធ្វើបានចាប់ពីផុតរយៈពេលនោះ ។

២.២. ការមានទីតិសម្បទាឡើងវិញតាមច្បាប់កំណត់

ដោយយោងតាមមាត្រា ៧៥ នៃច្បាប់ស្តីពីយុត្តិធម៌អនីតិជន នៃព្រះរាជាណាចក្រកម្ពុជា បានប្បញ្ញត្តិថា ការមានទីតិសម្បទាត្រូវមានឡើងវិញដោយពេញលក្ខណៈច្បាប់ នៅពេលផុតរយៈពេល ៖

- ៣ (បី) ឆ្នាំចំពោះបទឧក្រិដ្ឋ

ករណីជាក់ស្តែង ៖ អនីតិជនបានប្រព្រឹត្តបទឃាតកម្ម នៅថ្ងៃទី ០១ ខែ មករា ឆ្នាំ ២០១៩ ហើយត្រូវបានតុលាការប្រកាសអនុវត្តទោស ២ឆ្នាំ ៦ខែ នៅថ្ងៃទី ០១ ខែ មីនា ឆ្នាំ ២០១៩ ហើយអនីតិជនបានអនុវត្តទោសចប់សព្វគ្រប់នៅថ្ងៃទី ០១ ខែ កញ្ញា ឆ្នាំ ២០២១ ។ ដូច្នេះការទទួលបានទីតិសម្បទាឡើងវិញដោយតាមពេញលក្ខណៈច្បាប់ មិនតម្រូវឲ្យអនីតិជននោះ ឬអ្នកតំណាងដែលច្បាប់បានកំណត់ដាក់ពាក្យសុំទៅសភាព្រហ្មទណ្ឌនោះទេ ដោយគ្រាន់តែទុកឲ្យផុតរយៈពេល ៣ឆ្នាំ ១ឆ្នាំ ៣ខែ ចំពោះបទល្មើសដែលអនីតិជនបានប្រព្រឹត្ត គិតចាប់ពីថ្ងៃអនុវត្តទោសរួច ឬពេលទោសផុតអាជ្ញាយុកាល ។

- ១ (មួយ)ឆ្នាំ ចំពោះបទមជ្ឈិម និង
- ៣ (បី) ខែ ចំពោះបទលហុ ។

រយៈពេលនេះចាប់ផ្តើមគិតពីការអនុវត្តទោសរួច ឬនៅពេលទោសផុតអាជ្ញាយុកាល ។

អនីតិជនដែលទទួលបានទីតិសម្បទាឡើងវិញ ត្រូវបានលុបលាងចោលទណ្ឌកម្មព្រហ្មទណ្ឌទាំងអស់ ហើយត្រូវបានគេលុបចេញពីបញ្ជីថ្កោលទោស ។ កំណត់ហេតុ និងសំណុំរឿងឯក

សារដទៃទៀតរបស់អនីតិជនត្រូវបានរក្សាជាសម្ងាត់ ។

ផ្នែកទី ៣ : សមត្ថកិច្ចគ្រប់គ្រងអនីតិជន

៣.១. មណ្ឌលយុវនីតិសម្បទា

ការឃុំខ្លួនអនីតិជន ធ្វើឡើងក្នុងគោលបំណងនៃការស្តារនីតិសម្បទាជាអាទ៍ ការបណ្តុះបណ្តាល ការព្យាបាល ការថែទាំ ការការពារ ការអប់រំ និងផ្តល់ជំនាញវិជ្ជាជីវៈក្នុងទស្សនៈជួយអនីតិជនឲ្យក្លាយជាពលរដ្ឋសុចរិត និងមានប្រយោជន៍ដល់សង្គមជាតិ ។[38] មន្ត្រីមណ្ឌលយុវនីតិសម្បទាដដែលទទួលបន្ទុកគ្រប់គ្រងអនីតិជន ត្រូវទទួលការបណ្តុះបណ្តាលអំពីចិត្តសាស្ត្រ សុខុមាលភាព បទដ្ឋានជាតិ និងអន្តរជាតិពាក់ព័ន្ធនឹងកុមារ និងវិធានការសម្រាប់ការពារអនីតិជនដែលត្រូវបានដកហូតសេរីភាព ។ ត្រូវបង្កើតឲ្យមានមណ្ឌលយុវនីតិសម្បទានៅតាមរាជធានី ខេត្ត សម្រាប់គ្រប់គ្រងអនីតិជន។ មណ្ឌលនេះត្រូវស្ថិតនៅក្រោមការគ្រប់គ្រងរបស់ក្រសួងទទួលបន្ទុកវិស័យសង្គមកិច្ច ។ ការរៀបចំ និងការប្រព្រឹត្តទៅរបស់មណ្ឌលយុវនីតិសម្បទា ត្រូវកំណត់ដោយអនុក្រឹត្យ ។

សម្រាប់ការគ្រប់គ្រងអនីតិជននៅក្នុងមណ្ឌលយុវនីតិសម្បទា ត្រូវបែងចែកជា ៣ (បី) ផ្នែកដាច់ដោយឡែកពីគ្នា ៖

- ✓ ផ្នែកសម្រាប់ឃុំខ្លួនអនីតិជនបណ្តោះអាសន្ន
- ✓ ផ្នែកសម្រាប់ឃុំខ្លួនទណ្ឌិតជាអនីតិជនដើម្បីទទួលកម្មវិធីស្តារនីតិសម្បទា
- ✓ ផ្នែកសម្រាប់ត្រៀមដោះលែងអនីតិជន ដើម្បីទទួលកម្មវិធីសមាហារណកម្ម ។

បែបបទនៃការគ្រប់គ្រងអនីតិជនក្នុងមណ្ឌលយុវនីតិសម្បទាដែលត្រូវជាប់ឃុំ ត្រូវកំណត់ដោយប្រកាសអន្តរក្រសួងរវាងរដ្ឋមន្ត្រីក្រសួងទទួលបន្ទុកវិស័យយុវនីតិសម្បទា ។ បែបបទ និងនីតិវិធីនៃការផ្ទេរ ការប្រគល់ និងការទទួលអនីតិជន ត្រូវកំណត់ដោយប្រកាសអន្តរក្រសួងរវាងរដ្ឋមន្ត្រីទទួលបន្ទុក វិស័យសង្គមកិច្ច រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងក្រសួងយុត្តិធម៌ ។

ចំណែកឯការរក្សាអនីតិជននៅក្នុងមណ្ឌលយុវនីតិសម្បទាដូចជា ៖

- ➢ អនីតិជនត្រូវដាក់ដោយឡែកពីនីតិជន
- ➢ នៅក្នុងអាគារដាច់ដោយឡែកទៅតាមភេទផ្សេងគ្នា តាមប្រភេទ និងស្ថានភាពនៃបទល្មើស អាយុ អត្តចរិត សុខភាពផ្លូវកាយ និង ផ្លូវចិត្តរបស់អនីតិជន ។ អនីតិជនភេទស្រីត្រូវស្ថិតនៅក្រោមការថែទាំរបស់បុគ្គលិកភេទស្រីដូចគ្នា
- ➢ នៅអាគារដាច់ដោយឡែក និងដឹកជញ្ជូនតាមមធ្យោបាយដាច់ដោយឡែកសម្រាប់អនីតិជនដែលមានជម្ងឺឆ្លង ។

[38] មាត្រា ៧៩ នៃច្បាប់ស្តីពីយុត្តិធម៌អនីតិជន ឆ្នាំ២០១៦

៣.២. សិទ្ធិជាមូលដ្ឋានរបស់អនីតិជនក្នុងមណ្ឌលយុវនីតិសម្បទា

អនីតិជនដែលជាប់ឃុំនៅក្នុងមណ្ឌលយុវនីតិសម្បទា ទាំងអស់ត្រូវទទួលបានសិទ្ធិជាមូលដ្ឋានដូចតទៅ ៖

- ✓ សិទ្ធិទទួលបានការសិក្សាអប់រំ
- ✓ សិទ្ធិរួចផុតពីការធ្វើឬទារុណកម្ម អំពើឃោរឃៅ អមនុស្សធម៌ បន្ទាបបន្ថោក ការដាក់ទណ្ឌកម្មលើរូបកាយ និងផ្លូវចិត្ត ឬប្រើប្រាស់ទម្រង់ផ្សេងៗសម្រាប់ធ្វើទណ្ឌកម្ម រួមមានការដាក់ឲ្យនៅឯកា ការដាក់កំហិត ឬបដិសេធមិនឲ្យមានការប្រាស្រ័យទាក់ទងជាមួយក្រុមគ្រួសារ ការកាត់បន្ថយចំណីអាហារ និងពលកម្មដោយបង្ខំ
- ✓ សិទ្ធិទទួលបានវិធានការដាក់វិន័យដែលស្របតាមសេចក្ដីថ្លៃថ្នូររបស់អនីតិជន
- ✓ សិទ្ធិទទួលបានការណែនាំអំពីបទបញ្ជាផ្ទៃក្នុង អំពីសិទ្ធិ និងកាតព្វកិច្ច
- ✓ សិទ្ធិផ្ដល់ដំណឹងអំពីការឃុំខ្លួន ការផ្ទេរ ការដោះលែងទៅអ្នកតំណាងដែលច្បាប់បានកំណត់ អ្នកទំនុកបម្រុង និងមេធាវី
- ✓ សិទ្ធិទទួលបានការការពារ ការពិនិត្យសុខភាព និងការព្យាបាលជម្ងឺ ឬរបួស និងផ្ដល់ដំណឹងទៅឪពុកម្ដាយ ឬអ្នកអាណាព្យាបាលសម្រាប់អនីតិជន ឬអ្នកអាណាព្យាបាលទូទៅ អ្នកទំនុកបម្រុង និងមេធាវី
- ✓ សិទ្ធិទទួលបានការអនុញ្ញាតឲ្យមានការសួរសុខទុក្ខ ជាលក្ខណៈឯកជនពីសំណាក់សមាជិកគ្រួសារ ឬមិត្តភក្ដិ និង
- ✓ សិទ្ធិផ្សេងទៀតដែលទទួលស្គាល់ដោយបទដ្ឋានគតិយុត្តិជាធរមាន ។

ចំណែកឯការចុះឈ្មោះអនីតិជនក្នុងបញ្ជី គ្រប់មណ្ឌលយុវនីតិសម្បទា ត្រូវមានបញ្ជី និងនីតិវិធីដោយឡែកសម្រាប់ចុះឈ្មោះ និងគ្រប់គ្រងអនីតិជន ព្រមទាំងបំពេញព័ត៌មានពាក់ព័ន្ធទាំងអស់ និងរក្សាឲ្យមានសុវត្ថិភាព ។ បញ្ជី និងនីតិវិធីដោយឡែកនេះ ត្រូវកំណត់ដោយប្រកាសអន្តរក្រសួងរវាងរដ្ឋមន្ត្រីក្រសួងទទួលបន្ទុកវិស័យសង្គមកិច្ច និងរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ។

៣.៣. ការធ្វើអធិការកិច្ចមណ្ឌលយុវនីតិសម្បទា

អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ ព្រះរាជអាជ្ញាអមសាលាដំបូង ប្រធានសភាស៊ើបសួរ ចៅក្រមស៊ើបសួរ ត្រូវធ្វើអធិការកិច្ចជាប្រចាំលើមណ្ឌលយុវនីតិសម្បទា ដែលស្ថិតនៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន និងធានាថាលក្ខខណ្ឌនៃការប្រព្រឹត្ត និងការឃុំខ្លួនត្រូវអនុវត្តដោយអនុលោមតាមក្រមនីតិវិធីព្រហ្មទណ្ឌ និងច្បាប់ជាធរមាន ។ យន្តការបង្ការថ្នាក់ជាតិ និងមន្ត្រីមានសមត្ថកិច្ចផ្សេងទៀត ដែលអនុញ្ញាតដោយច្បាប់មានសិទ្ធិធ្វើទស្សនៈកិច្ចមណ្ឌលយុវនីតិសម្បទានានាបាន

គ្រប់ពេល ។

៣.៤. ភ្នាក់ងារសង្គមកិច្ច

ការតែងតាំង ការទទួលស្គាល់ និងការគ្រប់គ្រងភ្នាក់ងារសង្គមកិច្ចជាសមត្ថកិច្ចរបស់ក្រសួងទទួលបន្ទុកវិស័យសង្គមកិច្ច ។ បែបបទនៃការតែងតាំង និងការទទួលស្គាល់ភ្នាក់ងារសង្គមកិច្ច ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីទទួលបន្ទុកវិស័យសង្គមកិច្ច ។

ភ្នាក់ងារសង្គមកិច្ចមានភារកិច្ចជាអាទិ៍ ៖

- ជួបអនីតិជនគ្រប់ដំណាក់កាលនៃនីតិវិធី ជាពិសេស នៅដំណាក់កាលដំបូងនៃនីតិវិធីរបស់ មន្ត្រីនគរបាលយុត្តិធម៌ និងនៅក្នុងពន្ធនាគារដើម្បីប្រមូលព័ត៌មានវាយតម្លៃ និងផ្តល់សេវាជាបន្ទាន់ដល់អនីតិជន ។
- ប្រមូលព័ត៌មានស្តីពីស្ថានភាពគ្រួសារ អាកប្បកិរិយា ប្រវត្តិអប់រំ ការសិក្សា លក្ខខណ្ឌដែលទាក់ទងនឹងការរស់នៅ ការរីកលូតលាស់ និងព័ត៌មានពាក់ព័ន្ធផ្សេងទៀតដែលទាក់ទងនឹងកម្រិតយល់ដឹង បញ្ហាអារម្មណ៍ ផ្លូវចិត្ត សង្គមរបស់អនីតិជន ដើម្បីរៀបចំ និងផ្តល់របាយការណ៍ និងយោបល់ស្តីពីប៉ាន់ប្រមាណសុខុមាលភាព និងស្ថានភាពសង្គមរបស់អនីតិជនជូនចៅក្រម អយ្យការ និងតុលាការ ។
- ផ្តល់ការគាំទ្រផ្លូវចិត្ត និងសង្គមដល់អនីតិជននៅគ្រប់ដំណាក់កាលនៃនីតិវិធី
- រៀបចំ និងផ្តល់ផែនការបង្វែរដល់អាជ្ញាធរទទួលបន្ទុកបង្វែរដើម្បីពិនិត្យ និងសម្រេច
- ផ្តល់សេវាស្តារនីតិសម្បទា និងធ្វើសមាហារណកម្មអនីតិជន
- ភារកិច្ចចាំបាច់ផ្សេងទៀតដែល កំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងទទួលបន្ទុកវិស័យសង្គមកិច្ច ។

ផ្នែកទី ៤ : ការដោះលែង ការលើកលែងទោស និងការបន្ថយទោសអនីតិជន

៤.១. ការដោះលែងដោយមានលក្ខខណ្ឌ

ដើម្បីអាចឲ្យមានការដោះលែងដោយមានលក្ខខណ្ឌអាចយកមកអនុវត្តបាននោះ ច្បាប់បានកំណត់អំពីលក្ខខណ្ឌដូចតទៅនេះ ៖

៤.១.១. លក្ខខណ្ឌទាក់ទងនឹងបុគ្គល

បុគ្គលដែលមានសិទ្ធិស្នើសុំដោះលែងអនីតិជនដោយមានលក្ខខណ្ឌ រួមមាន ៖

- ✓ ទណ្ឌិតដែលជាអនីតិជន ឬមេធាវីរបស់ជននោះ
- ✓ អ្នកតំណាងដែលច្បាប់បានកំណត់
- ✓ ប្រធានមណ្ឌលយុវនីតិសម្បទា
- ✓ ភ្នាក់ងារសង្គមកិច្ចដែលពាក់ព័ន្ធនឹងរឿងក្តីអនីតិជននោះ

✓ បេសកកម្មទូត ឬកុងស៊ុលបរទេស ក្នុងករណីអនីតិជនជាជនបរទេស ។

៤.១.២. លក្ខខណ្ឌផាត់ឆងនឹងគំនិត មារយាទ និងការទទួលរងទោស

គ្រប់ទណ្ឌិត ដែលត្រូវទទួលរងទោសដាក់ពន្ធនាគារមួយ ឬច្រើនអាចត្រូវដោះលែងដោយមានលក្ខខណ្ឌ ប្រសិនបើទណ្ឌិតនោះបានបង្ហាញឲ្យឃើញថាខ្លួនមានគំនិតមារយាទល្អក្នុងរយៈពេលជាប់ឃុំ និងមាននីតិសម្បទាដែលអាចបញ្ចូលខ្លួនទៅក្នុងសង្គមវិញបាន។ លើសពីនេះការដោះលែងដែលមានលក្ខខណ្ឌអាចផ្តល់ទៅឲ្យទណ្ឌិតជាអនីតិជន ដែលបានទទួលរងទោសក្នុងមណ្ឌលយុវនីតិសម្បទា ៖

➢ ទណ្ឌិតបានបំពេញទោសចំនួនមួយភាគបីនៃទោសរបស់ខ្លួន ដែលតុលាការបានផ្តន្ទាទោសនោះសិន ប្រសិនបើទោសតិចជាង ឬស្មើ ១(មួយ)ឆ្នាំ

➢ ចំនួនពាក់កណ្តាលនៃទោស ក្នុងករណីផ្សេងទៀត ឬក្នុងករណីអនីតិជនមានបញ្ហាសុខភាព ឬមានគភ៌ ។

៤.២. ការលើកលែងទោស និងការបន្ធូរបន្ថយទោសចំពោះអនីតិជន

ការលើកលែងទោស និងការបន្ធូរបន្ថយទោសចំពោះអនីតិជន ត្រូវអនុវត្តទៅតាមនីតិវិធីដែលមានជាធរមាន ដោយផ្តល់អាទិភាពដល់ការដោះលែងឲ្យនៅក្រៅឃុំ ។ ការពិចារណាជាពិសេស និងអាទិភាពត្រូវផ្តល់ឲ្យអនីតិជនក្រោមបញ្ញត្តិនៃនេះ ក្នុងការទទួលបានការបន្ធូរបន្ថយទោស និងការលើកលែងទោស ។

សេចក្តីសន្និដ្ឋាន

សេចក្តីសន្និដ្ឋាន

បន្ទាប់ពីបានធ្វើការបកស្រាយពីខាងលើយ៉ាងល្អិតល្អន់រួចមក ចំណុចសំខាន់ៗជាច្រើនដែលទាក់ទងជាមួយយុត្តិធម៌សម្រាប់អនីតិជនក្នុងរឿងក្តីព្រហ្មទណ្ឌ ត្រូវបានស្រាយបំភ្លឺកាន់តែច្បាស់ ។ នៅពេលដែលអនីតិជនបានប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌណាមួយ ច្បាប់តម្រូវឲ្យអាជ្ញាធរមានសមត្ថកិច្ច ត្រូវតែអនុវត្តយ៉ាងដាច់ខាតទៅតាមនីតិវិធីទាំងឡាយ និងត្រូវគោរពតាមឲ្យបានហ្មត់ចត់ ក្នុងគោលបំណងដើម្បីធ្វើការពិនិត្យ ស្រាវជ្រាវឲ្យឃើញពីនត្ថិភាព ឬអត្ថិភាព ឬការកើតមានឡើងនូវបទល្មើសដែលប្រព្រឹត្តឡើងដោយអនីតិជន ។ ក៏ប៉ុន្តែអាជ្ញាធរមានសមត្ថកិច្ច មិនបានអនុវត្តទៅតាមនីតិវិធីទាំងនោះឲ្យបានត្រឹមត្រូវនោះទេ ជាហេតុដែលនាំឲ្យមានមោយ:ភាពនៃនីតិវិធីទាំងនោះកើតឡើង ។ ជាងនេះទៅទៀត ច្បាប់ស្តីពីយុត្តិធម៌អនីតិជនបានផ្តល់អាទិភាព និងការពារអនីតិជនយ៉ាងខ្លាំងក្លាបំផុត ដែលក្នុងនោះរួមមានជាអាទ៍ សិទ្ធិជាមូលដ្ឋានក្នុងកិច្ចនៃនីតិវិធីនៅពេលដែលអនីតិជនបានប្រព្រឹត្តបទល្មើស តាំងពីដំណាក់កាលនគរបាលយុត្តិធម៌រហូត ដល់ដំណាក់កាលជំនុំជម្រះដែលមានដូចជា សិទ្ធិមានមេធាវីក្នុងការផ្តល់ជំនួយផ្នែកច្បាប់ដល់ខ្លួន និងការសន្មតជាមុនថាគ្មានទោស ដរាបណាមិនទាន់មានការប្រកាសទោសដោយតុលាការនោះទេ ។ បន្ថែមពីនេះទៀត បើទោះបីជាអនីតិជនពិតជាបានប្រព្រឹត្តបទល្មើសពិតមែនក៏ដោយ តែច្បាប់បានផ្តល់នូវសិទ្ធិអំណាចដល់អនីតិជននោះយ៉ាងធំទូលាយ ដូចជាយន្តការនៃបង្វែរអនីតិជនចេញពីនីតិវិធីរបស់តុលាការព្រហ្មទណ្ឌ ដោយការប្រគល់អនីតិជនទៅអ្នកមានអំណាចមេបា ឬអ្នកដែលមាននីតិសម្បទាក្នុងការគ្រប់គ្រងអនីតិជន នៅក្នុងករណីអនីតិជននោះមិនទាន់គ្រប់អាយុដើម្បីទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌ ។ លើសពីនេះទៅទៀត យន្តការនៃការបង្វែរនេះបានផ្តល់នូវអត្ថប្រយោជន៍យ៉ាងច្រើនដល់អនីតិជនដូចជា បានធ្វើឲ្យអនីតិជននោះបានយល់ពីផលប៉ះពាល់នៃអាកប្បកិរិយារបស់ខ្លួនចំពោះជនរងគ្រោះ ធ្វើការកែប្រែកំហុសឆ្គងដែលបង្កឡើងដោយអំពើល្មើស ហើយអ្វីដែលសំខាន់នោះ គឺមិនមានការធ្វើការដកហូតនូវសិទ្ធិសេរីភាព ឬឃុំឃាំងអនីតិជនក្នុងទម្រង់នៃការដាក់ទោសណាមួយឡើយ ។

ម្យ៉ាងវិញទៀតប្រសិនបើអនីតិជននោះ បានដល់នីតិភាពនៃការទទួលខុសត្រូវព្រហ្មទណ្ឌហើយនោះ មានយន្តការផ្សេងទៀតដូចជា ការដាក់ឲ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ ការដោះលែងឲ្យនៅក្រៅឃុំដែលនីតិវិធីទាំងនេះ បានផ្តល់សិទ្ធិដល់អនីតិជនយ៉ាងខ្លាំង ។ មានន័យថាទោះបីជាបានប្រព្រឹត្តបទល្មើសមែនក៏ដោយ ក៏ខ្លួនមិនត្រូវបានដកហូតនូវសិទ្ធិសេរីភាពនោះទេ ហើយខ្លួនអាចប្រើប្រាស់នូវសិទ្ធិដែលខ្លួនធ្លាប់មានពីមុនបាន ប៉ុន្តែអាចមានករណីខ្លះមានសិទ្ធិមួយចំនួនមិនអាចត្រូវបានអនុញ្ញាតឲ្យប្រើផងដែរ នៅពេលដែលមានការ

បង្គាប់បញ្ជាពីអាជ្ញាធរមានសមត្ថកិច្ច ក្នុងគោលបំណងដើម្បីការពារនូវប្រយោជន៍របស់អនីតិជន ឬបង្ការកុំឲ្យមានបទល្មើសថ្មីកើតមានឡើងទៀត និងជាពិសេសនោះគឺការពារប្រយោជន៍សង្គមទាំងមូល ។ ប៉ុន្តែប្រសិនបើក្នុងករណីអនីតិជនមិនបាន អនុវត្តតាម ឬប្រតិបត្តិតាមឲ្យបានត្រឹមត្រូវទៅតាមការបង្គាប់បញ្ជារបស់អាជ្ញាធរមានសមត្ថកិច្ចនោះទេ នឹងត្រូវមានទណ្ឌកម្មផ្សេងៗទៀត និងត្រូវយកមកអនុវត្តចំពោះខ្លួនដូចជា ការយកមកឃុំខ្លួនបណ្តោះអាសន្នជាដើម ។

ចំពោះការអនុវត្តទោសរបស់អនីតិជន មានលក្ខណៈពិសេសខុសពីនីតិជនផងដែរ នៅពេលដែលតុលាការប្រកាសទោសឲ្យជាប់ពន្ធនាគារ ទោសរបស់អនីតិជនស្ថិតនៅក្រោមអប្បបរមាដែលទាបបំផុតខុសពីនីតិជន ។ លើសពីនេះទៅទៀត អនីតិជនមិនបានដាក់នៅក្នុងពន្ធនាគារនោះទេ ដែលផ្ទុយពីច្បាប់ស្តីពីពន្ធនាគារ និងលិខិតបទដ្ឋានគតិយុត្តផ្សេងទៀត ។ មានន័យថា រាល់បុគ្គលគ្រប់រូបៗដែលមានសាលក្រម ឬសាលដីកា ដែលត្រូវបានតុលាការធ្វើការផ្តន្ទាទោសឲ្យជាប់ពន្ធនាគារជាស្ថាពរ និងត្រូវយកមកអនុវត្តទោសនៅក្នុងពន្ធនាគារទាំងអស់ ។ ប៉ុន្តែផ្ទុយទៅវិញ ច្បាប់ស្តីពីយុត្តិធម៌អនីតិជន ឆ្នាំ២០១៦ យកអនីតិជនដែលបានប្រព្រឹត្តបទល្មើសយកមកធ្វើការរក្សាទុកក្នុងមណ្ឌលយុវនីតិសម្បទាដោយត្រូវដាក់អនីតិជននោះដាច់ដោយឡែកពីនីតិជន ហើយនៅក្នុងអគារដាច់ដោយឡែកទៅតាម ភេទ ប្រភេទ និងស្ថានភាពនៃបទល្មើស អាយុ អត្តចរិត សុខភាពផ្លូវកាយ និងផ្លូវចិត្តរបស់អនីតិជន ។

អនុសាសន៍

អនុសាសន៍

បើទោះបីជាអនីតិជន ដែលបានប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌ ហើយត្រូវបានតុលាការធ្វើការ ផ្តន្ទាទោសតាមរយៈការដាក់ក្នុងមណ្ឌលយុវនីតិសម្បទា ឬមានទណ្ឌកម្មផ្សេងទៀតត្រូវបានច្បាប់ជាតិ ក៏ដូចជាច្បាប់អន្តរជាតិ បានផ្តល់ឲ្យនូវសិទ្ធិឲ្យយ៉ាងច្រើនសន្ធឹកសន្ធាប់ក៏ពិតមែន ដូចជា (ក្រមព្រហ្មទណ្ឌ ឆ្នាំ២០១០, ក្រមនីតិវិធីព្រហ្មទណ្ឌ ២០០៧ , អនុសញ្ញាស្តីពីសិទ្ធិកុមារ និងច្បាប់ ផ្សេងៗទៀត ជាពិសេសនោះគឺច្បាប់ស្តីពីយុត្តិធម៌អនីតិជន ជាច្បាប់ពិសេសដែលអនុវត្តចំពោះតែអនីតិជនដែលបានប្រព្រឹត្តបទល្មើសណាមួយតែប៉ុណ្ណោះ)។ ប៉ុន្តែផ្ទុយទៅវិញភាពខ្វះខាតមួយចំនួននៅតែមានផងដែរ។ បើទោះបីជាអនីតិជនជាប់សង្ស័យថាបាន ឬមិនបានប្រព្រឹត្តបទល្មើសមែនច្បាប់ស្តីពីយុត្តិធម៌អនីតិជនតម្រូវឲ្យស្ថាប័នមានសមត្ថកិច្ច ត្រូវតែអនុវត្តដោយគោរពតាមនីតិវិធីទាំងឡាយ ដែលបានចែងឲ្យបានហ្មត់ចត់ ដើម្បីកំណត់ឲ្យបានច្បាស់លាស់នូវអត្ថិភាពនៃបទល្មើសព្រហ្មទណ្ឌណាមួយ ដែលប្រព្រឹត្តដោយអនីតិជន ។ ដោយហេតុថា បទល្មើសទាំងនោះអាចនាំឲ្យមានផលប៉ះពាល់យ៉ាងធ្ងន់ធ្ងរ ដល់កិត្តិយស សេចក្ដីថ្លៃថ្នូរ ខាតបង់ពេលវេលា និងការសិក្សា។ ហើយបើយោងតាមច្បាប់កំពូល គឺរដ្ឋធម្មនុញ្ញដែលបានកំណត់ទុកជាមុននូវគោលការណ៍មួយដ៏សំខាន់ គឺគោលការណ៍សច្ចធារណ៍នៃនិរទេសឬគោលការណ៍សន្ទតជាមុនថាគ្មានទោស ដរាបណាមិនទាន់មានការប្រកាសទោសដោយតុលាការនោះទេ ។

ការបង្ក្រាបបទល្មើស ឬបង្ការកុំឲ្យមានការប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌណាមួយដែលប្រព្រឹត្តដោយអនីតិជននោះ រដ្ឋគប្បីមានវិធានការណ៍ឲ្យបានច្បាស់លាស់ និងយ៉ាងជាក់លាក់បំផុត ដែលតម្រូវឲ្យមានការចូលរួមពីសំណាក់ភាគីពាក់ព័ន្ធមួយចំនួនដែលរួមមាន រាជរដ្ឋាភិបាលស្ថាប័នមានសមត្ថកិច្ច តុលាការ និងប្រជាពលរដ្ឋដោយផ្ទាល់តែម្តង។ ជាដំបូងរាជរដ្ឋាភិបាលដែលជាស្ថាប័នមានសិទ្ធិអំណាចក្នុងការគ្រប់គ្រងដឹកនាំប្រទេសជាតិដែលមានក្រសួង ឬស្ថាប័នផ្សេងៗទៀតជាសេនាធិការត្រូវផ្សព្វផ្សាយ និងអប់រំអំពីសិទ្ធិរបស់កុមារក្នុងប្រព័ន្ធអប់រំ ដោយហេតុថានៅពេលដែលអនីតិជនទាំងអស់នោះបានយល់ពីសិទ្ធិរបស់ខ្លួន ថាតើអាចប្រើប្រាស់សិទ្ធិសេរីភាពនោះបានកម្រិតណានោះ អំពើល្មើស នឹងមិនកើតមានឡើងនោះទេ ។ មានន័យថា បុគ្គលទាំងនោះនឹងមានភាពខ្លាចរអានូវទណ្ឌកម្ម ដែលពួកគេអាចនឹងទទួលនៅពេលដែលគេប្រើប្រាស់សិទ្ធិនោះហួសដែនកំណត់ ។ បន្ថែមពីនេះទៀត ត្រូវមានការអប់រំអំពីបញ្ហាផ្លូវច្បាប់ឲ្យមានច្រើនធ្វើការផ្សព្វផ្សាយតាមរយៈ កាសែត ទស្សនាវដ្ដី ទូរទស្សន៍ និងបណ្ដាញសង្គមហ្វេសប៊ុកមួយចំនួន ដែលជាហេតុនាំឲ្យប្រជាជនបានយល់ដឹងពីច្បាប់ និងអាចទប់ស្កាត់មិនឲ្យមានការកើតឡើងនៃចំនួនបទល្មើស ។

ម្យ៉ាងវិញទៀតកត្តាគ្រួសារ ក៏ជាចំណែកមួយក្នុងការទប់ស្កាត់អនីតិជនមិនឲ្យប្រព្រឹត្តបទល្មើសផងដែរ មានន័យថានៅពេលដែលគ្រួសារមិនដែលបានបង្ហាត់បង្រៀនកូននិងពន្យល់បន្ថែមពីបញ្ហាផ្លូវច្បាប់ចំពោះកូនថែមទាំងតែងតែមានអំពើហិង្សាក្នុងគ្រួសារច្រើននោះជាហេតុនាំឲ្យកូនយកគម្រូតាម ។ ដូចនេះសមាជិកក្នុងគ្រួសារ ត្រូវតែមានភាពស្និទ្ធស្នាលចំពោះកូន ហើយពួកគាត់ត្រូវតែបង្ហាត់បង្រៀនឲ្យកូនធ្វើជា កូនល្អ សិស្សល្អ និងពលរដ្ឋល្អនៅក្នុងសង្គមជាតិ និងត្រូវធ្វើការពន្យល់ពីបញ្ហាផ្លូវច្បាប់ចំពោះកូនរបស់ខ្លួនផងដែរ ថាតើអំពើនេះ ឬអំពើនោះត្រូវបានច្បាប់ហាមឃាត់ ហើយបើសិនបានធ្វើខុសនោះនឹងត្រូវមានទណ្ឌកម្មយកអនុវត្តចំពោះខ្លួន ។

ជាពិសេសមួយទៀតស្ថាប័នតុលាការ ដែលជាស្ថាប័នមានសមត្ថកិច្ចក្នុងកំណត់ថាអំពើណាមួយជាបទល្មើស ជាស្ថាប័នដែលមានសិទ្ធិអំណាចក្នុងការសម្រេចសេចក្ដីថាបុគ្គលណាមួយមានពិរុទ្ធភាព ឬគ្មានពិរុទ្ធភាពតាមនីតិវិធីទាំងឡាយដែលមានចែងក្នុងក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ ២០០៧ និងក្រមព្រហ្មទណ្ឌ ឆ្នាំ ២០១០ រួមទាំងច្បាប់ដោយឡែកផ្សេងទៀត ជាពិសេសច្បាប់ស្ដីពីយុត្តិធម៌អនីតិជន។ បើទោះបីជាច្បាប់ស្ដីពីយុត្តិធម៌អនីតិជន តម្រូវឲ្យស្ថាប័នដែលទទួលបន្ទុកចាត់ការរឿងក្ដីអនីតិជន ដែលបានប្រព្រឹត្តបទព្រហ្មទណ្ឌ ត្រូវអនុវត្តឲ្យបានត្រឹមត្រូវតាមច្បាប់នេះក៏ពិតមែន តែដោយសារតែច្បាប់នេះនៅមានចំណុចមួយចំនួនមិនអនុវត្តបានពេញលេញនៅឡើយ ។

គួរកត់សម្គាល់ថា នៅក្នុងការអនុវត្តជាក់ស្ដែង នៅក្នុងស្ថាប័នដែលទទួលបន្ទុកចាត់ការរឿងក្ដី អនីតិជននេះក៏ឃើញមាននូវចំនុចគប្បីធ្វើការកែតម្រូវមួយចំនួនដូចជា ការជំនុំជម្រះអនីតិជនជាសាធារណៈ រាល់ការបង្ហែរនៅមិនទាន់អាចអនុវត្តបានឲ្យពេញលេញនៅឡើយ ករណីខ្លះមិនមានការបំបែកសំណុំរឿងនៅឡើយនោះទេគឺធ្វើការជំនុំជម្រះអនីតិជនជាមួយនឹងនីតិជនតែម្ដង ហើយនៅតាមអង្គភាពនគរបាលខ្លះ ពិសេសនៅតាមបណ្ដាខេត្ត ឬស្រុកមួយចំនួនមិនទាន់មានការិយាល័យមេធាវី ឬអង្គការជំនួយផ្នែកច្បាប់ ដើម្បីចាំជួយផ្ដល់ជំនួយផ្នែកច្បាប់តាមរយៈមេធាវីដោយមិនយកកម្រៃនោះទេ ។

ជាចុងក្រោយសម្រាប់ទស្សនៈរបស់ក្រុមយើងខ្ញុំ មើលឃើញថាការអនុវត្តច្បាប់ស្ដីពីយុត្តិធម៌សម្រាប់អនីតិជននៅមានភាពខ្វះចន្លោះច្រើន ដូចនេះរដ្ឋាភិបាលត្រូវតែពង្រឹងវិស័យយុត្តិធម៌អនីតិជន ជាពិសេសការអនុវត្តច្បាប់ក្នុងដំណើការរឿងក្ដី ឲ្យល្អប្រសើរតាំងពីដំណាក់កាលដំបូងរហូតដល់ការអនុវត្តទោសចប់របស់អនីតិជន ព្រោះដើម្បីការពារអនីតិជន សេចក្ដីថ្លៃថ្នូរកិត្តិយស និងឧត្តមប្រយោជន៍អនីតិជនដែលបានប្រព្រឹត្តបទល្មើសឲ្យបានសុក្រឹត្យភាព កុំឲ្យមានការអនុវត្តខុសពីនីតិវិធីដែលមានចែងក្នុងច្បាប់ ។

ឥន្ទសិទ្ធេស

គន្ថនិទ្ទេស

លិខិតបទដ្ឋានគតិយុត្តិជាតិ

១. រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ១៩៩៣ និងច្បាប់ស្តីពីវិសោធនកម្មរដ្ឋធម្មនុញ្ញ ចុះថ្ងៃទី ២៨ តុលា ឆ្នាំ ២០១៤

២. ច្បាប់ស្តីពីយុត្តិធម៌អនីតិជន ប្រកាសឲ្យប្រើប្រាស់នៅថ្ងៃទី ១៤ ខែកក្កដា ឆ្នាំ ២០១៦

៣. ច្បាប់ស្តីពីពន្ធនាគារ ប្រកាសឲ្យប្រើប្រាស់នៅថ្ងៃទី ១៦ ខែធ្នូ ឆ្នាំ ២០១១

៤. ច្បាប់ស្តីពីយុត្តិធម៌អនីតិជនទំនាស់នឹងច្បាប់កែសម្រួល ខែសីហា ឆ្នាំ ២០១០

៥. ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ប្រកាសឲ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/១១០៩/០២ ចុះថ្ងៃទី ៣០ វិច្ឆិកា ឆ្នាំ ២០០៩

៦. ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ប្រកាសឲ្យនៅថ្ងៃទី ១០ ខែ សីហា ឆ្នាំ ២០០៧ និងច្បាប់ស្តីពីវិសោធនកម្ម ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០៦ មិថុនា ឆ្នាំ ២០១៣

៧. ក្រមរដ្ឋប្បវេណី ប្រកាសឲ្យប្រើនៅថ្ងៃទី ០៨ ខែធ្នូ ឆ្នាំ ២០០៧

៨. អនុក្រឹត្យស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់មណ្ឌលយុវនីតិសម្បទា ប្រកាសឲ្យប្រើប្រាស់នៅថ្ងៃទី ២៩ ខែកញ្ញា ឆ្នាំ ២០១៧

៩. ច្បាប់ស្តីពីយុត្តិធម៌អនីតិជនទំនាស់នឹងច្បាប់កែសម្រួលក្រោយពីប្រជុំ ខែសីហា ឆ្នាំ ២០១១

១០. សៀវភៅសារណា យុត្តិធម៌អនីតិជនទំនាស់នឹងច្បាប់ រៀបរៀងដោយ ឈឹន មុន្នី និង ហ្ជូត ថារ៉ារិត ឆ្នាំ

១១. សៀវភៅសារណា អនីតិជនក្នុងរឿងក្តីអនីតិជន រៀបរៀងដោយ ហ្ជូ ស៊ីយ៉ែ និង ឡ្ចឹក សុភារ៉ីកា ឆ្នាំ ២០១៧

លិខិតបទដ្ឋានគតិយុត្តិអន្តរជាតិ

១២. សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស ចុះថ្ងៃទី ១០ ខែធ្នូ ឆ្នាំ ១៩៤៨

១៣. អនុសញ្ញាអន្តរជាតិស្តីពីសិទ្ធិកុមារ ចុះថ្ងៃទី ២០ ខែ វិច្ឆិកា ឆ្នាំ ១៩៨៩

១៤. វិធានជាបទដ្ឋានអប្បបរមានៃអង្គការសហប្រជាជាតិសំរាប់គ្រប់គ្រងវិស័យយុត្តិធម៌អនីតិជន ឆ្នាំ ១៩៨៥ វិធានក្រុងប៉េកាំង

ឧបសម្ព័ន្ធ